ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ..០៦៦..សណ.ជ.ណ/គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី..០៥ ខែ..កុម្ភៈ.. ឆ្នាំ២០១៣

**គោរពជូន**

**ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត**

**ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ**

**កម្មវត្ថុ** ៖ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពី ការបង្កើតក្រុមកែលម្អជីវភាព នៃគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប ។

**យោង** ៖កិច្ចព្រមព្រៀងហិរញ្ញប្បទានលេខ 2599 និង 0186-CAM (SF) ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៩ រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ។

**ជូនភ្ជាប់** ៖ឯកសារគោលការណ៍ណែនាំស្តីពីការបង្កើតក្រុមកែលម្អជីវភាព

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប (TS-PRSDP) បាននិងកំពុងអនុវត្តនៅក្នុងខេត្តគោលដៅបួនរួមមាន ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ ។ លេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំចងក្រងគោលការណ៍ណែនាំនេះ ដើម្បីជាមូលដ្ឋានសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធផ្សេងទៀតយកទៅប្រើប្រាស់ក្នុងការបង្កើតក្រុមកែលម្អជីវភាពដែលជាក្រុមអ្នកទទួលផលជាក់មួយ ហើយដែលនឹងទទួលបានការគាំទ្រពីគម្រោងតាមរយៈមូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ ។ គោលការណ៍ណែនាំនេះ នឹងពន្យល់ពីដំណើរការនៃការជ្រើសរើសភូមិគោលដៅ ការកំណត់ពីគ្រួសារក្រីក្រ និងការរៀបចំបង្កើតក្រុមកែលម្អជីវភាព ។ ក្នុងន័យនេះ ដើម្បីឱ្យការកំណត់ ជ្រើសរើស និងការបង្កើតបានក្រុមអ្នកទទួលផលពីគម្រោងមួយជាក់លាក់ប្រព្រឹត្តិទៅប្រកបដោយតម្លាភាព និងមានការចូលរួមនោះ លេខាធិការដ្ឋាន គ.ជ.អ.ប សូមដាក់ឱ្យប្រើប្រាស់នូវគោលការណ៍ណែនាំស្តីពីការបង្កើតក្រុមកែលម្អជីវភាពរបស់គម្រោង TS-PRSDP ។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាជ្រាប និងចាត់វិធានការអនុវត្តតាមការគួរ ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

អនុប្រធាន

**ង៉ាន់ ចំរើន**

ចម្លងជូនៈ

-ផ្នែកសម្របសម្រួលការអភិវឌ្ឍ(DCU)នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ធនាគារអភិវឌ្ឍន៍អាស៊ី

«ដើម្បីជូនជ្រាប»

-ឯកសារ-កាលប្បវត្តិ

គណ (NCDD logo text): គជអប NCDD

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

លេខាធិការដ្ឋាន

# គោលការណ៍ណែនាំ

# ស្តីពី

# ការបង្កើតក្រុមកែលម្អជីវភាព

## ក្រោមក្របខ័ណ្ឌគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប

*Loan: 2599/Grant 0186-CAM (SF)*

**Cambodia**
Tonle Sap Poverty Reduction and Smallholder Development Project




The designations employed and the presentation of the material in this map do not imply the expression of any opinion whatsoever on the part of IFAD concerning the delimitation of the frontiers or boundaries, or the authorities thereof.
IFAD *Map compiled by IFAD*

ឧបត្ថម្ភដោយ៖

IFAD Enabling poor rural people to overcome poverty

ADB

ខែមករា ឆ្នាំ២០១៣

# អារម្ភកថា

គោលការណ៍ណែនាំស្តីពីការបង្កើតក្រុមកែលម្អជីវភាព ត្រូវបានរៀបចំ និងចងក្រងដោយក្រុមការងារគម្រោងនៃលេខាធិការដ្ឋាន គ.ជ.អ.ប សហការជាមួយក្រុមការងារគម្រោងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងមន្ត្រីការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា និង IFAD ។

ការរៀបចំចងក្រងគោលការណ៍នេះ គឺផ្អែកតាមការប្រមូលផ្តុំឯកសារ និងបទពិសោធន៍ជាក់ស្តែងពីគម្រោង RULIP, RPRP, TSSLP ក្នុងគោលបំណងដើម្បីណែនាំដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការបង្កើតក្រុមកែលម្អជីវភាព ។

គោលការណ៍ណែនាំនេះ នឹងពន្យល់ពីដំណើរការនៃការជ្រើសរើសភូមិគោលដៅ ការកំណត់ពីគ្រួសារក្រីក្រ និងការរៀបចំបង្កើតក្រុមកែលម្អជីវភាព ។ គោលការណ៍ណែនាំក៏បានបរិយាយអំពីនីតិវិធីនានា សម្រាប់ការពង្រឹងក្រុមកែលម្អជីវភាពតាំងពីការកកើតជារូបរាងរហូតដល់ដំណាក់កាលដែលក្រុមអាចទ្រទ្រង់គ្រប់គ្រងបានដោយខ្លួនឯងផងដែរ ។ គោលការណ៍បង្កើតក្រុមក៏ផ្តល់ជាប្រយោជន៍ផងដែរ ដល់អ្នកអនុវត្តគម្រោងពិសេសនៅថ្នាក់ឃុំ សង្កាត់ ដើម្បីប្រើប្រាស់ជាមធ្យោបាយក្នុងរៀបចំបង្កើតក្រុមប្រកបដោយភាពត្រឹមត្រូវ តម្លាភាព មានការចូលរួម ហើយម្យ៉ាងទៀតវាអាចជួយដល់អ្នកផ្សព្វផ្សាយកសិកម្ម និងជំនួយការរដ្ឋបាលឃុំ សង្កាត់ ធ្វើជាឯកសារយោងមួយដើម្បីធានាការអនុវត្តប្រព្រឹត្តទៅបានដោយរលូនប្រកបដោយប្រសិទ្ធភាព ។

គោលការណ៍ណែនាំនេះមានសារៈសំខាន់បំផុត ដោយហេតុថាវាអាចជួយឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធដទៃទៀតកំណត់បាននូវក្រុមអ្នកទទួលផលដីជាក់លាក់មួយដែលនឹងត្រូវបានទទួលការគាំទ្រពីមូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ សម្រាប់កែលម្អជីវភាពរស់នៅឈានទៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

លេខាធិការដ្ឋាន គ.ជ.អ.ប សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមការងារគម្រោងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទីប្រឹក្សាគម្រោង ធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា និងអ្នកពាក់ព័ន្ធផ្សេងទៀត ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចូលរួមពិភាក្សា និងផ្តល់យោបល់កែលម្អគោលការណ៍ណែនាំនេះពីដើមរហូតមក ។

ដោយសារគោលការណ៍ណែនាំនឹងត្រូវដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធប្រើប្រាស់ជាលើកដំបូង ដូច្នេះ វាប្រាកដជាមានចំណុចខ្វះខាតមួយចំនួនជាមិនខាន អាស្រ័យហេតុនេះ លេខាធិការដ្ឋាន គ.ជ.អ.ប មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រី និងអ្នកពាក់ព័ន្ធទាំងអស់នឹងបន្តផ្តល់យោបល់កែលម្អដើម្បីធ្វើឱ្យគោលការណ៍ណែនាំនេះកាន់តែមានលក្ខណៈសមស្រប និងអាចយកទៅអនុវត្តតាមបានយ៉ាងមានប្រសិទ្ធភាព ។

ភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣

**រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជា**

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**សក់ សេដ្ឋា**

**មាតិកា** **ទំព័រ**

**១. សេចក្តីផ្តើម..........១**

**២. ឃុំ សង្កាត់គោលដៅ..........២**

២.១. ផែនទីភូមិសាស្រ្តឃុំ សង្កាត់គោលដៅនៃខេត្តទាំងបួន..........២

២.២. ផែនការអនុវត្តសម្រាប់ ១៩៦ ឃុំ សង្កាត់..........៦

**៣. ការជ្រើសរើសភូមិគោលដៅ..........៧**

៣.១. ការប្រជុំលើកទី១..........៧

៣.២. លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសភូមិ..........៧

៣.៣. ការប្រៀបធៀបកម្រិតភាពក្រីក្រក្នុងភូមិនិមួយៗ..........៨

៣.៤. ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ..........៨

៣.៥. ការចាត់អាទិភាពភូមិគោលដៅ..........១០

៣.៦. ការអនុម័តលើបញ្ជីឈ្មោះភូមិគោលដៅ..........១១

**៤. ដំណើរការជ្រើសរើសគ្រួសារគោលដៅ..........១២**

៤.១. ការប្រជុំភូមិលើកទី១..........១២

៤.២. ការជ្រើសរើសគ្រួសារគោលដៅ..........១៤

៤.៣. ការអង្កេតតាមគ្រួសារ..........១៦

៤.៤. ការប្រជុំភូមិលើកទី២..........១៦

៤.៥. ការចុះឈ្មោះចូលជាសមាជិកក្រុម..........១៦

៤.៦. ការបង្កើតក្រុមកែលម្អជីវភាព..........១៧

៤.៧. ការបង្កើតក្រុមមានចំណាប់អារម្មណ៍ដូចគ្នា (ក្រុមតូច)..........១៨

៤.៨. ការប្រកាសទទួលស្គាល់ក្រុមកែលម្អជីវភាព..........១៩

៤.៩. ចំនួនក្រុមកែលម្អជីវភាពនៅក្នុងឃុំ សង្កាត់គោលដៅដំណាក់កាលទី១..........១៩

**៥. ការគ្រប់គ្រងក្រុមកែលម្អជីវភាព ....... ២០**

៥.១. អ្នកដឹកនាំក្រុម ....... ២០

៥.២. សមាសភាពអ្នកដឹកនាំក្រុម ....... ២០

៥.៣. តួនាទី និងការទទួលខុសត្រូវ និងលក្ខណៈសម្បត្តិរបស់អ្នកដឹកនាំក្រុម ....... ២០

៥.៣.១ តួនាទីប្រធានក្រុម ....... ២០

៥.៣.២ តួនាទីអនុប្រធានក្រុម ....... ២១

៥.៣.៣ តួនាទីរបស់ហិរញ្ញឹក ....... ២២

៥.៤. តួនាទី និងការទទួលខុសត្រូវរបស់សមាជិកក្រុម ....... ២៣

៥.៥. អាណត្តិរបស់ប្រធានក្រុម ....... ២៤

៥.៦. រចនាសម្ព័ន្ធក្រុម ....... ២៥

**៦. ការគ្រប់គ្រងហិរញ្ញវត្ថុក្រុម ....... ២៦**

៦.១. ធនធានហិរញ្ញវត្ថុសម្រាប់ក្រុមកែលម្អជីវភាព ....... ២៦

៦.២. មុខសញ្ញាដែលត្រូវចំណាយ ....... ២៦

៦.៣. ប្រាក់កម្ចី ....... ២៦

៦.៤. ក្រុមសន្សំ ....... ២៧

៦.៥. ការរក្សាទុក និងដកប្រាក់ពីធនាគារ ....... ២៧

៦.៦. បញ្ជីគណនេយ្យ ....... ២៨

**៧. ការបណ្តុះបណ្តាល ....... ២៩**

៧.១. ប្រធានបទ ....... ២៩

៧.២. យុទ្ធសាស្ត្របណ្តុះបណ្តាល ....... ៣០

**៨. បទបញ្ជាផ្ទៃក្នុងរបស់ក្រុម ....... ៣១**

៨.១. សារៈសំខាន់ ............................................................ ៣១

៨.២. គំរូបទបញ្ជាផ្ទៃក្នុង ............................................................ ៣១

**៩. ការណែនាំស្ដីពីការប្រជុំក្រុម ............................................................ ៣៣**

៩.១. ការប្រជុំលើកទី១របស់ក្រុម ............................................................ ៣៣

៩.២. ការប្រជុំប្រចាំខែរបស់ក្រុម ............................................................ ៣៣

៩.២.១. សារៈសំខាន់............................................................ ៣៣

៩.២.២. របៀបវារៈ............................................................ ៣៤

៩.២.៣. ការផ្ដើមអង្គប្រជុំ............................................................ ៣៤

៩.២.៤. ការដឹកនាំអង្គប្រជុំ............................................................ ៣៥

៩.២.៥ ការបិទអង្គប្រជុំ............................................................ ៣៥

**១០. ការធ្វើផែនការក្រុម............................................................៣៦**

១០.១. តើផែនការជាអ្វី? ............................................................៣៦

១០.២. តើអ្នកណាជាអ្នកធ្វើផែនការ? ............................................................៣៦

១០.៣. តើធ្វើផែនការនោះមានលក្ខណៈបែបណា?............................................................ ៣៧

**១១. គោលការណ៍ឲ្យមាននិរន្តរភាពក្រុម ............................................................៣៨**

១១.១. ទុនពីខាងក្រៅ............................................................៣៨

១១.២. ទុនទ្រទ្រង់ ............................................................៣៨

១១.៣. ការវាយតម្លៃក្រុម............................................................៣៨

១១.៤. គោលការណ៍ទូទៅ............................................................៤១

**ឧបសម្ព័ន្ធ ២០១** ៖បញ្ជីឈ្មោះឃុំ សង្កាត់ និងកម្រិតភាពក្រីក្រ........................................................៤២

**ឧបសម្ព័ន្ធ ២០២** ៖តារាងប្រៀបធៀបកម្រិតនៃភាពក្រីក្រតាមភូមិនៃឃុំ សង្កាត់គោលដៅ.....................៤៨

**ឧបសម្ព័ន្ធ ២០៣** ៖បញ្ជីគ្រួសារក្រីក្រតាមភូមិនៃឃុំ សង្កាត់គោលដៅ........................................... ៥៤

**ឧបសម្ព័ន្ធ ២០៤** ៖បញ្ជីគ្រួសារក្រីក្រភូមិអាទិភាពពារបស់ឃុំ សង្កាត់គោលដៅ...................................៥៧

**ឧបសម្ព័ន្ធ ២០៥** ៖បញ្ជីសំនួរសម្រាប់អង្កេត ....................................................................................៥៨

**ឧបសម្ព័ន្ធ ២០៦** ៖ពាក្យសុំចុះឈ្មោះជាសមាជិកក្រុម ...................................................................៦០

**ឧបសម្ព័ន្ធ ២០៧** ៖ប័ណ្ណចំណូល ............................................................................................... ៦១

**ឧបសម្ព័ន្ធ ២០៨** ៖ប័ណ្ណចំណាយ ................................................................................................៦២

**ឧបសម្ព័ន្ធ ២០៩** ៖កិច្ចសន្យាខ្ចីប្រាក់ ...........................................................................................៦៣

**ឧបសម្ព័ន្ធ ២១០** ៖តារាងតាមដានប្រាក់កម្ចីរបស់ក្រុមសន្សំប្រាក់ ................................................... ៦៤

**ឧបសម្ព័ន្ធ ២១១** ៖សៀវភៅសន្សំប្រាក់របស់សមាជិក ................................................................... ៦៥

**ឧបសម្ព័ន្ធ ២១២** ៖បញ្ជីចំណូល ចំណាយក្រុមសន្សំប្រាក់...............................................................៦៦

**ឧបសម្ព័ន្ធ ២១៣** ៖សៀវភៅឥណទានក្រុម .....................................................................................៦៧

**ឧបសម្ព័ន្ធ ២១៤** ៖សៀវភៅសន្សំប្រាក់ក្រុម.....................................................................................៦៨

**ឧបសម្ព័ន្ធ ២១៥** ៖តារាងកាលវិភាគខ្ចី-សងប្រាក់ ...................................................................... ៦៩

**ឧបសម្ព័ន្ធ ២១៦** ៖លក្ខន្តិកៈក្រុម................................................................................................... ៧០

**ឧបសម្ព័ន្ធ ២១៧** ៖គំរូបញ្ជីវត្តមាន ...............................................................................................៧៩

**ឧបសម្ព័ន្ធ ២១៨** ៖គំរូរបៀបវារៈប្រជុំ..............................................................................................៨០

**ឧបសម្ព័ន្ធ ២១៩** ៖គំរូកំណត់ត្រាប្រជុំរបស់ក្រុម ........................................................................... ៨១

**ឧបសម្ព័ន្ធ ២២០** ៖ឧទាហរណ៍ផែនការសកម្មភាពគម្រោងចិញ្ចឹមមាន់ .............................................៨៣

**ឧបសម្ព័ន្ធ ២២១** ៖គំរូសន្លឹកឆ្នោតជ្រើសរើសថ្នាក់ដឹកនាំក្រុមកែលម្អជីវភាព.....................................៨៤

## ១. សេចក្តីផ្តើម

នៅក្នុងសមាភាគទី១គឺការអភិវឌ្ឍឃុំសង្កាត់តាមរយៈមូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ ដែលអនុវត្តដោយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ជាភ្នាក់ងារប្រតិបត្តិ និងអនុវត្តគម្រោង ។ ការអភិវឌ្ឍឃុំ សង្កាត់ មានគោលបំណងសំខាន់គឺ៖ ១)កែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ ដើម្បីចូលរួមចំណែកលើកកម្ពស់ផលិតភាពកសិកម្ម ២)អភិវឌ្ឍសមត្ថភាពក្រុមកសិករខ្នាតតូច និងក្រុមផ្សេងទៀត និង ៣)ពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការគ្រប់គ្រង គម្រោង។ ដើម្បីសម្រេចគោលបំណងខាងលើនេះ ចាំបាច់តម្រូវឱ្យមានការសហការគ្នាជាមួយសមាសភាគពីរផ្សេងទៀតដែលអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍវិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (NiDA)។

ប្រជាពលរដ្ឋក្រីក្រនៅតាមជនបទខ្វះខាតនូវមធ្យោបាយគ្រប់បែបយ៉ាងដូចជា កម្លាំងអូសទាញ ដីស្រែ ចំការ ពូជស្រូវ បន្លែ ចំណេះដឹងបច្ចេកទេសកសិកម្ម ព័ត៌មានទីផ្សារកសិកម្ម ប្រភពទុនឥណទាន... ។ល។ ដើម្បីបង្កើតប្រាក់ចំណូលសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេ។ ក្រុមកែលម្អជីវភាព (LIGs) និងក្រុមផ្សេងទៀត គឺជាដំណោះស្រាយមួយក្នុងចំណោមដំណោះស្រាយជាច្រើនចំពោះបញ្ហាខាងលើ។ ហេតុដូចនេះហើយ បានជាក្រុមការងារគម្រោងថ្នាក់ជាតិ បានផ្តួចផ្តើមបង្កើតឡើងនូវគោលការណ៍ណែនាំនេះដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធយកទៅអនុវត្ត។

គោលបំណងនៃគោលការណ៍ណែនាំនេះគឺដើម្បីណែនាំដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការបង្កើតក្រុមកែលម្អជីវភាព។

គោលការណ៍ណែនាំនេះ នឹងពន្យល់ពីដំណើរការនៃការជ្រើសរើសភូមិគោលដៅ ការកំណត់ពីគ្រួសារក្រីក្រ និងការរៀបចំបង្កើតក្រុមកែលម្អជីវភាព។ គោលការណ៍ណែនាំបរិយាយផងដែរ ពីគោលការណ៍សម្រាប់ការពង្រឹងក្រុមកែលម្អជីវភាព តាំងពីការកកើតជារូបរាង ដល់ដំណាក់កាលដែលក្រុមអាចស្វ័យគ្រប់គ្រងបានដោយខ្លួនឯង។

គោលការណ៍បង្កើតក្រុមក៏បានជាប្រយោជន៍ផងដែរ ដល់អ្នកអនុវត្តគម្រោងពិសេសនៅថ្នាក់ឃុំ សង្កាត់ ប្រើប្រាស់ជាមធ្យោបាយក្នុងរៀបចំបង្កើតក្រុមប្រកបដោយភាពត្រឹមត្រូវ តម្លាភាព មានការចូលរួម និងដំណើរប្រព្រឹត្តទៅរបស់វា។ វានឹងជួយដល់អ្នកផ្សព្វផ្សាយកសិកម្ម និងជំនួយការរដ្ឋបាលឃុំ សង្កាត់ ដើម្បីធានាការជ្រើសរើស និងការអនុវត្តប្រព្រឹត្តទៅបានដោយរលូន និងមានតម្លាភាពផងដែរ។ គោលការណ៍ណែនាំនេះ គឺជាឯកសារគោលមួយដែលអាចកែសម្រួលបានដោយផ្អែកលើមេរៀនបទពិសោធន៍ក្នុងកំឡុងពេលនៃការអនុវត្តនីតិវិធីនេះ។

## ២.     ឃុំ សង្កាត់គោលដៅ

គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប មាន ១៩៦ឃុំ សង្កាត់គោលដៅ នៅក្នុងខេត្តចំនួនបួននៅជុំវិញបឹងទន្លេសាប។ ៣២ ឃុំ សង្កាត់ នៅក្នុងខេត្តបន្ទាយមានជ័យ ៥៨ ឃុំ សង្កាត់នៅក្នុងខេត្តសៀមរាប ៤៥ ឃុំ សង្កាត់នៅក្នុងខេត្តកំពង់ធំ និង៦១ ឃុំ សង្កាត់ នៅក្នុងខេត្តកំពង់ចាម ។

### ២.១.   ផែនទីភូមិសាស្ត្រឃុំ សង្កាត់គោលដៅនៃខេត្តទាំងបួន




ផែនទីបង្ហាញឃុំ សង្កាត់ និងក្រុង ស្រុកគោលដៅ ខេត្តសៀមរាប
សាលាខេត្ត
សាលាស្រុក
ព្រំប្រទល់ខេត្ត
ព្រំប្រទល់ស្រុក
ព្រំប្រទល់ឃុំ
ផ្លូវជាតិ
ឃុំគោលដៅឆ្នាំទី១
ឃុំគោលដៅឆ្នាំទី២
ឃុំគោលដៅឆ្នាំទី៣
ឃុំក្រៅគោលដៅ
ទន្លេ បឹង ស្ទឹង ព្រែក


ផែនទីបង្ហាញឃុំ សង្កាត់ និងក្រុង ស្រុកគោលដៅ ក្នុងខេត្តកំពង់ធំ
កំណត់សំគាល់
សាលាខេត្ត
សាលាស្រុក
ផ្លូវជាតិ
ព្រំប្រទល់ខេត្ត
ព្រំប្រទល់ស្រុក
ព្រំប្រទល់ឃុំ
ឃុំគោលដៅឆ្នាំទី១
ឃុំគោលដៅឆ្នាំទី២
ឃុំគោលដៅឆ្នាំទី៣
ឃុំក្រៅគោលដៅ
ទន្លេ បឹង ស្ទឹង ព្រែក
ស្ទោង
ប្រាសាទសំបូរ
កំពង់ស្វាយ
សណ្ដាន់
ស្ទឹងសែន
សន្ទុក
បារាយណ៍


ផែនទីបង្ហាញឃុំ សង្កាត់ និងក្រុង ស្រុកគោលដៅ ក្នុងខេត្តកំពង់ចាម
កំណត់សំគាល់
សាលាខេត្ត
សាលាស្រុក
ផ្លូវ ចាក់កៅស៊ូ
ព្រំប្រទល់ប្រទេស
ព្រំប្រទល់ខេត្ត
ព្រំប្រទល់ស្រុក
ព្រំប្រទល់ឃុំ
ឃុំគោលដៅឆ្នាំទី១
ឃុំគោលដៅឆ្នាំទី២
ឃុំគោលដៅឆ្នាំទី៣
ឃុំក្រៅគោលដៅ
ទន្លេ បឹង ស្ទឹង ព្រែក
ប្រទេសវៀតណាម

## ២.២. ផែនការអនុវត្តសម្រាប់ ១៩៦ ឃុំ សង្កាត់

ដោយផ្អែកតាមស្ថានភាពជាក់ស្តែងរួមទាំងសក្តានុពល និងចំនួន ឬឈ្មោះឃុំ សង្កាត់ មួយចំនួនអាចនឹងមានការផ្លាស់ប្តូររួមបញ្ចូលជាមួយគម្រោងផ្សេងៗ។ ក្រុមការងារគម្រោងនៃលេខាធិការដ្ឋាន គ.ជ.អ.ប នឹងធ្វើការពិនិត្យមើលឡើងវិញពីសុពលភាពនៃឃុំ សង្កាត់ និមួយៗ ហើយការវាយតម្លៃនឹងត្រូវធ្វើឡើងនៅមុនការអនុវត្តក្នុងដំណាក់កាលទីពីរចំនួន៨៨ ឃុំ សង្កាត់ [1]។

តារាងទី១ ៖បង្ហាញពីចំនួនក្រុង ស្រុក និងឃុំ សង្កាត់គោលដៅតាមដំណាក់កាលនីមួយៗ

| ខេត្តគោលដៅ | ចំនួនក្រុង ស្រុកគោលដៅ | | | ចំនួនឃុំ សង្កាត់គោលដៅ | | | |
|---|---|---|---|---|---|---|---|
| | សរុប | លើកទី១ | លើកទី២ | សរុប | លើកទី១ | លើកទី២ | លើកទី៣ |
| បន្ទាយមានជ័យ | ៥ | ៣ | ២ | ៣២ | ៤ | ១៤ | ១៤ |
| សៀមរាប | ៩ | ២ | ៧ | ៥៨ | ២ | ២៦ | ៣០ |
| កំពង់ធំ | ៦ | ៤ | ២ | ៤៥ | ៥ | ២១ | ១៩ |
| កំពង់ចាម | ៨ | ៣ | ៥ | ៦១ | ៥ | ២៧ | ២៩ |
| **សរុប** | **២៨** | **១២** | **១៦** | **១៩៦** | **១៦** | **៨៨** | **៩២** |

[1] សូមមើលឧបសម្ព័ន្ធ០២ ឯកសារនេះបង្ហាញពីកម្រិតភាពក្រីក្រក្នុងឃុំ សង្កាត់ លើកលែងតែស្រុកពីរ (ក្រូចឆ្មារ និងកោះសូទិន)នៃខេត្តកំពង់ចាម ដែលមិនមានទិន្នន័យគ្រប់គ្រាន់។

# ៣. ការជ្រើសរើសភូមិគោលដៅ

## ៣.១. ការប្រជុំលើកទី១

ការជ្រើសរើសភូមិគោលដៅត្រូវមានតម្លាភាព និងមានការចូលរួម ។ មេឃុំ ចៅសង្កាត់តម្រូវឱ្យមានការរៀបចំការប្រជុំក្រុមប្រឹក្សាដែលមានការចូលរួមពីជំនួយការរដ្ឋបាលឃុំ សង្កាត់ មន្ត្រីផ្សព្វផ្សាយកសិកម្ម មេភូមិ (មេភូមិគ្រាន់តែចូលរួមអង្កេតមើលពីដំណើរការ ឬផ្តល់ព័ត៌មានប៉ុណ្ណោះ ការចាត់អាទិភាពភូមិគោលដៅគឺជាការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ជាអ្នកសម្រេច) ជនបង្គោលទទួលបន្ទុកស្ត្រី និងកុមារឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធគម្រោងពីថ្នាក់ខេត្ត ក្រុង ស្រុក ។ មេឃុំ ចៅសង្កាត់ត្រូវពន្យល់ពីលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសដល់អង្គប្រជុំមួយចំនុចម្តងៗ ។ ចំនួនភូមិគោលដៅ ដែលត្រូវជ្រើសរើសគឺស្មើនឹងចំនួនក្រុមកែលម្អជីវភាពដែលត្រូវបង្កើត មានន័យថាភូមិមួយបង្កើតក្រុមមួយ ។ មេឃុំ ចៅសង្កាត់ក៏នឹងបង្ហាញផងដែរ ពីបញ្ជីភូមិអាទិភាពនៅក្នុងចំនុច៣.៣ ដល់អង្គប្រជុំ ។ បញ្ជីនេះគឺជាឯកសារជំនួយស្មារតីមួយដ៏សំខាន់សម្រាប់យកទៅវាយតម្លៃការជ្រើសរើសភូមិក្រីក្រ ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយការសម្រេចចិត្តអាចមិនមែនជាភូមិអាទិភាពតាមបញ្ជីដែលផ្តល់ជូននេះទេ គឺវាអាស្រ័យទាំងស្រុងលើក្រុមប្រឹក្សាឃុំ សង្កាត់ជាអ្នកសម្រេចដោយពិនិត្យលើស្ថានភាពជាក់ស្តែង ។ ឃុំ សង្កាត់ត្រូវបញ្ជូនបញ្ជីឈ្មោះភូមិដែលបានជ្រើសរើសជាភូមិគោលដៅ ដោយភ្ជាប់ជាមួយនូវកំណត់ហេតុប្រជុំស្តីពីដំណើរការជ្រើសរើសភូមិគោលដៅទៅអភិបាលក្រុង ស្រុក ដើម្បីផ្តល់អនុលោមភាព និងចម្លងជូនក្រុមសម្របសម្រួលគម្រោងថ្នាក់ខេត្តជ្រាបជាព័ត៌មាន និងទុកជាឯកសារ ។

## ៣.២. លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសភូមិ

ភូមិគោលដៅនឹងត្រូវបានជ្រើសរើសផ្អែកតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

១. មានសក្តានុពលក្នុងការបង្កើនផលិតកម្មកសិកម្ម (ប្រភពចំណូលចំបងបានមកពីមុខរបរកសិកម្ម) ។

២. ជាភូមិក្រីក្រដោយផ្អែកតាមការវិភាគអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ឬទិន្នន័យឃុំ សង្កាត់ ។

៣. មានការប្តេជ្ញាចិត្តខ្ពស់ពីថ្នាក់ដឹកនាំភូមិក្នុងការធ្វើឱ្យគម្រោងទទួលបានជោគជ័យ ។

៤. ស្ថានភាពភូមិសាស្ត្រល្អសម្រាប់ការអនុវត្តគម្រោង (ងាយចេញចូល និងទាក់ទងបានគ្រប់ពេលគ្រប់រដូវ) ។

៥. មានសាមគ្គីល្អរវាងថ្នាក់ដឹកនាំភូមិ និងមានសុវត្ថិភាព ។

៦. មិនបានទទួលការគាំទ្រពីគម្រោងដទៃទៀតលើសកម្មភាពស្រដៀង ឬដូចគ្នា ។

៧. មានគ្រួសារក្រីក្រយ៉ាងតិចចំនួន១០គ្រួសារក្នុង១ភូមិដែលអាចក្លាយជាសមាជិក LIG ។

### ៣.៣. ការប្រៀបធៀបកម្រិតភាពក្រីក្រក្នុងភូមិនិមួយៗ

យោងតាមរបាយការណ៍បច្ចុប្បន្នភាព ដែលចេញផ្សាយដោយក្រសួងផែនការ ឆ្នាំ២០១១ បានបង្ហាញច្បាស់លាស់ពីកម្រិតនៃភាពក្រីក្រនៅតាមភូមិគោលដៅនិមួយៗ។ ប៉ុន្តែ ចាំបាច់ណាស់ដែលក្រុមប្រឹក្សាឃុំ សង្កាត់ ជំនួយការរដ្ឋបាល និងអ្នកផ្សព្វផ្សាយកសិកម្មត្រូវតែធ្វើការផ្ទៀងផ្ទាត់ឡើងវិញពីអ្វីដែលមាននៅក្នុងរបាយការណ៍ និងពីស្ថានភាពជាក់ស្តែងនៅតាមភូមិនិមួយៗ។ ការផ្ទៀងផ្ទាត់ត្រូវធ្វើឡើងតាមរយៈការលើកយកមួយភូមិម្តងៗមកពិភាក្សាដោយលម្អិតនៅក្នុងអង្គប្រជុំ។ ដោយក្នុងមួយឃុំ សង្កាត់គេអាចធ្វើការជ្រើសរើសភូមិគោលដៅច្រើនទៅតាមចំនួនដែលបានផ្តល់ឱ្យនៅក្នុងឯកសារគម្រោង។ យោងតាមការវិភាគទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ គម្រោងសូមធ្វើការណែនាំថា ភូមិដែលត្រូវជ្រើសរើសមកធ្វើជាភូមិគោលដៅនោះ គឺជាភូមិដែលមានភាគរយនៃភាពក្រីក្រកម្រិតទី១ និងទី២សរុបច្រើនជាងគេ (សូមមើលតារាងខាងក្រោមស្តីពីភូមិអាទិភាពនៃឃុំ សង្កាត់គោលដៅទាំង ១៦ ក្នុងដំណាក់កាលទី១) ហើយចំនួនក្រុមដែលត្រូវបង្កើតនៅក្នុងឆ្នាំដំបូងនេះគឺ ១១៣ក្រុមកែលម្អជីវភាពគឺ ស្មើនឹង ១១៣ភូមិ ដូចនេះគេត្រូវបន្ថែមអាទិភាពពី ២ ទៅ ៣ភូមិថែមទៀត។ ក្នុងឧបសម្ព័ន្ធ២០២ នឹងបង្ហាញលំអិតពីការប្រៀបធៀបកម្រិតនៃភាពក្រីក្រនៅតាមភូមិអាទិភាពចំនួន៣នៃឃុំ សង្កាត់គោលដៅ។

### ៣.៤. ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ

ដើម្បីធ្វើការជ្រើសរើសគ្រួសារក្រីក្រពិតប្រាកដឱ្យចូលរួមនៅក្នុងគម្រោង អ្នកពាក់ព័ន្ធ ពិសេសអ្នកផ្សព្វផ្សាយកសិកម្មត្រូវប្រើប្រាស់ទិន្នន័យទាំងនេះជាមូលដ្ឋានដើម្បីកំណត់ពីភាពក្រីក្ររបស់គ្រួសារនិមួយៗ។ នៅក្នុងដំណាក់កាលដំបូងនេះគម្រោងនឹងអនុវត្តសកម្មភាពរបស់ខ្លួនជាមួយឃុំ សង្កាត់គោលដៅចំនួន ១៦ នៅខេត្តគោលដៅចំនួនបួនតំបន់ទន្លេសាប។ មុននឹងចាប់ផ្តើមនូវការអនុវត្តការកំណត់ពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ អ្នកពាក់ព័ន្ធត្រូវស្វែងយល់ពីអត្ថន័យមួយចំនួនដែលពាក់ព័ន្ធនៅក្នុងបរិបទនេះរួមមានដូចខាងក្រោម៖

**គ្រួសារក្រីក្រកម្រិតទី១៖** គឺជាចំណាត់ថ្នាក់ក្រីក្របំផុត ឬ "ទីទាល់ក្រ"។ ចំណាត់ថ្នាក់នេះ នឹងត្រូវកំណត់សម្រាប់គ្រួសារណា ដែលមានពិន្ទុចាប់ពី៥៩ ទៅ ៦៨ [2] តាមសៀវភៅណែនាំរបស់ក្រសួងផែនការ។

**គ្រួសារក្រីក្រកម្រិតទី២៖** គឺជាចំណាត់ថ្នាក់ក្រីក្របន្ទាប់ពីក្របំផុត ឬ "ក្រ"។ ចំណាត់ថ្នាក់នេះនឹងត្រូវកំណត់សម្រាប់គ្រួសារណាដែលមានពិន្ទុចាប់ពី៤៥ ទៅ ៥៨តាមសៀវភៅណែនាំរបស់ក្រសួងផែនការ។

ចំពោះគ្រួសារក្រៅពីចំណាត់ថ្នាក់ទាំងពីរខាងលើនឹងត្រូវគេចាត់បញ្ចូលជាគ្រួសារមធ្យម ឬធូរធារ។ ទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅក្នុងភូមិមួយចំនួននៅក្នុងឃុំ សង្កាត់ទាំង១៦ នឹងបង្ហាញជូននៅក្នុងឧបសម្ព័ន្ធ ២០៣។ ដោយចំនួនភូមិនៅក្នុងឃុំ សង្កាត់នីមួយៗមានចំនួនច្រើនដែលមិនអាចលើកយកមកបង្ហាញជូនទាំងអស់

[2] ពិន្ទុនេះត្រូវបានគណនាផ្អែកតាមសំណួរដែលបានបង្កើតសម្រាប់ការកំណត់ពីអត្តសញ្ញាណកម្មក្រីក្រនៃក្រសួងផែនការ ហើយពិន្ទុសរុបមានពី0 ដល់ ៦៨ ច្រើនបំផុត ដែលត្រូវបានគេប្រើប្រាស់ដើម្បីដាក់គ្រួសារក្នុងចំណាត់ថ្នាក់ភាពក្រីក្រផ្សេងគ្នា។ ក្រកម្រិតទី១ (ក្រីក្របំផុត) មានពិន្ទុពី៥៩ ដល់ ៦៨ ក្រកម្រិតទី២ (ក្រីក្រ) មានពិន្ទុពី ៤៥ ដល់ ៥៨ និងផ្សេងៗ មានពិន្ទុពី 0 ដល់ ៤៤។

គម្រោងបានធ្វើសំយោគទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់ក្រសួងផែនការ ហើយសម្រេចបង្ហាញជូនតែកម្រិតភាពក្រីក្ររបស់គ្រួសារក្រីក្រនៅភូមិក្រីក្រជាងគេទី១ ទី២ និងទី៣។ តាមរយៈការបង្ហាញនោះវាមានលក្ខណៈងាយស្រួលបំផុតសម្រាប់អ្នកផ្សព្វផ្សាយកសិកម្ម ជំនួយការរដ្ឋបាលឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងការបង្ហាញពីបញ្ជីឈ្មោះក្រុមគ្រួសារគោលដៅ និងក្រុមដទៃទៀត។

**តារាងទី២** ៖បញ្ជីភូមិអាទិភាព៣នៃ ១៦ ឃុំ សង្កាត់គោលដៅក្នុងដំណាក់កាលទី១

| ខេត្ត | ស្រុក | ឃុំ | ភូមិអាទិភាពទី១ | សរុប%ក្រក្រីកម្រិតទី១ និងទី២ | ភូមិអាទិភាពទី២ | សរុប%ក្រក្រីកម្រិតទី១ និងទី២ | ភូមិអាទិភាពទី៣ | សរុប%ក្រក្រីកម្រិតទី១ និងទី២ |
|---|---|---|---|---|---|---|---|---|
| **បន្ទាយមានជ័យ** | ភ្នំស្រុក | ពន្លៃ | ពន្លៃ | ២៤,៩ | ស្វាយស | ២៣,៤ | ស្វាយខ្មៅ | ២១ |
| | ព្រះនេត្យព្រះ | ទឹកជោរ | កណ្តាល | ២៩,៨ | ស្នាច់ | ២៨,៦ | អន្លង់វិល | ២៨,៤ |
| | | បុសស្បូវ | ស្រះខ្ទុំ | ៤១ | ខ្មែរ | ៣៩ | ខ្វាវ | ៣៨,៨ |
| | ថ្មពួក | គោករមៀត | ផ្លូវបំបែក | ៦២,៨ | ត្រពាំងសំរោង | ៥៦,២ | សាមគ្គី | ៥៤,៩ |
| **សៀមរាប** | សូទ្រនិគម | ពពេល | ពពេលកណ្តាល | ៥១,២ | ត្រពាំងប្រីយ៍ | ៤៩,៣ | ត្រពាំងត្រុំ | ៤៨ |
| | វ៉ារិន | វ៉ារិន | នេល | ៦១,៣ | គោកភ្នំ | ៥៦,៦ | គោកស្រុក | ៤៨,២០ |
| **កំពង់ធំ** | ស្ទឹងសែន | អាចារ្យលាក់ | ព្រៃបន្ទិច | ១៩,៧ | ក្រចាប់ | ១៧,៦ | អាចារ្យលាក់ | ១៣,៦ |
| | | ស្រយូវ | រលួស | ៤៧,៦ | ម្នាវ | ៤៣,៨ | ពោធិ៍សែនស្នាយ | ៤៣,៥ |
| | ប្រសាទបល្ល័ង្គ | សាលាវិស័យ | ចំណារ | ៥៦,២ | ក្វាន់ទៀង | ៥៥,៨ | វាលល្អាក់ | ៥៥,៣ |
| | សន្ទុក | ប្រាសាទ | ស្រែតាកោ | ៥៣ | សំពុង | ៣៣,៦ | លាវ | ២៧,៩ |
| | ស្ទោង | ប្រឡាយ | គោករវៀង | ៦១,៧ | ស្រែតាមែន | ៦០,៧ | តាទ្រាល | ៦០,៥ |
| **កំពង់ចាម** | ពញាក្រែក | ក្រែក | ព្រៃទទឹង | ៥០,៧ | កូវ | ៤៥,២ | ស្រែទឹក | ៤០,៤ |
| | | វាលម្លូ | ១០,៨ | ៥៥,២ | កប្បាស | ៣៣,៦ | សុខចំរើន | ៣៣,៦ |
| | បាធាយ | តាំងក្រាំង | តាំងគោក | ៥១,៣ | ពពិត | ៤២,៥ | ត្បូងភ្នំ | ៣៤,៣ |
| | | តាំងក្រសាំង | ជីនាង | ៦១,១ | ចាន់ | ៤៤,៤ | ក្រដាស ក | ៣៦,៥ |

### ៣.៥. ការចាត់អាទិភាពភូមិគោលដៅ

គោលការណ៍ចំណាត់ថ្នាក់តាមបែបចូលរួមសម្រាប់គ្រប់ភូមិនៅក្នុងឃុំ សង្កាត់ត្រូវបានសម្របសម្រួលដោយអ្នកផ្សព្វផ្សាយកសិកម្ម និងជំនួយពីក្រុមគាំទ្រថ្នាក់ក្រុង ស្រុក។ ដំណើរការនីតិវិធីចំណាត់ថ្នាក់មានដូចតទៅ៖

- គ្រប់ភូមិនៅក្នុងឃុំ សង្កាត់ត្រូវបានធ្វើចំណាត់ថ្នាក់តាមលក្ខណៈវិនិច្ឆ័យទាំងប្រាំពីរ
- សម្រាប់ភូមិនីមួយៗការបូកសរុបទាំងប្រាំពីរចំណាត់ថ្នាក់ត្រូវបានគណនាពិន្ទុទៅតាមភូមិនីមួយៗ។ ភូមិដែលទទួលបានពិន្ទុចំណាត់ថ្នាក់តិចជាងគេគឺត្រូវមានអាទិភាព សម្រាប់ជ្រើសរើសជាភូមិគោលដៅ ទៅតាមចំនួនដែលបានកំណត់ ។
- មេឃុំ ចៅសង្កាត់ត្រូវធ្វើការសម្រេចចិត្តទៅលើចំណាត់ថ្នាក់ ដោយមានជំនួយពីក្រុមគាំទ្រថ្នាក់ក្រុង ស្រុក ហើយថ្នាក់ដឹកនាំភូមិជាអ្នកសង្កេតក្នុងដំណើរការនេះ។
- ភូមិទាំងអស់ត្រូវបានចុះបញ្ជីតាមលំដាប់ពិន្ទុចំណាត់ថ្នាក់ដើម្បីផ្តល់អាទិភាពដល់ភូមិទាំងនោះសម្រាប់ការគាំទ្រពីគម្រោង។
- ចំនួនភូមិគោលដៅដែលបានកំណត់ក្នុងឃុំ សង្កាត់ត្រូវបានជ្រើសរើសយកចេញពីការធ្វើចំណាត់ថ្នាក់នេះ។

**តារាងទី៣ ៖ការធ្វើចំណាត់ថ្នាក់តាមបែបចូលរួមសម្រាប់គ្រប់ភូមិនៅក្នុងឃុំ សង្កាត់**

| លក្ខណៈវិនិច្ឆ័យ | ភូមិ-ក | ភូមិ-ខ | ភូមិ-គ | ភូមិ-ឃ | ភូមិ-ង |
|---|---|---|---|---|---|
| មានសក្តានុពលក្នុងការបង្កើនផលិតកម្មកសិកម្ម (ប្រភពចំណូលចំបងបានមកពីមុខរបរកសិកម្ម) | | | | | |
| ជាភូមិក្រីក្រដោយផ្អែកតាមការវិភាគអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ឬទិន្នន័យឃុំ សង្កាត់ | | | | | |
| មានការប្តេជ្ញាចិត្តខ្ពស់ពីថ្នាក់ដឹកនាំភូមិក្នុងការធ្វើឱ្យគម្រោងទទួលបានជោគជ័យ | | | | | |
| ស្ថានភាពភូមិសាស្ត្រល្អសម្រាប់ការអនុវត្តគម្រោង (ងាយចេញចូល និងទាក់ទងបានគ្រប់ពេលគ្រប់រដូវ) | | | | | |
| មានសាមគ្គីល្អរវាងថ្នាក់ដឹកនាំភូមិ និងមានសុវត្ថិភាព | | | | | |
| មិនបានទទួលការគាំទ្រពីគម្រោងដទៃលើសកម្មភាពស្រដៀង ឬដូចគ្នា | | | | | |
| មានគ្រួសារក្រីក្រយ៉ាងតិចចំនួន១០គ្រួសារក្នុង១ភូមិដែលអាចក្លាយជាសមាជិកក្រុមកែលម្អជីវភាព | | | | | |
| សរុប | | | | | |
| ចំណាត់ថ្នាក់ | | | | | |

*កំណត់សំគាល់ ៖ភូមិដែលទទួលបានពិន្ទុសរុបតិចជាងគេត្រូវបានជាប់ចំណាត់ថ្នាក់អាទិភាពសម្រាប់ការជ្រើសរើស*

## ៣.៦. ការអនុម័តលើបញ្ជីឈ្មោះភូមិគោលដៅ

បន្ទាប់ពីចាត់អាទិភាព និងឯកភាពគ្នាលើភូមិគោលដៅដែលបានកំណត់ និងជ្រើសរើសយក មេឃុំ ចៅសង្កាត់ ដោយមានជំនួយពីជំនួយការរដ្ឋបាលឃុំ សង្កាត់ ត្រូវរៀបចំបញ្ជីឈ្មោះភូមិគោលដៅ និងភ្ជាប់កំណត់ហេតុប្រជុំស្តីពីដំណើរការជ្រើសរើសភូមិគោលដៅដាក់ជូនអភិបាលក្រុង ស្រុក ដើម្បីផ្តល់អនុលោមភាព និងចម្លងជូនក្រុមការងារគម្រោងថ្នាក់ខេត្ត ក្រុង ស្រុក ជ្រាបជាព័ត៌មាន និងទុកជាឯកសារ ។

**គំរូ**

**គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប**

Loan: 2599/Grant 0186-CAM (SF)

---

ខេត្ត

ស្រុក

ឃុំ

**បញ្ជីឈ្មោះភូមិគោលដៅ**

| ល.រ | ឈ្មោះភូមិគោលដៅ | ចំនួនប្រជាពលរដ្ឋសរុបក្នុងភូមិ | កំណត់សំគាល់ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |

ធ្វើនៅ...................ថ្ងៃទី............ខែ............ឆ្នាំ២០១២

អ្នករៀបចំ

បានពិនិត្យ និងបញ្ជាក់ថាត្រឹមត្រូវ

គោរពជូនអភិបាលក្រុង ស្រុក

ដើម្បីផ្តល់អនុលោមភាព

មេឃុំ ចៅសង្កាត់ ជំនួយការរដ្ឋបាលឃុំ សង្កាត់

## ៤. ដំណើរការជ្រើសរើសគ្រួសារគោលដៅ

នៅក្នុងដំណើរការនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវយកចិត្តទុកដាក់ខ្ពស់លើផលប្រយោជន៍រួមរបស់សហគមន៍ ការជ្រើសរើសគ្រួសារគោលដៅគឺជាកត្តាដ៏សំខាន់ដែលធ្វើឱ្យការអនុវត្តគម្រោងទទួលបានជោគជ័យ និងមាននិរន្តរភាពនៅក្នុងមូលដ្ឋានរបស់ខ្លួន។ ជំនួយការរដ្ឋបាល និងមន្ត្រីផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់មានតួនាទីជាសំខាន់នៅក្នុងដំណាក់កាលនេះ។ ការជ្រើសរើសនេះ ត្រូវផ្តោតជាសំខាន់គឺៈ គ្រួសារគោលដៅក្រីក្រកម្រិត២ (ID Poor 2) តែក្នុងករណីដែលគ្រួសារក្រីក្រកម្រិត១ (ID Poor 1) មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចលក្ខណៈវិនិច្ឆ័យខាងក្រោម (សូមមើលចំណុច ៤.២) ក៏អាចត្រូវបានជ្រើសរើសផងដែរ ប៉ុន្តែ បើសិនជាក្នុងចំណោមគ្រួសារក្រីក្រកម្រិត២មិនមានអ្នកចេះអក្សរនោះ គ្រួសារមធ្យមនឹងត្រូវបានពិចារណាជាសមាជិកក្រុម និងពិនិត្យតាមលទ្ធភាពជាក់ស្តែងសម្រាប់តំណែងអ្នកដឹកនាំក្នុងក្រុមតាមរយៈការបោះឆ្នោតពីសមាជិកក្រុម។ គ្រួសារដែលបានជ្រើសរើសនឹងបង្កើតបានជាក្រុមកែលម្អជីវភាព (LIGs)។ រូបភាពខាងក្រោមនេះ បង្ហាញពីចំណាត់ថ្នាក់តាមប្រភេទគ្រួសារនៅតាមភូមិគោលដៅដែលរួមមានៈ គ្រួសារក្រីក្របំផុត (ID Poor 1=Poorest H/H) គ្រួរសារក្រីក្រ (ID Poor 2 = Poor H/H) គ្រួសារមធ្យម (Medium H/H) និងគ្រួសារគ្រាន់បើ (Better Off H/H) ។ ត្រង់កន្លែងត្រួតស៊ីគ្នាគឺ បង្ហាញពីគ្រួសារដែលការវាយតម្លៃមិនសូវច្បាស់ ឬកំណត់បានជាក់លាក់ថាតើជាប្រភេទគ្រួសារណាមួយពិតប្រាកដប្រសិនបើមានពីរទៅបីលក្ខណៈវិនិច្ឆ័យនៃចំណាត់ថ្នាក់ទ្រព្យសម្បត្តិលាយឡំគ្នា។




### ៤.១. ការប្រជុំភូមិលើកទី១

ក្រោយពីទទួលបានចំណាត់ថ្នាក់ជាភូមិគោលដៅសម្រាប់អនុវត្តគម្រោងតាមរយៈការជ្រើសរើសដូចមានចែងនៅក្នុងចំនុច៣ខាងលើ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំការប្រជុំជាដំបូងនៅភូមិនិមួយៗ ដើម្បីពន្យល់ពីគោលបំណង និងសមាសភាគរបស់គម្រោង។ ការប្រជុំនេះ ដឹកនាំដោយមេឃុំ ចៅសង្កាត់ និងមានការចូលរួមផងដែរ ពីក្រុមសម្របសម្រួលគម្រោងថ្នាក់ក្រុង ស្រុក ខេត្ត (PFT/DFT) ក្រុមគាំទ្រក្រុង ស្រុក (DFT) អ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់ (CEW) ជំនួយការរដ្ឋបាលឃុំ សង្កាត់ (CAA) មេភូមិ ចាស់ព្រឹទ្ធាចារ្យ ឬព្រះសង្ឃក្នុងភូមិ និងអ្នកពាក់ព័ន្ធដទៃទៀត។ គោលបំណងនៃការប្រជុំគឺដើម្បីធ្វើការបង្ហាញពីគម្រោងដល់អ្នកភូមិ និង

ការចូលរួមរបស់ពួកគាត់ និងអនុវត្តធ្វើចំណាត់ថ្នាក់ទ្រព្យសម្បត្តិដើម្បីបង្កើតបញ្ជីឈ្មោះសមាជិកក្រុមកែលម្អជីវភាពបណ្តោះអាសន្នមួយ ។

យ៉ាងហោចណាស់មុនពេលប្រជុំ៥ថ្ងៃ មេឃុំ ចៅសង្កាត់គួរពិភាក្សាជាមួយប្រធានភូមិ អ្នកផ្សព្វផ្សាយកសិកម្ម និងក្រុមសម្របសម្រួល និងគាំទ្រគម្រោងថ្នាក់ក្រុង ស្រុក (DFT&DST) អំពីៈ

- ✓ របៀបវារៈសម្រាប់ប្រជុំ
- ✓ អ្នកសម្របសម្រួលសម្រាប់សកម្មភាពនីមួយៗ
- ✓ ការអញ្ជើញគ្រួសារទាំងអស់ក្នុងភូមិដើម្បីប្រាកដថាពួកគាត់បានចូលរួមប្រជុំតាមលទ្ធភាពដែលអាចធ្វើទៅបាន
- ✓ រៀបចំបញ្ជីសារពើភ័ណ្ឌគ្រួសារក្នុងភូមិឱ្យបានចប់សព្វគ្រប់
- ✓ ទីកន្លែងប្រជុំ
- ✓ ភស្តុភាររួមទាំង អាហារសម្រន់ និងសម្ភារផ្សេងៗ
- ✓ តម្រូវការសាច់ប្រាក់សម្រាប់ដឹកនាំការប្រជុំ

**របៀបវារៈសម្រាប់ការប្រជុំនេះអាចមានដូចខាងក្រោមៈ**

ក. ការណែនាំឱ្យស្គាល់អំពីគម្រោងដោយរួមបញ្ចូលសមាសភាគ និងសកម្មភាពរបស់គម្រោង

ខ. តួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ ជំនួយការរដ្ឋបាលឃុំ សង្កាត់ មន្ត្រីផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់ ក្រុមសម្របសម្រួល និងក្រុមគាំទ្រថ្នាក់ក្រុង ស្រុក ខេត្ត និងអ្នកផ្តល់សេវាកម្ម ។

គ. ផលប្រយោជន៍ និងការទទួលខុសត្រូវរបស់គ្រួសារកសិករ

ឃ. ពន្យល់ពីដំណើរការនៃការជ្រើសរើសគ្រួសារគោលដៅ

ង. ការផ្សព្វផ្សាយពីបញ្ជីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

ច. ការផ្ទៀងផ្ទាត់បញ្ជីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

ជ. ការបង្ហាញពីលក្ខណៈនៃគ្រួសារក្រីក្រដែលត្រូវជ្រើសរើស

ឈ. ការបង្ហាញបញ្ជីគ្រួសារតាមអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

### ៤.២. ការជ្រើសរើសគ្រួសារគោលដៅ

មុននឹងបញ្ចប់ការប្រជុំខាងលើនេះមេឃុំ ចៅសង្កាត់ត្រូវប្រកាសរកគ្រួសារណាដែលមិនមានបំណងចូលរួមនៅក្នុងសកម្មភាពគម្រោងហើយត្រូវកាត់ឈ្មោះចេញពីគ្រួសារដែលត្រូវជ្រើសរើស។ បន្ទាប់មកមេឃុំ ចៅសង្កាត់ត្រូវប្រកាសរំសាយការប្រជុំ ហើយសន្យាជាមួយសមាជិកអង្គប្រជុំទាំងអស់ថាឈ្មោះគ្រួសារដែលត្រូវជ្រើសរើសនឹងបិទផ្សាយនៅសាលាឃុំ សង្កាត់ ក្ដារព័ត៌មានតាមភូមិ និងតាមទីប្រជុំជននៅក្នុងឃុំ សង្កាត់ បន្ទាប់ពីការសម្រេចចិត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ នៅថ្ងៃដដែល ក្រុមប្រឹក្សាឃុំ សង្កាត់រួមជាមួយនឹងជំនួយការរដ្ឋបាល មន្ត្រីផ្សព្វផ្សាយកសិកម្ម ក្រុមសម្របសម្រួលថ្នាក់ក្រុងស្រុក ខេត្ត ក្រុមគាំទ្រក្រុង ស្រុក ទីប្រឹក្សាគម្រោង (បើអាច) និងចាស់ព្រឹទ្ធាចារ្យ ឬព្រះសង្ឃ ក្នុងភូមិបើកការពិភាក្សាគ្នាដើម្បីកំណត់ពីគ្រួសារដែលត្រូវជ្រើសរើស។ ជាការសំខាន់ណាស់ដែលតម្រូវឱ្យមានការចូលរួមពីចាស់ៗ ឬព្រះសង្ឃ ពីព្រោះថាអ្នកទាំងនេះអាចជួយវាយតម្លៃពីចរិតលក្ខណៈ និងឥរិយាបទរបស់គ្រួសារដែលនឹងត្រូវជ្រើសរើស។

**លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសគ្រួសារគោលដៅមានដូចខាងក្រោម៖**

- គ្រួសារក្រីក្រដែលឧស្សាហ៍ព្យាយាម និងមានឆន្ទៈចូលរួម
- គ្រួសារដែលមានទីលំនៅជាអចិន្ត្រៃយ៍នៅក្នុងភូមិគោលដៅ
- គ្រួសារដែលមានដីបង្កបង្កើនផល ឬមានដីខ្លះនៅជុំវិញផ្ទះសម្រាប់ ដាំដំណាំ ឬចិញ្ចឹមសត្វបាន ឬមានមុខរបរក្រៅកសិដ្ឋាន ដែលទាក់ទងការកែច្នៃផលិតផលកសិកម្មផ្សេងៗ
- គ្រួសារដែលមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ដាំដំណាំ ចិញ្ចឹមសត្វ ឬរកប្រាក់ចំណូលពីរបរក្រៅកសិដ្ឋានដែលទាក់ទងកសិកម្ម។ គ្រួសារប្រភេទនេះទទួលបានអាទិភាព ប្រសិនបើមានសមាជិកណាម្នាក់៖ ជាស្ត្រីមេម៉ាយ ស្ត្រីមានប្ដីជាជនពិកា ឬជាជនជាតិដើមភាគតិច ឬមានបន្ទុកកូនក្មេងច្រើន
- គ្រួសារដែលស្មោះត្រង់ គោរពច្បាប់ មានការទទួលខុសត្រូវ និងមានទំនាក់ទំនងល្អជាមួយអ្នកជិតខាង ឬអ្នកក្នុងភូមិជាមួយ
- គ្រួសារមានការព្យាយាមសន្សំប្រាក់ជាទៀងទាត់ ដោយយោងទៅតាមការសម្រេចចិត្តរបស់ក្រុម

**តារាងទី៤ ៖**លក្ខណៈវិនិច្ឆ័យនៃចំណាត់ថ្នាក់ទ្រព្យសម្បត្តិ

| សន្ទស្សន៍ | ក្រីក្របំផុត | ក្រីក្រ | មធ្យម | គ្រាន់បើ |
|---|---|---|---|---|
| ផ្ទះ | ដំបូលស្បូវមាន ជញ្ជាំងស្លឹករហែក | ដំបូលស្បូវ ឬស័ង្កសី មានជញ្ជាំងឬស្សី ឈើប្រហោងៗ | ដំបូលក្បឿង មាន ជញ្ជាំងឈើប្រហោង ៗ | ដំបូលក្បឿង ជញ្ជាំងឥដ្ឋ |
| ដី | តិចជាង ០,២ ហ.ត | តិចជាង ០,៥ ហ.ត | ០,៥-១,៥ ហ.ត | ច្រើនជាង ១,៥ ហ.ត |
| សត្វពាហនៈ | គ្មានគោ ក្របី | មាន ១-២ គោ | មាន ២-៤ គោ | គោច្រើនជាង ៤ |
| មធ្យោបាយធ្វើដំណើរ | គ្មានកង់ ម៉ូតូ | មាន ១-២ កង់ | មានកង់ ម៉ូតូច្រើន | មានកង់ ម៉ូតូទំនើប |
| សម្ភារកសិកម្ម | នង្គ័ល រនាស រទេះ | មាននង្គ័ល រនាស់ រទេះ និងឧបករណ៍ តូចៗ | មានគោយន្ត ឬ ត្រាក់ទ័រ និងមានឧបករណ៍ ផ្សេងៗ | មានគោយន្ត ត្រាក់ទ័រប្រើ ឬជួល |
| រយៈពេលខ្វះស្បៀង | ៨-១២ ខែ | ៣-៧ ខែ | ០-២ ខែ | ០ |
| មុខរបរ | កសិករ ឬលក់កំលាំង ពលកម្ម | កសិករ ជំនួញតូចតាច កម្មករ មន្ត្រីរាជការ | កសិករ ឬជំនួយមធ្យម ធំ | |
| ចំនួនសមាជិកគ្រួសារដែល មិនអាចធ្វើការរកម្រេបាន | ច្រើនជាង ៥០% | តិចជាងឬស្មើ ៥០% តែ ច្រើនជាង២៥% | តិចជាង ឬស្មើ២៥% តែច្រើនជាង១០% | តិចជាង១០% |
| ការអប់រំ | ក្មេងច្រើនជាង៣នាក់(៦-១១ ឆ្នាំ)មិនបានចូលសាលា | ក្មេង៣នាក់(៦-១១ ឆ្នាំ) មិនបានចូលសាលា | ក្មេង៣នាក់(៦-១១ ឆ្នាំ)មិនបានចូលសាលា | គ្មាន |

*សំគាល់ ៖ ប្រសិនបើលក្ខណៈវិនិច្ឆ័យពីរទៅបីនៃក្រីក្របំផុត (Poor 1) និងក្រីក្រ (Poor2) លាយឡំគ្នា គ្រួសារនោះនឹងត្រូវបានជ្រើសរើស*

នីតិវិធី**ចំណាត់ថ្នាក់ទ្រព្យសម្បត្តិ**គឺត្រូវបានប្រើនៅពេលដែលមិនមានការធ្វើបច្ចុប្បន្នភាព ឬគ្មានបញ្ជីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ID Poor (សូមមើលឧបសម្ព័ន្ធ ខ០៤)។ ការអនុវត្តបែបនេះ មានបំណងដើម្បីឱ្យដឹងពិតប្រាកដពីស្ថានភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងកម្រិតផ្សេងៗគ្នា ដើម្បីគម្រោងធ្វើអន្តរាគមន៍កែលម្អកម្រិតជីវភាពរស់នៅរបស់ពួកគាត់ប្រកបដោយប្រសិទ្ធិភាព។ការអនុវត្តធ្វើចំណាត់ថ្នាក់ទ្រព្យសម្បត្តិគួរតែសម្របសម្រួលដោយអ្នកផ្សព្វផ្សាយកសិកម្ម ដោយមានជំនួយពីក្រុមសម្របសម្រួល និងក្រុមគាំទ្រក្រុង ស្រុក។ អ្នកផ្សព្វផ្សាយកសិកម្មនឹងចាប់ផ្តើមដំណើរការដោយប្រើបញ្ជីឈ្មោះគ្រួសារទូទៅនៅក្នុងភូមិនីមួយៗ និងធ្វើការបែងចែកប្រភេទគ្រួសារតាមកម្រិតជីវភាពរស់នៅ និងលក្ខណៈវិនិច្ឆ័យទៅតាមថ្នាក់នីមួយៗ។ អ្នកផ្សព្វផ្សាយកសិកម្ម

អាចលើកឧទាហរណ៍ជាបន្តបន្ទាប់ដើម្បីលើកទឹកចិត្តឱ្យមានការពិភាក្សាតាមបែបចូលរួមដើម្បីព្រមទទួល ឬបន្ថែមលក្ខណៈវិនិច្ឆ័យបន្ថែមទៀតនៃការចាត់ថ្នាក់នីមួយៗ។

### ៤.៣. ការអង្កេតតាមគ្រួសារ

ការអង្កេតតាមគ្រួសារត្រូវតែធ្វើឡើងដោយអ្នកផ្សព្វផ្សាយកសិកម្ម ជំនួយការរដ្ឋបាលឃុំ សង្កាត់ ដោយមានជំនួយពីក្រុមសម្របសម្រួល និងគាំទ្រគម្រោងថ្នាក់ក្រុង ស្រុក (DFT/DST)។សកម្មភាពនេះ ចាប់អនុវត្តដោយមិនចាំបាច់មានវត្តមានក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេភូមិឡើយ។ ការអង្កេតនេះត្រូវធ្វើចំពោះក្រុមណាដែលទើបជ្រើសរើសក្នុងបញ្ជីបណ្តោះអាសន្ន ហើយមេគ្រួសារត្រូវបានសំភាសន៍ដើម្បីពិភាក្សាពីឆន្ទៈចូលរួមក្នុងក្រុម។ ចំនុចសំខាន់ៗ ដែលត្រូវអនុវត្តនៅពេលចុះធ្វើការអង្កេតនោះ (សូមមើលឧបសម្ព័ន្ធ២០៥)។ ជាលទ្ធផលនៃការអង្កេតតាមគ្រួសារ បើពិនិត្យឃើញថា មានគ្រួសារដែលមិនសមស្របទៅនឹងលក្ខណៈវិនិច្ឆ័យរបស់គម្រោងទេ នោះត្រូវធ្វើការជំនួសដោយក្រុមសមាជិកគ្រួសារថ្មី ដោយមានការពិគ្រោះយោបល់ជាមួយមេភូមិ និងធ្វើការអង្កេតបន្ថែមទៅលើគ្រួសារជំនួសថ្មីនោះ។

### ៤.៤. ការប្រជុំភូមិលើកទី២

បន្ទាប់ពីបញ្ចប់ដំណើរការអង្កេតតាមគ្រួសារ អ្នកផ្សព្វផ្សាយកសិកម្មដោយមានជំនួយពីក្រុមសម្របសម្រួល និងគាំទ្រគម្រោងថ្នាក់ក្រុង ស្រុក នឹងរៀបចំបញ្ជីចុងក្រោយនៃសមាជិកក្រុមកែលម្អជីវភាពដែលមានសក្តានុពលទាំងអស់ចេញពីគ្រួសារដែលបានធ្វើការអង្កេត។ ប្រធានភូមិត្រូវរៀបចំប្រជុំភូមិដើម្បីបង្ហាញបញ្ជីឈ្មោះគ្រួសារចុងក្រោយដែលបានជ្រើសរើស អ្នកផ្សព្វផ្សាយកសិកម្ម ក្រុមការងារគម្រោងថ្នាក់ក្រុង ស្រុក នឹងពន្យល់ពីលក្ខខ័ណ្ឌផ្សេងៗ សម្រាប់សមាជិកភាពនៃក្រុមកែលម្អជីវភាពដូចមានក្នុងលក្ខណៈវិនិច្ឆ័យខាងលើ។

គ្រួសារដែលបានកំណត់ថាជាសមាជិកមានសក្តានុពលនៃក្រុមកែលម្អជីវភាពនឹងត្រូវស្នើឱ្យចុះហត្ថលេខាពីការប្តេជ្ញាចិត្តតាមលក្ខខ័ណ្ឌទាំងនេះ ឬលក្ខណៈវិនិច្ឆ័យនៃសមាជិកក្រុមកែលម្អជីវភាព។ បន្ទាប់ពីការប្រជុំលើកទី២ មេឃុំ ចៅសង្កាត់ត្រូវរៀបចំបញ្ជីឈ្មោះចុងក្រោយនេះ ដើម្បីដាក់ឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ប្រជុំអនុម័ត។

### ៤.៥. ការចុះឈ្មោះចូលជាសមាជិកក្រុម

គ្រួសារដែលមានឈ្មោះនៅក្នុងបញ្ជីដែលបានអនុម័តដោយក្រុមប្រឹក្សាឃុំ សង្កាត់នឹងត្រូវអញ្ជើញឱ្យចុះឈ្មោះដើម្បីឱ្យក្លាយខ្លួនទៅជាសមាជិកពេញសិទ្ធិក្នុងក្រុម។ ការចុះឈ្មោះនេះចាត់ទុកជាផ្លូវការលុះណាតែមានការចុះហត្ថលេខា ឬស្នាមមេដៃមេគ្រួសារ(ប្តី និងប្រពន្ធ)ជាមួយគ្នា។ បើក្នុងករណីមានភាគីណាមួយមិនយល់ព្រមក្នុងចំណោមប្តីប្រពន្ធ គ្រួសារនោះមិនអាចក្លាយជាសមាជិកក្រុមកែលម្អជីវភាពរបស់គម្រោងបានទេ។ គំរូពាក្យសុំចូលជាសមាជិកមាននៅក្នុងឧបសម្ព័ន្ធ ២០៦ នៃគោលការណ៍នេះ។

### ៤.៦. ការបង្កើតក្រុមកែលម្អជីវភាព

អ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់ ដោយមានជំនួយពីក្រុមសម្របសម្រួល និងគាំទ្រគម្រោងថ្នាក់ក្រុងស្រុកនឹងសម្របសម្រួលការប្រជុំលើកទី១របស់សមាជិកក្រុមកែលម្អជីវភាព ក្នុងការជ្រើសរើសថ្នាក់ដឹកនាំក្រុម (ប្រធានក្រុម អនុប្រធានក្រុម និងហិរញ្ញិក) ***យ៉ាងហោចណាស់ត្រូវមានស្ត្រីម្នាក់ក្នុងចំណោមអ្នកទាំងបី***។ អ្នកផ្សព្វផ្សាយកសិកម្មនឹងសម្របសម្រួលក្នុងការកំណត់ឱ្យបានច្រើនជាងបីនាក់ ទាំងបុរស និងស្ត្រី ដែលមានឆន្ទៈឈរឈ្មោះសម្រាប់ការបោះឆ្នោត ហើយការជ្រើសរើសអ្នកដឹកនាំក្រុមតម្រូវឱ្យមានការចូលរួមពីគ្រប់សមាជិកនៃក្រុមកែលម្អជីវភាពតាមរយៈការបោះឆ្នោត ។ អ្នកសម្របសម្រួលត្រូវច្បាស់ថា យ៉ាងហោចណាស់មានស្ត្រីមួយរូប ក្នុងចំណោមអ្នកដឹកនាំក្រុមទាំងបីរូប ហើយអ្នកសម្របសម្រួលគួរតែចំណាយពេល១៥នាទី ដើម្បីពន្យល់ពីទស្សនទានសមធមិយេនឌ័រដល់គ្រប់សមាជិកក្រុមកែលម្អជីវភាពទាំងអស់ មុននឹងចាប់ផ្តើមការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំក្រុម ។

ការបោះឆ្នោតនឹងត្រូវអនុវត្តជាពីរដំណាក់កាល៖

- ការបោះឆ្នោតលើកទី១ ជ្រើសរើសហិរញ្ញិក
- ការបោះឆ្នោតលើកទី២ ជ្រើសរើសប្រធាន និងអនុប្រធានក្រុម ហើយក្នុងដំណាក់កាលបោះឆ្នោតនីមួយៗត្រូវមានបេក្ខភាពឈរឈ្មោះយ៉ាងហោចណាស់បីរូប ។

នៅពេលកំណត់បេក្ខភាព អ្នកសម្របសម្រួលត្រូវជម្រាបជូនអង្គប្រជុំពីលក្ខណៈសម្បត្តិ និងការទទួលខុសត្រូវរបស់អ្នកដឹកនាំក្រុម កិច្ចការទាំងនេះរួមមានដូចខាងក្រោម៖

- ដឹកនាំ និងគ្រប់គ្រងគ្រប់សកម្មភាពរបស់ក្រុម
- សម្របសម្រួលការអនុវត្តផែនការរបស់ក្រុម
- បង្កើតទំនាក់ទំនងជាអ្នកដ៏ទៃដើម្បីពង្រឹងគុណភាពនៃភាពជាអ្នកដឹកនាំ
- សម្របសម្រួល និងដោះស្រាយរាល់បញ្ហាដោយមានគណនេយ្យភាពខ្ពស់
- ដឹកនាំការប្រជុំក្រុមជាទៀងទាត់
- ធ្វើជាគំរូដល់សមាជិកក្រុមនៅពេលដែលទទួលខុសត្រូវសកម្មភាពគម្រោង។ សកម្មភាពបន្ថែមគឺត្រូវគ្រប់គ្រងក្រុមសន្សំ ការចំណាយ ចំណូល និងប្រាកដថាគ្រប់សមាជិកក្រុមបានសន្សំជាទៀងទាត់ និងសងប្រាក់កម្ចីរបស់ពួកគាត់ទាន់ពេល ។

នៅក្នុងសន្លឹកឆ្នោត បេក្ខភាពពីររូបនៃបុរសមួយរូប និងស្ត្រីមួយរូប គួរត្រូវបានបោះដោយសមាជិកក្រុមក្នុងពេលតែមួយដើម្បីធានាបានសមភាពយេនឌ័រ (ឧបសម្ព័ន្ធ២១ ៖មានគំរូសន្លឹកឆ្នោត)។ អ្នកផ្សព្វផ្សាយកសិកម្មត្រូវប្រកាសបញ្ជីឈ្មោះបេក្ខជនជាប់ឆ្នោតទាំងអស់ក្រោយ ពីការបោះឆ្នោតតាមក្រុម នីមួយៗ ហើយធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ។

សមភាពយេនឌ័ ក្នុងការគ្រប់គ្រងក្រុមកែលម្អជីវភាពនឹងត្រូវបានលើកតម្កើងតាមរយៈការបោះឆ្នោត។ នៅក្នុងសន្លឹកឆ្នោតមានពីរកូឡោន មួយសម្រាប់បុរស មួយសម្រាប់ស្ត្រី។ នេះមានន័យថា សមាជិកក្រុមនីមួយៗ អាចបោះឱ្យមនុស្សពីរនាក់ បុរស០១រូប និងស្ត្រី០១រូប ក្នុងពេលតែមួយសម្រាប់តំណែងប្រធាន និងអនុប្រធានក្រុម។

បេក្ខភាពបុរស ឬស្ត្រីដែលទទួលចំនួនឆ្នោតច្រើនជាងគេ នោះនឹងក្លាយជាប្រធានក្រុម និងអ្នកដែលទទួលបានចំនួនឆ្នោតច្រើនបន្ទាប់នឹងក្លាយជាអនុប្រធាន។ នៅពេលដែលបុរសជាប្រធានក្រុម ស្ត្រីនឹងក្លាយជាអនុប្រធានក្រុមដោយស្វ័យប្រវត្តិ បើទោះបី ជាគាត់ទទួលបានចំនួនឆ្នោតតិចជាងបេក្ខភាពទី២ខាងបុរសក៏ដោយ។

ក្នុងករណីចំនួនបោះឱ្យបុរស និងស្ត្រីស្មើគ្នានោះ ការបោះឆ្នោតឡើងវិញនឹងត្រូវធ្វើទៅលើបេក្ខភាពទាំងពីររូបនេះ តាមរយៈការសួរឱ្យសមាជិកលើកដៃ ថាតើអ្នកណាគួរធ្វើប្រធាន ហើយអ្នកណាគួរធ្វើជាអនុប្រធាន ។

### ៤.៧. ការបង្កើតក្រុមមានចំណាប់អារម្មណ៍ដូចគ្នា (ក្រុមតូច)

សមាជិកក្រុមកែលម្អជីវភាពនិមួយៗនឹងមានសមាជិកពី ១០ ទៅ ២៥នាក់ បានកំណត់សកម្មភាពកែលម្អជីវភាពជាក់លាក់ដែលនឹងមានសិទ្ធិទទួលបានការគាំទ្រពីមូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់។ ពួកគាត់អាចចាប់ផ្តើមការបង្កើតក្រុមមានចំណាប់អារម្មណ៍ដូចគ្នាមួយដែលមានសមាជិកយ៉ាងហោចណាស់៤ នាក់ នៅក្នុងក្រុមកែលម្អជីវភាព។

វារិតតែប្រសើរ បើគ្រួសារក្រុមដែលមានចំណាប់អារម្មណ៍ដូចគ្នា រស់នៅក្បែរគ្នា។ **ឧទាហរណ៍** មីងសុំ មីងសយ ពូសុខ ពូសុន និងពូស៊ុយមានចំណង់ចំណូលចិត្តចិញ្ចឹមមាន់ដូចគ្នា ហើយពួកគេមានការរាប់អានគ្នាល្អកន្លងមក។ ភារកិច្ចរបស់ពួកគាត់គឺជួយគ្នាទៅវិញទៅមក ហើយសមាជិកក្រុមតូចត្រូវមានគណនេយ្យភាពចំពោះក្រុមកែលម្អជីវភាពទៅលើប្រាក់កម្ចីណាមួយ បើសមាជិកណាម្នាក់ខកខានមិនបានសងត្រឡប់មកក្រុមធំវិញនូវប្រាក់ ឬអ្វីៗដែលខ្ចីពីក្រុម សមាជិកផ្សេងទៀតនៃក្រុមតូចនេះនឹងត្រូវសងជំនួសសមាជិកនោះ។

ការបង្កើតក្រុមមានចំណាប់អារម្មណ៍ដូចគ្នានឹងសម្របសម្រួលដោយអ្នកផ្សព្វផ្សាយកសិកម្ម ដោយមានការគាំទ្រពីក្រុមសម្របសម្រួល និងក្រុមគាំទ្រក្រុង ស្រុក។ ក្រុមមានចំណាប់អារម្មណ៍ដូចគ្នា តម្រូវឱ្យមានតែងតាំងប្រធានក្រុមមួយរូបសម្រាប់ទាក់ទងជាមួយអ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់ ក្រុមសម្របសម្រួលក្រុង ស្រុក ក្រុមគាំទ្រក្រុង ស្រុក និងអ្នកផ្តល់សេវា ដើម្បីសម្របសម្រួលការគាំទ្ររបស់ពួកគេ។ ប្រសិនបើ គ្រប់សមាជិកក្រុមកែលម្អជីវភាពគួរបង្កើតជាក្រុមមានចំណាប់អារម្មណ៍តែមួយ នោះនឹងមិនតម្រូវឱ្យមានប្រធានដឹកនាំក្រុមទៀតឡើយ។

### ៤.៨. ការប្រកាសទទួលស្គាល់ក្រុមកែលម្អជីវភាព

ក្រោយពីគ្រប់ក្រុមកែលម្អជីវភាពបានបង្កើត អ្នកផ្សព្វផ្សាយកសិកម្ម ជំនួយការរដ្ឋបាលឃុំ សង្កាត់ ត្រូវរៀបចំធ្វើរបាយការណ៍ដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីចេញសេចក្តីសម្រេចទទួលស្គាល់ក្រុមទាំងនោះជាផ្លូវការ (រចនាសម្ព័ន្ធក្រុមមាននៅក្នុងចំនុចទី៥.៦ ខាងក្រោម)។

### ៤.៩. ចំនួនក្រុមកែលម្អជីវភាពនៅក្នុងឃុំ សង្កាត់គោលដៅដំណាក់កាលទី១

នៅក្នុងឆ្នាំទី១របស់ខ្លួន គម្រោងមានផែនការបង្កើតឱ្យបាន ១១៣ក្រុមកែលំអជីវភាព (LIGs) នៅក្នុងឃុំ សង្កាត់គោលដៅទាំង១៦ នៃខេត្តទាំងបួន។

**តារាងទី៥ ៖ចំនួនក្រុង ស្រុក ឃុំ សង្កាត់ និងក្រុមកែលម្អជីវភាពនៅក្នុងឃុំ សង្កាត់គោលដៅដំណាក់កាលទី១**

| ល.រ | ឈ្មោះខេត្ត | ចំនួនក្រុង ស្រុក | ចំនួនឃុំ សង្កាត់ | ចំនួនក្រុម LIGs |
|---|---|---|---|---|
| ១ | កំពង់ចាម | ៣ | ៥ | ៣៥ |
| ២ | កំពង់ធំ | ៤ | ៥ | ៣៣ |
| ៣ | សៀមរាប | ២ | ២ | ១៤ |
| ៤ | បន្ទាយមានជ័យ | ៣ | ៤ | ៣១ |
| សរុប | | **១២** | **១៦** | **១១៣** |

# ៥. ការគ្រប់គ្រងក្រុមកែលម្អជីវភាព

## ៥.១. អ្នកដឹកនាំក្រុម

វាជាការចាំបាច់ដែលត្រូវមានសមាសភាពគ្រប់គ្រងមួយដើម្បីរួមចំណែកដឹកនាំក្រុម និងធ្វើឱ្យដំណើរការប្រព្រឹត្តទៅរបស់ក្រុមប្រកបដោយភាពរលូន និងនិរន្តរភាព។

## ៥.២. សមាសភាពអ្នកដឹកនាំក្រុម

- **ប្រធានក្រុម** ៖ជាមនុស្សសំខាន់នៅក្នុងក្រុមដើម្បីធានាឱ្យក្រុមដំណើរការដោយរលូន និងមាននិរន្តរភាព។
- **អនុប្រធានក្រុម** ៖ជាអ្នកទទួលខុសត្រូវបន្ទាប់ពីប្រធានក្រុម និងដឹកនាំក្រុមនៅពេលដែលប្រធានក្រុមអវត្តមាន។
- **ហិរញ្ញិក** ៖ជាមនុស្សសំខាន់ក្នុងការគ្រប់គ្រងនូវរាល់ការចំណាយ ចំណូលរបស់ក្រុមរួមទាំងរបាយការណ៍បូកសរុបរបស់ក្រុមផងដែរ។

## ៥.៣. តួនាទី និងការទទួលខុសត្រូវ និងលក្ខណៈសម្បត្តិរបស់អ្នកដឹកនាំក្រុម

### ៥.៣.១ តួនាទីប្រធានក្រុម

ប្រធានក្រុមទទួលខុសត្រូវរួមក្នុងការគ្រប់គ្រងក្រុមកែលម្អជីវភាពដើម្បីប្រាកដថាមុខងាររបស់ក្រុមមានតម្លាភាព គណនេយ្យភាព និងឆ្លុះបញ្ចាំងសមភាព និងសមធមិយេនឌ័រ។ ការទទួលខុសត្រូវសំខាន់របស់ប្រធានក្រុមមានដូចខាងក្រោម៖

- ទទួលខុសត្រូវ និងគ្រប់គ្រងក្រុមរួម ដោយធានាអោយមានតម្លាភាព គណនេយ្យភាព និងសមធមិ និងសមភាពយេនឌ័រក្នុងការគ្រប់គ្រង
- លើកទឹកចិត្តស្ត្រីក្នុងការសម្រេចចិត្ត និងអនុវត្ត LIG
- ជាអ្នកសម្របសម្រួលដឹកនាំធ្វើផែនការក្រុម រៀបចំកិច្ចប្រជុំ និងវគ្គបណ្តុះបណ្តាល
- ទំនាក់ទំនង និងស្វែងរកប្រភពទុនពីស្ថាប័ន សប្បុរសជន និងអង្គការនានា
- ត្រួតពិនិត្យ តាមដានសកម្មភាពក្នុងក្រុមដែលបាននឹងកំពុងអនុវត្តដោយមានការទទួលខុសត្រូវយេនឌ័រ ធានាថាបញ្ហាយេនឌ័រត្រូវបានបញ្ចូលទៅក្នុងផែនការ LIG
- ចុះហត្ថលេខាលើសំណើកិច្ចសន្យាខ្ចីសង
- ចូលរួមប្រមូលទុនក្រុម (ស្រូវពូជ និងសម្របសម្រួលកម្មវិធីសន្សំប្រាក់ សន្សំស្រូវក្នុងក្រុម)
- ទទួលខុសត្រូវក្នុងការគ្រប់គ្រងសាច់ប្រាក់
- ទទួលខុសត្រូវក្នុងការផ្ញើ និងដកប្រាក់ពីធនាគារ
- ផ្សព្វផ្សាយបច្ចេកទេសដល់សមាជិករបស់ក្រុម និងបន្តអនុវត្តសកម្មភាពដែលគម្រោងផ្តល់ឱ្យ

- o អនុម័តបទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈក្រុម
- o ត្រូវធានាថារាល់បទបញ្ញត្តិទាំងឡាយត្រូវបានគោរពដោយស្មើភាពគ្នា
- o តួនាទីជាតំណាងឱ្យសមាជិកក្រុមទាំងមូល
- o ត្រូវមានពេលវេលាគ្រប់គ្រាន់សម្រាប់ក្រុម
- o សម្របសម្រួលការអនុវត្តផែនការសកម្មភាពរបស់ក្រុម
- o បង្កើតទំនាក់ទំនងល្អជាមួយអ្នកដទៃ និងសមាជិកក្នុងក្រុម
- o សម្របសម្រួល និងដោះស្រាយបញ្ហាក្នុងក្រុម
- o ដើរតួជាជនគំរូនូវគ្រប់ការអនុវត្តសកម្មភាពគម្រោង
- o ធ្វើការយ៉ាងជិតស្និទ្ធជាមួយជំនួយការរដ្ឋបាល និងអ្នកផ្សព្វផ្សាយកសិកម្មដើម្បីដោះស្រាយបញ្ហាប្រឈម។
- o ធានាថារាល់របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាសមានបញ្ចូលទិន្នន័យបែងចែកភេទ

- **លក្ខណៈសម្បត្តិរបស់ប្រធានក្រុម**
  - o គោលជំហររឹងមាំ នឹងម៉ឺងមាត់
  - o ជាមនុស្សរស់នៅក្នុងភូមិ ហើយលេចធ្លោនៅក្នុងសហគមន៍
  - o មានសមត្ថភាពអាចដឹកនាំក្រុមបាន
  - o មានភាពស្មោះត្រង់ និងឆ្លាតវាងវៃ
  - o ត្រូវមានចំណេះដឹងខ្លះៗពីឥណទានជនបទ
  - o មានអំណត់អត់ធ្មត់ ចេះជួយយកអាសារ និងជាមនុស្សសកម្ម
  - o ផ្តល់តម្លៃដល់សមាជិកស្ត្រី និងបុរសស្មើៗគ្នា ក្នុងការបញ្ចេញមតិ និងការធ្វើសេចក្តីសម្រេច
  - o មានទំនាក់ទំនងល្អជាមួយនឹងសមាជិកក្រុម ជាពិសេសជាមួយស្ត្រី

**៥.៣.២ តួនាទីអនុប្រធានក្រុម**

អនុប្រធានក្រុមគាំទ្រប្រធានក្រុម និងបំពេញមុខងារ ជំនួសប្រធានក្រុមនៅពេលគាត់អវត្តមានមិននៅក្នុងភូមិ។ ការទទួលខុសត្រូវសំខាន់របស់អនុប្រធានក្រុមមានដូចខាងក្រោម៖

- o ជួយផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់សមាជិករបស់ក្រុម និងបន្តអនុវត្តសកម្មភាពដែលគម្រោងផ្តល់ឱ្យ និងធានាថាប្រធានបទយេនឌ័រ ត្រូវបានបញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលបច្ចេកកសិកម្ម ឬការផ្សព្វផ្សាយនានា
- o ជួយផ្សព្វផ្សាយបញ្ហាសង្គម និងការបញ្ជ្រាបយេនឌ័រក្នុង LIG ដល់ សមាជិកក្រុម
- o ទទួលបន្ទុកទំនាក់ទំនងទូទៅ និងតាមដានសកម្មភាពក្នុងក្រុម
- o ចូលរួមសម្របសម្រួល និងដោះស្រាយបញ្ហារបស់ក្រុមដែលកើតមានឡើង

- ជួយរៀបចំធ្វើផែនការក្រុម កត់ត្រាកំណត់ហេតុ និងធ្វើរបាយការណ៍ ដល់សមាជិកក្រុមទាំងអស់
- ជួសមុខឱ្យប្រធានពេលប្រធានអវត្តមាន
- ត្រូវមានពេលវេលាគ្រប់គ្រាន់សម្រាប់ក្រុម
- ចូលរួមជាមួយក្រុមក្នុងការប្រមូលទុនតាមប្រភេទជា ថវិកា ស្រូវ ប្រាក់សន្សំ
- ជួយក្នុងការគ្រប់គ្រងសាច់ប្រាក់ ផ្ញើ និងដកប្រាក់ក្នុងធនាគារ
- ជួយកត់ត្រានូវរាល់ការសន្សំទាំងអស់របស់សមាជិកក្រុមនៅក្នុងសៀវភៅសន្សំ
- ជួយកត់ត្រានូវរាល់ការសន្សំទាំងអស់របស់សមាជិកក្រុមនៅក្នុងប័ណ្ណសន្សំ និងកម្ចី
- ជួយរក្សា និងរាប់ចំនួនទឹកប្រាក់សន្សំទាំងអស់ដែលបានទទួល
- តាមដាន និងឱ្យយោបល់ជាប្រចាំដល់សមាជិកណាដែលត្រូវការជំនួយ
- ជួយកត់ត្រានូវរាល់ការខ្ចីទាំងអស់របស់សមាជិកក្រុមនៅក្នុងសៀវភៅកម្ចី
- ជួយកត់ត្រារាល់ការខ្ចី និងការប្រាក់បានសងទាំងអស់របស់សមាជិកក្រុមនៅក្នុងសៀវភៅកម្ចី
- ជួយកត់ត្រានូវរាល់ការខ្ចី និងការប្រាក់បានសងទាំងអស់របស់សមាជិកក្រុមនៅក្នុងប័ណ្ណសន្សំ និងកម្ចី
- ធ្វើការយ៉ាងជិតស្និទ្ធជាមួយជំនួយការរដ្ឋបាល និងអ្នកផ្សព្វផ្សាយកសិកម្មដើម្បីដោះស្រាយបញ្ហាប្រឈមនានា

• **លក្ខណៈសម្បត្តិរបស់អនុប្រធាន**
  - អាចអាន និងសរសេរអក្សរបាន
  - មានសមត្ថភាពអាចកត់ត្រាពីដំណើរការរបស់ក្រុមបាន
  - មានចិត្តស្មោះត្រង់ វាងវៃ
  - ត្រូវមានចំណេះដឹងខ្លះៗពីឥណទានជនបទ
  - មានអំណត់អត់ធ្មត់ ចេះជួយយកអាសារ និងជាមនុស្សសកម្ម។
  - មានទំនាក់ទំនងល្អជាមួយនឹងសមាជិកក្រុម ជាពិសេសជាមួយនឹងស្ត្រី

### ៥.៣.៣ តួនាទីរបស់ហិរញ្ញិក

ការទទួលខុសត្រូវរបស់ហិរញ្ញិកមានដូចខាងក្រោម៖

- គ្រប់គ្រងបញ្ជីស្មាមក្រុមទាំងអស់ដែលមាន
- តាមដាន និងប្រមូលទុនក្រុមតាមប្រភេទទុននិមួយៗ
- កត់ត្រាការខ្ចីសងតាមប្រភេទទុននិមួយៗ និងរាល់ចំណាយចំណូលរបស់ក្រុម

- ធ្វើរបាយការណ៍អំពីស្ថានភាពទុន ចំណាយចំណូលជាទៀងទាត់ និងរាយការណ៍ដល់សមាជិកក្រុមទាំងអស់
- ទទួលខុសត្រូវក្នុងការគ្រប់គ្រងសាច់ប្រាក់
- ទទួលខុសត្រូវក្នុងការផ្ញើ និងដកប្រាក់ក្នុងធនាគារ
- កត់ត្រានូវរាល់ចំនួនសន្សំដែលទទួលបានពីសមាជិកក្រុមនៅក្នុងសៀវភៅ សាច់ប្រាក់
- កត់ត្រានូវរាល់ចំនួនប្រាក់សង់ដែលទទួលបានពីសមាជិកក្រុមនៅក្នុងសៀវភៅសាច់ប្រាក់
- កត់ត្រានូវរាល់ចំនួនចំណូលដែលទទួលបានពីសមាជិកក្រុមនៅក្នុងសៀវភៅសាច់ប្រាក់
- កត់ត្រានូវរាល់ចំនួនប្រាក់កម្ចីដែលបានផ្តល់ឱ្យសមាជិកក្រុមនៅក្នុងសៀវភៅសាច់ប្រាក់
- ធ្វើការគណនាសមតុល្យនៃសាច់ប្រាក់
- សហការជាមួយភ្នាក់ងារឥណទាន (ប្រសិនបើគម្រោងប្រើប្រាស់សេវាកម្ម ស្ថាប័នមីក្រូហិរញ្ញវត្ថុ MFI)
- ធ្វើការយ៉ាងជិតស្និទ្ធជាមួយជំនួយការរដ្ឋបាល និងអ្នកផ្សព្វផ្សាយកសិកម្មដើម្បីដោះស្រាយបញ្ហាប្រឈម ។

- **លក្ខណៈសម្បត្តិរបស់ហិរញ្ញិក**
  - អាចអាន និងសរសេរអក្សរបាន
  - មានសមត្ថភាពអាចកត់ត្រាពីដំណើរការសន្សំបាន
  - មានចិត្តស្មោះត្រង់ និងវាងវៃ ។

## ៥.៤. តួនាទី និងការទទួលខុសត្រូវរបស់សមាជិកក្រុម

សមាជិកក្រុមកែលម្អជីវភាពត្រូវទទួលខុសត្រូវដូចតទៅ៖

- ចូលរួមកែលម្អជីវភាពរបស់ខ្លួនដោយខ្លួនឯង
- ជាមេគ្រួសារល្អក្នុងការគ្រប់គ្រង និងលើកកំពស់ជីវភាពគ្រួសារ
- ជាសមាជិកក្រុមល្អក្នុងការអនុវត្ត និងគោរពតាមគោលការណ៍របស់ក្រុម
- សកម្មចូលរួមក្នុងចលនាអភិវឌ្ឍន៍គ្រប់វិស័យ
- ចូលរួមកាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារ និងឱ្យតម្លៃស្មើគ្នារវាងបុរស និងស្ត្រី
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីបញ្ហាសង្គម  និងយេនឌ័រ
- មិនមានការរើសអើងចំពោះស្ត្រីលើការងារបច្ចេកទេសកសិកម្មនានា
- ចូលរួមប្រជុំតាមការអញ្ជើញរបស់អ្នកដឹកនាំក្រុម
- អនុវត្តការងារផលិតកម្មតាមលក្ខណៈបច្ចេកទេសដែលបានបណ្តុះបណ្តាល

- រៀន និងជួយបង្រៀនដល់កសិករដទៃទៀតពីបច្ចេកទេសផលិតកម្មកសិកម្មដែលបានអនុវត្ត និងបណ្តុះបណ្តាល
- ខ្ចី និងសងរាល់បំណុលផ្សេងៗមកក្រុមវិញអោយបានគ្រប់ចំនួន និងបានទាន់ពេលវេលា
- ត្រូវមានពេលវេលាគ្រប់គ្រាន់ដើម្បីចូលរួមកសាងផែនការអភិវឌ្ឍន៍ក្រុម និងភូមិ
- មានសិទ្ធិឈរឈ្មោះអោយសមាជិកបោះឆ្នោតជាអ្នកដឹកនាំក្រុម
- ទទួលការបណ្តុះបណ្តាលពីបច្ចេកទេសផលិតកម្មកសិកម្ម និងឥណទាន
- ប្រាកដថាបញ្ហាយេនឌ័រ និងសង្គមបានបញ្ចូល និងបញ្ជ្រាបទៅក្នុងបទបញ្ជាផ្ទៃក្នុងក្រុម
- ទទួលទុន (សម្ភារ និងថវិកា មូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់)
- ចូលរួមមតិយោបល់ក្នុងការប្រជុំក្រុម ឬអង្គប្រជុំដទៃទៀតដែលពាក់ព័ន្ធទៅនឹងការងារអភិវឌ្ឍន៍
- ចូលរួមដោះស្រាយបញ្ហាផ្សេងៗដែលមាននៅក្នុងក្រុម
- បោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន
- រាយការណ៍ ឬសំណូមពរ ផ្លាស់ប្តូរអ្នកដឹកនាំក្រុមដែលអសកម្ម
- ចូលរួមការពារ និងថែរក្សាសម្បត្តិរបស់ក្រុម
- សមាជិកក្រុមត្រូវចូលរួមសន្សំប្រាក់ប្រចាំខែ និងប្រចាំឆ្នាំតាមចំនួនដែលក្រុមបានកំណត់
- មានសិទ្ធិប្រើប្រាស់ទុនក្រុមទៅតាមប្រភេទទុន ដែលមានការឯកភាពពីសមាជិក និងថ្នាក់ដឹកនាំក្រុមទាំងអស់។

### ៥.៥. អាណត្តិរបស់ប្រធានក្រុម

អាណត្តិរបស់ប្រធានក្រុមមានរយៈពេល២ឆ្នាំ។ ប្រធានក្រុមចាស់អាចឈរឈ្មោះឱ្យគេបោះឆ្នោតនៅអាណត្តិបន្ទាប់បាន ។ ការជ្រើសរើសថ្នាក់ដឹកនាំក្រុមថ្មី មុនអាណត្តិអាចធ្វើទៅបានក្នុងករណីដូចខាងក្រោម៖

- អសកម្មការងារក្នុងការដឹកនាំក្រុម
- ការលាលែងពីការងាររបស់អ្នកគ្រប់គ្រង
- មានជំងឺធ្ងន់ធ្ងរ មិនអាចបន្តសកម្មភាពការងារតទៅទៀតបាន
- អវត្តមានពីក្រុម និងសកម្មភាពរបស់ក្រុមរយៈពេល ៣០ថ្ងៃឡើងទៅ
- ការជំពាក់ទុនក្រុមលើសពីចំនួនកំណត់ និងហួសកាលកំណត់ច្រើនដង
- ប្រសិនបើមានការមិនពេញចិត្តចំពោះការប្រតិបត្តិរបស់អ្នកគ្រប់គ្រងមិនអាចទទួលយកបាន។

## ៥.៦. រចនាសម្ព័ន្ធក្រុម

ក្រុមនីមួយៗត្រូវបានដឹកនាំដោយថ្នាក់ដឹកនាំចំនួន៣រូប ដែលត្រូវជ្រើសតាំងឡើងតាមរយៈការបោះឆ្នោតរបស់សមាជិកក្រុមហើយត្រូវមានសមាសភាពដូចខាងក្រោម៖

១- ប្រធាន ១ រូប ទទួលបន្ទុកក្តាប់រួម

២- អនុប្រធាន ១ រូប ទទួលបន្ទុកផែនការ និងបញ្ជីការគណនេយ្យ

៣- ហិរញ្ញិក ១ រូប ទទួលបន្ទុកគ្រប់គ្រងថវិកា

**រចនាសម្ព័ន្ធក្រុមកែលម្អជីវភាព**



## ៦. ការគ្រប់គ្រងហិរញ្ញវត្ថុក្រុម

### ៦.១. ធនធានហិរញ្ញវត្ថុសម្រាប់ក្រុមកែលម្អជីវភាព

- ជំនួយហិរញ្ញប្បទានពីគម្រោង តាមរយៈមូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ (CDF)
- ការប្រាក់ ១០០%ពីទុនរបស់ក្រុម
- ប្រាក់សន្សំប្រចាំខែ របស់សមាជិកក្រុម (*សូមមើលឧបសម្ព័ន្ធ ០៧ ស្តីពីប័ណ្ណចំណូលក្រុម*)
- មូលនិធិផ្សេងណាមួយដែលក្រុមនឹងទទួលពីគម្រោងផ្សេង ។

### ៦.២. មុខសញ្ញាដែលត្រូវចំណាយ

| | |
|---|---|
| - ចំណាយរដ្ឋបាល និងការងារផ្សេងៗ | ១០% នៃការប្រាក់ដែលប្រមូលបាន |
| - ចំណាយលើការឧបត្ថម្ភដល់ថ្នាក់ដឹកនាំក្រុម | ៣០% នៃការប្រាក់ដែលប្រមូលបាន |
| - ហិបសង្គ្រោះ | ១០% នៃការប្រាក់ដែលប្រមូលបាន |

(*សូមមើលឧបសម្ព័ន្ធ ០៨ស្តីពីប័ណ្ណចំណាយរបស់ក្រុម*)

**ថ្នាក់ដឹកនាំក្រុមត្រូវប្រើប្រាស់ការចំណាយដូចតទៅ៖**

- ចំណាយរដ្ឋបាលត្រូវប្រើឱ្យមានប្រសិទ្ធភាព ដោយការរក្សានូវវិក្ក័យប័ត្រ ដើម្បីបង្ហាញដល់សមាជិកពេលប្រជុំក្រុម ហើយការចំណាយនេះមិនអាចលើសពី ១០% ដូចមានចែងខាងលើ ។
- ថ្នាក់ដឹកនាំក្រុមរួមមានប្រធាន អនុប្រធាន និងហិរញ្ញិក នឹងទទួលបានប្រាក់ឧបត្ថម្ភស្មើៗគ្នា ដែលដកយក ៣០% នៃការប្រាក់ដែលប្រមូលបានពីសមាជិកក្រុម ។
- ថ្នាក់ដឹកនាំក្រុមមានសិទ្ធិដកយកប្រាក់ឧបត្ថម្ភខ្លួនបានក្នុងករណីដែលសមាជិកក្រុមទាំងអស់បានសងទុនទាំងអស់ដែលបានខ្ចីមកក្រុមវិញ ហើយទុនដែលបានសងទាំងអស់ត្រូវបានបញ្ចូលនៅក្នុងធនាគាររួចរាល់ ។
- ថ្នាក់ដឹកនាំក្រុមត្រូវរក្សាទុក ១០% នៃការប្រាក់នៅក្នុងហិបសង្គ្រោះជាប្រចាំ ដោយមិនដកឱ្យសមាជិកណាម្នាក់យកទៅប្រើប្រាស់បានឡើយ ។ ប្រាក់នេះរក្សាទុកដល់គ្រួសារណាដែលមានករណីចាំបាច់បន្ទាន់ដោយមិនគិតការប្រាក់ ។ ប្រាក់នេះក៏អាចជួយឧបត្ថម្ភដល់សមាជិកក្រុមដែលមានជំងឺធ្ងន់ធ្ងរ ឬធ្វើពិធីបុណ្យសព ។

### ៦.៣. ប្រាក់កម្ចី

កម្រិតប្រាក់ទុនត្រូវឱ្យសមាជិកក្រុមខ្ចី អាស្រ័យការសម្រេចរបស់ក្រុម ។ ការប្រាក់ដែលសមាជិកត្រូវបង់(ជាភាគរយ)កំណត់ដោយការប្រជុំសមាជិកក្រុម ប៉ុន្តែគួរត្រូវបានពិចារណាពីអតិផរណា និងមូលដ្ឋានប្រតិបត្តិការដូចមានក្នុងចំនុច ៦.២ ខាងលើ ។ ការកំណត់ពេលវេលាខ្ចី និងសងគឺអាស្រ័យការប្រជុំសម្រេចរបស់សមាជិក

តែមិនត្រូវលើសពី១២ខែ ឡើយ។ ក្រុមមានសិទ្ធិរក្សាទុកទុនបង្វិលមិនលើសពី ៣០០.០០០រៀល (សាមសិបម៉ឺនរៀល) សូមមើលឧបសម្ព័ន្ធ ខ០៩ ស្តីពីកិច្ចសន្យាខ្ចីប្រាក់។

ថ្នាក់ដឹកនាំក្រុម ដោយមានជំនួយពីអ្នកផ្សព្វផ្សាយកសិកម្ម និងជំនួយការរដ្ឋបាល ធ្វើការពិនិត្យតាមដាននូវរាល់សកម្មភាពរបស់សមាជិកក្រុមដែលបានខ្ចីប្រាក់។ ការធ្វើបែបនេះគឺដើម្បីធានាថា សមាជិកនោះបានប្រើប្រាស់ទុនត្រឹមត្រូវទៅតាមសំណើផែនការសកម្មភាពដែលបានដាក់ស្នើសុំ (សូមមើលឧបសម្ព័ន្ធ ខ១០ ស្តីពីតារាងតាមដានប្រាក់កម្ចីរបស់ក្រុមសន្សំប្រាក់)។

ក្នុងករណី សមាជិកក្រុមដែលទទួលមរណភាព ឬគ្រោះមហន្តរាយណាមួយ ហើយមិនមានសមាជិកគ្រួសារដែលត្រូវទទួលសងបន្ត សមាជិកក្រុមទាំងអស់ធ្វើការប្រជុំធ្វើលិខិតជូនដំណឹងដល់រដ្ឋអំណាចភូមិ និងឃុំសង្កាត់ពីមរណភាពរបស់សមាជិកនោះ ។ សមាជិកទាំងអស់ត្រូវប្រជុំដើម្បីពិភាក្សាពីយន្តការសម្រាប់ការសងជំនួសវិញ រួមទាំងលទ្ធភាពនៃការប្រើមូលនិធិសង្គ្រោះ។ សមាជិកទាំងអស់អាចសម្រេចពីការបរិច្ចាកទៅលើការចំណាយធ្វើបុណ្យសព្វដែលយកពីមូលនិធិសង្គ្រោះផងដែរ។

### ៦.៤ ក្រុមសន្សំ

សមាជិកក្រុមដែលផ្លាស់ប្តូរទីលំនៅស្របច្បាប់ដោយមានការបញ្ជាក់ពីរដ្ឋអំណាចភូមិ និងឃុំ សង្កាត់ច្បាស់លាស់មានសិទ្ធិអាចដកថវិកាចូលជាសមាជិកភាពរបស់ខ្លួននៅក្នុងក្រុមទាំងការទាំងដើម និងការប្រាក់ចំនួន ៥០% នៃទុនកម្ចីដែលក្រុមសន្សំផ្តល់ឱ្យ។

### ៦.៥. ការរក្សាទុក និងដកប្រាក់ពីធនាគារ

ក្រុមកែលម្អជីវភាពគួរបង្កើតគណនីនៅធនាគារជាជាងថ្នាក់ដឹកនាំក្រុមកាន់សាច់ប្រាក់ខ្លួនឯង។ ក្រុមគួរធ្វើការបិទបញ្ជីប្រចាំឆ្នាំ ហើយកាលបរិច្ឆេទនៃការបិទបញ្ជីត្រូវធ្វើការប្រជុំពិភាក្សាជាមួយសមាជិកក្រុមយ៉ាងតិច ២ ភាគ៣នៃសមាជិកសរុប។ ថវិកាប្រមូលបានពីការបិទបញ្ជីត្រូវរក្សាទុកនៅក្នុងធនាគារជាចាំបាច់ ពោលគឺនៅពេលប្រជុំបិទបញ្ជីតែម្តង ជៀសវាងការរក្សាទុកថវិកានៅកន្លែងគ្មានសុវត្ថិភាព។ ថ្នាក់ដឹកនាំក្រុមអាចមានសិទ្ធិយកប្រាក់ទៅផ្ញើនៅធនាគារក្រោមការឯកភាពពីសមាជិកក្រុម។ ការដកប្រាក់ពីធនាគារត្រូវដកថវិកាតាមចំនួនដែលសមាជិកក្រុមម្នាក់ៗស្នើសុំដោយមានការឯកភាពពីសមាជិកក្រុម និងជូនដំណឹងដល់ក្រុមប្រឹក្សាឃុំ សង្កាត់។ ថ្នាក់ដឹកនាំក្រុមពីរនាក់ក្នុងចំណោមបីនាក់មានសិទ្ធិដកប្រាក់ពីធនាគារ ដោយមានផែនការសកម្មភាពដែលបានផ្តល់អនុលោមភាព សៀវភៅធនាគារ និងប័ណ្ណដកសាច់ប្រាក់។ ក្រុមកែលម្អជីវភាព មានសិទ្ធិជ្រើសរើសធនាគារដែលមានប្រតិបត្តិការនៅនឹងមូលដ្ឋានរបស់ខ្លួន។ ប្រព័ន្ធធនាគារតាមភូមិរបស់មីក្រូហិរញ្ញវត្ថុជនបទអាចជាជម្រើសមួយសម្រាប់ក្រុម។

### ៦.៦. បញ្ជីគណនេយ្យ

ប្រាក់ដែលមាននៅក្នុងគណនេយ្យត្រូវធ្វើបញ្ជីចំណូលចំណាយឱ្យបានច្បាស់លាស់។ ប្រាក់ចំណូល និងចំណាយត្រូវរាយការណ៍ជូនអង្គប្រជុំរៀងរាល់ពេលប្រជុំ។ ក្រុមត្រូវបិទបញ្ជីប្រចាំឆ្នាំ ឬអាស្រ័យលើការប្រជុំក្រុមសម្រេច ហើយទុនប្រមូលបានត្រូវបញ្ចូលក្នុងធនាគារមុនដកយកមកប្រើប្រាស់ឡើងវិញនៃឆ្នាំបន្ទាប់។ ក្រុមកែលម្អជីវភាពនឹងកត់ត្រានូវរាល់ទុនទាំងអស់ដែលផ្តល់ទៅឱ្យសមាជិកក្រុមនៅក្នុងសៀវភៅសមាជិកក្រុម។ អ្នកផ្សព្វផ្សាយកសិកម្ម ជំនួយការរដ្ឋបាល អ្នកគ្រប់គ្រងក្រុម និងហិរញ្ញិកនឹងត្រូវធានាកំណត់ត្រាទាំងនេះឱ្យមានភាពច្បាស់លាស់ និងទៀងទាត់តាមពេលវេលា។ ក្រុមកែលម្អជីវភាពនឹងមាននូវកំណត់ត្រាមួយចំនួនដូចខាងក្រោម៖

- កិច្ចសន្យាខ្ចីប្រាក់ (សូមមើលឧបសម្ព័ន្ធ ខ០៩)
- សៀវភៅសន្សំប្រាក់របស់សមាជិក (សូមមើលឧបសម្ព័ន្ធ ខ១១)
- បញ្ជីចំណូល ចំណាយរបស់ក្រុម (សូមមើលឧបសម្ព័ន្ធ ខ១២)
- របាយការណ៍ចំណេញ ខាតប្រចាំខែ
- សៀវភៅឥណទានក្រុម (សូមមើលឧបសម្ព័ន្ធ ខ១៣)
- បញ្ជីផ្សេងទៀតចាំបាច់សម្រាប់ក្រុម...

# ៧. ការបណ្តុះបណ្តាល

## ៧.១. ប្រធានបទ

ក្រោយពីបង្កើតបានក្រុមកែលម្អជីវភាពគ្រប់ចំនួនដែលបានកំណត់ ហើយការងារបន្ទាប់គឺការផ្តល់ការបណ្តុះបណ្តាលដល់ក្រុមទាំងនោះទៅតាមប្រភេទនៃក្រុមនិមួយៗ។ យ៉ាងហោចណាស់ត្រូវមានវគ្គបណ្តុះបណ្តាលរយៈពេលបីថ្ងៃត្រូវរៀបចំឡើងសម្រាប់អ្នកដឹកនាំក្រុម ដែលផ្តោតសំខាន់ ស្តីពីយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងក្រុម និងការចុះបញ្ជី។ ដោយយោងទៅលើការដែលអ្នកគ្រប់គ្រងក្រុមមួយចំនួនមិនសូវមានចំណេះដឹងគ្រប់គ្រាន់ ការបណ្តុះបណ្តាលចាំបាច់ត្រូវមានលក្ខណៈសាមញ្ញជាទីបំផុត ហើយគំរូឯកសារមួយចំនួនតម្រូវឱ្យមានការរៀបចំជាស្រេចសម្រាប់ក្រុមបំពេញការងារ។ ការបណ្តុះបណ្តាលគួរបែងចែកជាពីរប្រភេទ គឺការបណ្តុះបណ្តាលក្រុម និងអ្នកដឹកនាំក្រុម ចំពោះប្រធានបទបណ្តុះបណ្តាលមួយចំនួនសម្រាប់អ្នកដឹកនាំក្រុម ដែលមិនមាននៅក្នុង CIP នឹងត្រូវដាក់បញ្ចូលក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ (AWBP) ដែលរៀបចំដោយក្រុមការងារគម្រោង។

ខាងក្រោមនេះជាប្រធានបទមួយចំនួនសម្រាប់បណ្តុះបណ្តាលក្រុមៈ

- តួនាទី និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ និងសមាជិកក្រុម និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុម
- ការគ្រប់គ្រងមូលនិធិទុនបង្វិលរបស់ក្រុម និងការចុះបញ្ជី
- ការបណ្តុះបណ្តាលពីដំណាំស្រូវ
- ការបណ្តុះបណ្តាលសួនបន្លែតាមផ្ទះ
- ការបណ្តុះបណ្តាលការចិញ្ចឹមមាន់
- ការបណ្តុះបណ្តាលការចិញ្ចឹមជ្រូក
- សុខភាព និងអាហាររូបត្ថម្ភ
- បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ
- ការសិក្សា និងការស្វែងយល់ពីព័ត៌មានទីផ្សារ
- ជំនាញសម្របសម្រួល
- ការធ្វើផែនការអភិវឌ្ឍ
- ការបញ្ជ្រាបយេនឌ័រក្នុងក្រុមកែលម្អជីវភាព
- បង្កើតមេរៀនខ្លីស្តីពីការវិភាគយេនឌ័រ និងសង្គមដើម្បីបញ្ចូលទៅក្នុងវគ្គបណ្តាលបច្ចេកទេសកសិកម្មនានា
- ការសរសេររបាយការណ៍ដោយមានការទទួលខុសត្រូវយេនឌ័រ
- បច្ចេកវិជ្ជាក្រោយពេលប្រមូលផល និង
- ការសរសេររបាយការណ៍....... ។ល។

### ៧.២. យុទ្ធសាស្ត្របណ្តុះបណ្តាល

ការធ្វើលទ្ធកម្មផ្តល់សេវាកម្មការបណ្តុះបណ្តាលចំពោះប្រធានបទខាងលើត្រូវធ្វើឡើងដោយគណៈកម្មការលទ្ធកម្មឃុំ សង្កាត់ ។ ក្រុមការងារគម្រោង នឹងរៀបចំគោលការណ៍ណែនាំស្តីពីសេវាកម្មខាងលើនេះ ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធសម្រាប់យកទៅអនុវត្ត ។

យុទ្ធសាស្ត្រនៃវគ្គបណ្តុះបណ្តាល ត្រូវអនុវត្តតាមគោលការណ៍នៃការបណ្តុះបណ្តាលដែលមានលក្ខណៈសាមញ្ញ តាមបែបចូលរួម សិស្សមជ្ឈមណ្ឌល និងខ្លឹមសារខ្លីៗងាយយល់ ។ ចំនុចសំខាន់មួយទៀតគឺជាការផ្សាភ្ជាប់ការសិក្សាទាំងឡាយទៅនឹងការអនុវត្តជាក់ស្តែង ឬផ្សាភ្ជាប់ទៅនឹងទស្សនៈកិច្ចសិក្សា ។ ដើម្បីធានាថាស្ត្រីយល់ច្បាស់ពីខ្លឹមសារនៃការបង្រៀនអ្នកសម្របសម្រួលគួររៀបចំក្រុមពិភាក្សាជាមួយសិក្ខាកាមស្ត្រីផ្សេងពីបុរស ។អ្នកសម្របសម្រួលត្រូវមានបុរស និងស្ត្រី ។

បង្កើតពេលវេលាបណ្តុះបណ្តាល មិនឱ្យចំពេលដែលស្ត្រីរវល់ (ដូចជាពេលដែលស្ត្រីរវល់រៀបចំចម្អិនអាហារឱ្យគ្រួសារជាដើម ។ល ។) គំនិតយោបល់របស់ស្ត្រីនឹងត្រូវយកមកវិភាគនិងពិចារណា ក្នុងកំឡុងពេលបណ្តុះបណ្តាល ដើម្បីលើកទឹកចិត្តស្ត្រីក្នុងការចូលរួមបញ្ចេញមតិ ។

ការបណ្តុះបណ្តាលក៏ត្រូវយកចិត្តទុកដាក់ផងដែរដល់ការពង្រឹងសមត្ថភាពអ្នកអនុវត្តគម្រោងគ្រប់លំដាប់ថ្នាក់ ជាពិសេសថ្នាក់ឃុំ សង្កាត់ ។ ការកសាងសមត្ថភាពជាប្រចាំធានាដល់និរន្តរភាពរបស់គម្រោងនាពេលចុងបញ្ចប់អាយុកាលរបស់គម្រោង ។

## ៨. បទបញ្ជាផ្ទៃក្នុងរបស់ក្រុម

### ៨.១. សារៈសំខាន់

បទបញ្ជាផ្ទៃក្នុងគឺជាឧបករណ៍ដ៏សំខាន់សម្រាប់ដឹកនាំក្រុមឆ្ពោះទៅរកភាពជោគជ័យ ។ បទបញ្ជានេះត្រូវបង្កើតឡើងដោយសមាជិកក្រុមខ្លួនឯងក្រោមការសម្របសម្រួលពីអ្នកផ្សព្វផ្សាយកសិកម្ម ជំនួយការរដ្ឋបាលឃុំសង្កាត់ ។ អ្នកដឹកនាំក្រុម និងសមាជិកក្រុមមានភារៈកិច្ចគោរពតាមបទបញ្ជាផ្ទៃក្នុងនេះឱ្យបានខ្ជាប់ខ្ជួន និងដោយស្មើភាពគ្នា វាជាឧបករណ៍មួយដែលនឹងត្រូវគេប្រើប្រាស់សម្រាប់វាយតម្លៃពីនិរន្តរភាពរបស់ក្រុម ។

### ៨.២. គំរូបទបញ្ជាផ្ទៃក្នុង

**គម្រោង**

**កាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប(គ.ក.អ.ក)**

**ស្រុក ............................ ខេត្ត....................................**

**ឧបត្ថម្ភដោយ ÷ធនាគារអភិវឌ្ឍន៍អាស៊ី** (ADB)

ADB Grant/Loan: 2599/0186-CAM

**ឈ្មោះឃុំ៖ ............................... ឈ្មោះភូមិ៖ ............................... ឈ្មោះក្រុម៖ ..........................**
**ថ្ងៃចាប់ផ្តើម៖ ...........................**

**ខ១.** ប្រជាពលរដ្ឋត្រូវចុះឈ្មោះជាសមាជិកក្រុមកែលម្អជីវភាពដើម្បីក្លាយខ្លួនជាសមាជិកពេញសិទ្ធិរបស់ក្រុម ហើយសមាជិកក្រុមត្រូវចូលរួមទុនបដិភាគជាទុនគ្រួសារចំនួន ៤០ ០០០រៀលក្នុងមួយគ្រួសារ ។

**ខ២.** សមាជិកក្រុមកែលម្អជីវភាពត្រូវតែជាមនុស្សដែលរស់នៅភូមិ ឃុំ សង្កាត់ខាងលើ ។

**ខ៣.** សមាជិកក្រុមកែលម្អជីវភាពត្រូវមានប្រវត្តិល្អ ស្មោះត្រង់ ឧស្សាហ៍ព្យាយាម និងមានទំនុកចិត្តគ្នាទៅវិញទៅមក ។

**ខ៤.** ក្រុមកែលម្អជីវភាពត្រូវជួបប្រជុំគ្នានៅរៀងរាល់ថ្ងៃ....ដើមខែ នៅវេលាម៉ោង.... នៅ ...... ។

**ខ៥.** សមាជិកក្រុមកែលម្អជីវភាពម្នាក់ៗត្រូវបង់ប្រាក់សន្សំ ចំនួន............រៀល រៀងរាល់ (១ខែឬបីខែ...) ។ ការបង់ប្រាក់សន្សំអតិបរមាគឺចំនួន..... រៀល ។

**ខ៦.** សមាជិកម្នាក់ៗត្រូវមានវត្តមាននៅរាល់ការប្រជុំចាប់ពី ៧០% ឡើងទៅទើបមានសិទ្ធិខ្ចីប្រាក់ពីក្រុម

**ខ៧.** ការខ្ចីប្រាក់មានរយៈពេល ០៦ ខែយ៉ាងយូរបំផុតរយៈពេលនេះកូនបំណុល (អ្នកខ្ចី) ត្រូវសងត្រឡប់មកក្រុមវិញ ។ ការខ្ចីប្រាក់អតិបរមាសម្រាប់សមាជិកម្នាក់គឺចំនួន..........រៀល ។

**ខ៨.** ជាគោលការណ៍អត្រាការប្រាក់គឺចំនួន ....% ក្នុងរយៈពេល....ខែ ។

**ខ៩.** ចំពោះករណីយឺតយ៉ាវក្នុងការសងប្រាក់ កូនបំណុលត្រូវបង់ការផាកពិន័យចំនួន ...% នៃប្រាក់កម្ចីក្នុងមួយសប្តាហ៍។

**ខ១០.** សមាជិកក្រុមកែលម្អជីវភាពមានសិទ្ធិខ្ចីប្រាក់ពីក្រុមសម្រាប់ការសង្គ្រោះបន្ទាន់លើបញ្ហាសុខភាព គ្រោះថ្នាក់ផ្សេងៗ ឬការបាត់បង់ដល់ជីវិតនូវសមាជិកក្នុងក្រុមគ្រួសារ។

**ខ១១.** គ្មានអត្រាការប្រាក់សម្រាប់ការខ្ចីក្នុងករណីសង្គ្រោះបន្ទាន់ ។

**ខ១២.** ការខ្ចីប្រាក់សម្រាប់ករណីសង្គ្រោះបន្ទាន់មានរយៈពេល ០៦ សប្តាហ៍យ៉ាងយូរ។

**ខ១៣.** ចំពោះករណីយឺតយ៉ាវក្នុងការសងប្រាក់កម្ចីសង្គ្រោះបន្ទាន់ កូនបំណុលត្រូវបង់ការផាកពិន័យចំនួន ០២% ក្នុងមួយសប្តាហ៍។

**ខ១៤.** ការមកប្រជុំត្រូវប្រព្រឹត្តទៅជាទៀងទាត់នឹងមានសមាជិកចូលរួមគ្រប់ចំនួន។ ការមកយឺត និងការឈប់គ្មានមូលហេតុសមរម្យនឹងត្រូវពិន័យជាប្រាក់ ១០០០រៀល។

**ខ១៥.** ក្នុងករណីសមាជិកណាម្នាក់ផ្លាស់ទីលំនៅចេញពីភូមិ សមាជិកនោះនឹងទទួលបាននូវប្រាក់សន្សំដែលគេបានបង់ ចំណែកនៃការប្រាក់ដែលត្រូវទទួល និងចំនួនទឹកប្រាក់ដែលបានមកពីការពិន័យផ្សេងៗ។

**ខ១៦.** ក្នុងករណីសមាជិកណាម្នាក់បោះបង់សមាជិកភាពរបស់ខ្លួនតែបន្តរស់នៅក្នុងភូមិដដែល សមាជិកនោះត្រូវរង់ចាំរហូតដល់បំណាច់ឆ្នាំទើបអាចទទួលបាននូវចំនួនទឹកប្រាក់របស់ខ្លួនដែលទទួលបន្ទាប់ពីក្រុមធ្វើការបិទបញ្ជីសិន

**ខ១៧.** ក្នុងករណីសមាជិកណាម្នាក់បាត់បង់ជីវិត បំណុលត្រូវសងដោយសមាជិកគ្រួសារនៃអតីតសមាជិកនោះ។ ផលប្រយោជន៍ទាំងឡាយដូចមានចែងក្នុង **ខ១៥** ខាងលើនឹងផ្តល់ជូនគ្រប់ចំនួនដល់សមាជិកនៃគ្រួសារនោះ។

**ខ១៨.** ការផ្លាស់ប្តូរ ឬការជំនួស (ក្នុង **ខ១៥** និង**ខ១៧** ខាងលើនេះ) សមាជិកភាពទៅឱ្យសមាជិកណាម្នាក់នៅក្នុងក្រុមគ្រួសារដដែលនឹងអាចធ្វើទៅបានលុះណាតែមានការឯកភាពពីសមាជិកទាំងអស់។

# ៩. ការណែនាំស្តីពីការប្រជុំក្រុម

## ៩.១. ការប្រជុំលើកទី១របស់ក្រុម

អ្នកផ្សព្វផ្សាយកសិកម្ម និងជំនួយការរដ្ឋបាលឃុំ សង្កាត់ មានតួនាទីសំខាន់ក្នុងការសម្របសម្រួលការប្រជុំលើកដំបូងរបស់ក្រុម។ ការប្រជុំនេះ មានគោលបំណងសំខាន់ក្នុងការត្រួសត្រាយផ្លូវឱ្យក្រុមចាប់ផ្តើមសកម្មភាពរបស់ខ្លួន ដោយមានទំនុកចិត្តខ្ពស់ដើម្បីបង្កើត និងអនុម័តចំនុចសំខាន់ៗមួយចំនួនមានដូចជា៖

- លក្ខន្តិកៈក្រុម (សូមមើលក្នុងឧបសម្ព័ន្ធ១៦)
- បទបញ្ជាផ្ទៃក្នុង
- តួនាទីរបស់ប្រធាន អនុប្រធាន ហិរញ្ញឹក និងសមាជិក
- គោលការណ៍នៃការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមទៅលើ៖ អត្រាការប្រាក់ ទំហំប្រាក់ខ្ចី រយៈពេលខ្ចីការប្រើប្រាស់ប្រាក់កម្ចី ចំនួនប្រាក់សន្សំដោយសមាជិកម្នាក់ និងការផាកពិន័យចំពោះសមាជិកដែលអនុវត្តខុសបទបញ្ជាក្រុម។
- ការកត់ត្រាត្រឹមត្រូវ
- ទីតាំងការប្រជុំ ពេលវេលាប្រជុំ របៀបវារៈការប្រជុំ... ។ល។

## ៩.២. ការប្រជុំប្រចាំខែរបស់ក្រុម

### ៩.២.១. សារៈសំខាន់

ការប្រជុំមានសារៈសំខាន់ណាស់ក្នុងការអនុវត្តសកម្មភាពការងាររបស់ក្រុម ក៏ដូចជាការធានាពីនិរន្តរភាពរបស់ក្រុម។ តាមរយៈការសិក្សានានាបង្ហាញថាក្រុមដែលមានភាពជោគជ័យសព្វថ្ងៃនេះគឺជាក្រុមដែលមានការប្រជុំជាទៀងទាត់ មួយវិញទៀតរាល់បញ្ហាដែលកើតមានត្រូវដោះស្រាយនៅចំពោះមុខសមាជិកក្រុម។

ក្រុមដែលនឹងត្រូវបង្កើតមានចំនួនសមាជិកពី១០ ទៅ ២៥នាក់ ដូចនេះការប្រជុំត្រូវមានសមាជិកយ៉ាងហោចណាស់ ២០នាក់ដែលស្មើនឹង៨០% នៃសមាជិកទាំងអស់។ ក្នុងករណី សមាជិកវត្តមានមិនគ្រប់ចំនួន ការប្រជុំត្រូវលើកទៅពេលក្រោយ។ ការប្រជុំនិមួយៗត្រូវដឹកនាំដោយប្រធានក្រុមជានិច្ច ប៉ុន្តែ បើសិនប្រធានអវត្តមានអនុប្រធានក្រុមត្រូវមានភារកិច្ចដឹកនាំអង្គប្រជុំជំនួស។

រាល់ការប្រជុំគួរអញ្ជើញមេភូមិ អ្នកផ្សព្វផ្សាយកសិកម្ម ឬអ្នកពាក់ព័ន្ធដទៃទៀតបើអាចធ្វើបានដើម្បីជួយផ្តល់យោបល់ ឬដំណោះស្រាយបញ្ហាផ្សេងៗ។ ការប្រជុំសាមញ្ញអាចធ្វើរៀងរាល់ខែដោយអនុលោមទៅតាមការសម្រេចចិត្តរបស់សមាជិកក្រុម។ ក្រុមទាំងមូលត្រូវកំណត់ឱ្យបានច្បាស់ពីទីកន្លែងប្រជុំថ្ងៃខែ និងពេលវេលាប្រជុំ។ ទីកន្លែងនោះគួរស្ថិតនៅចំនុចកណ្តាលរវាងសមាជិកក្រុម ហើយជាកន្លែងដែលមិនរងនូវការរំខានផ្សេងៗនៅជុំវិញជាមួយគ្នានេះដែរ ពេលវេលាគួរសមស្របជាមួយសមាជិកទូទៅដោយផ្អែកតាមកាលៈទេសៈ និងវដ្តកាលការងាររបស់សមាជិកក្រុម អនុប្រធានក្រុមត្រូវដើរតួជាលេខាកត់ត្រាគ្រប់ការប្រជុំ។ ក្នុងនោះដែរ បញ្ជីវត្តមានតម្រូវឱ្យ

មាននូវរាល់កិច្ចប្រជុំរបស់ក្រុមទាំងអស់ (សូមមើលក្នុងឧបសម្ព័ន្ធខ១៧ គំរូបញ្ជីវត្តមាន) ។

**៩.២.២. របៀបវារៈ**

រាល់ការប្រជុំទាំងសាមញ្ញ ឬវិសាមញ្ញចាំបាច់ត្រូវមានរបៀបវារៈច្បាស់លាស់ ។ របៀបវារៈទាំងនោះត្រូវដាក់ចេញដោយសមាជិកក្រុមមិនមែនអត្តនោម័តដោយប្រធានក្រុមនោះទេ ។ របៀបវារៈគួរតែមានលក្ខណៈជាក់លាក់ ហើយមិនត្រូវមានចំនួនច្រើនហួសហេតុពេកដែលមិនមានពេលវេលាគ្រប់គ្រាន់នឹងពិភាក្សា ហើយធានាថាបញ្ហាយេនឌ័រ និងសង្គម ត្រូវបានបញ្ចូលក្នុងរបៀបវារៈនៃការប្រជុំក្រុម (សូមមើលក្នុងឧបសម្ព័ន្ធខ១៨ របៀបវារៈប្រជុំក្រុម) ។

ឧទាហរណ៍របៀបវារៈមានដូចជា៖

- របាយការណ៍ពីជំងឺសត្វ (សកម្មភាពកសិកម្ម)
- ការសន្សំ
- ការសងប្រាក់
- របាយការណ៍ស្ថានភាពទុនក្នុងខែកន្លងមក (ចំណូលចំណាយ)
- ការពង្រឹងក្រុម វិន័យ និងការផាកពិន័យ
- ការចែករំលែកបច្ចេកវិទ្យាកសិកម្មថ្មីៗ
- ការសិក្សាស្វែងយល់ពីព័ត៌មានទីផ្សារ
- ប្រាក់កម្ចី....... ។ល ។
- លើកផែនការសម្រាប់ខែបន្ទាប់
- អ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់ត្រូវណែនាំពីការចុះបញ្ជីស្នាម និងរបាយការណ៍ស្ថានភាពទុនដោយផ្ទាល់នៅពេលចប់ប្រជុំដល់ហិរញ្ញិក ។

**៩.២.៣. ការផ្តើមអង្គប្រជុំ**

ប្រធានអង្គប្រជុំអាចចាប់ផ្តើមដោយការស្វាគមន៍សមាជិករបស់ខ្លួន បន្ទាប់មកគាត់អាចចាប់ផ្តើមដោយរំលឹកពីប្រធានបទសំខាន់មួយចំនួនដែលបានពិភាក្សាកាលពីការប្រជុំលើកមុន ។ ក្នុងនោះដែរ ប្រធានអង្គប្រជុំអាចលើកឡើងពីស្ថានភាពទូទៅក្នុងរយៈពេលមួយខែនេះ ។ ជាការសំខាន់ណាស់ដែលរបៀបវារៈសម្រាប់ការប្រជុំថ្ងៃនេះនឹងត្រូវលើកមកនិយាយប្រាប់ដល់អង្គប្រជុំទាំងមូលជាថ្មីម្តងទៀត ។ ប្រធានអង្គប្រជុំត្រូវសួរយោបល់អង្គប្រជុំទាំងមូលពីរបៀបវារៈដែលនឹងជជែកថ្ងៃនេះ ថាតើមានអ្នកណាចង់បន្ថែម ឬបន្ថយលើរបៀបវារៈនេះឬទេ? ឬមានប្រធានបទបន្ទាន់ណាមួយចាំបាច់បំផុត ដែលត្រូវលើកមកពិភាក្សាមុនគេឬទេ? ការចាប់ផ្តើមនេះត្រូវមានលក្ខណៈហ្មត់ចត់ និងច្បាស់លាស់ដើម្បីទាក់ទាញការយកចិត្តទុកដាក់របស់សមាជិកក្រុម ។

### ៩.២.៤. ការដឹកនាំអង្គប្រជុំ

- **របាយការណ៍ពីសមាជិក**

គួរមានពេលវេលាសម្រាប់សមាជិកណាដែលចង់រាយការណ៍ពីស្ថានភាពជាក់ស្តែងដែលកើតមានឡើងនៅក្នុងគ្រួសាររបស់គេ។ បញ្ហាអាចមានច្រើនពិសេស ចំពោះក្រុមចិញ្ចឹមសត្វ (គោ ក្របី ជ្រូក ឬមាន់)។ បញ្ហាបច្ចេកទេសស្ទើរតែទាំងអស់មិនអាចដោះស្រាយនៅកម្រិតក្រុមនោះទេ ប្រធានអង្គប្រជុំអាចសន្យាជាមួយក្រុមដោយលើកយកបញ្ហាទាំងនោះទៅពិភាក្សាជាមួយអ្នកផ្សព្វផ្សាយកសិកម្ម ក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីសម្របសម្រួលគម្រោងក្រុង ស្រុក ខេត្ត ឬទីប្រឹក្សាគម្រោង។

បន្ទាប់មកប្រធានអង្គប្រជុំត្រូវលើកយកប្រធានបទដែលមាននៅក្នុងរបៀបវារៈម្តងមួយៗមកពិភាក្សាជាមួយសមាជិកក្រុម។

### ៩.២.៥ ការបិទអង្គប្រជុំ

ប្រធានអង្គប្រជុំត្រូវបង្កលក្ខណៈយ៉ាងណាឱ្យមានបរិយាកាសល្អនូវរាល់ការប្រជុំនិមួយៗ។ ប្រធានអង្គប្រជុំ ក៏ត្រូវឆ្លៀតឱកាសនេះអរគុណចំពោះសមាជិកគ្រប់រូបដែលបានមកចូលរួម និងផ្តល់យោបល់ក្នុងអង្គប្រជុំនេះ។ ចំនុចដែលសំខាន់បំផុតនោះ គឺការសង្ខេបឡើងវិញពីការសម្រេចចិត្ត និងសកម្មភាពនានាដែលបានឯកភាពគ្នាមុននេះ ហើយត្រូវបញ្ជាក់ពីអ្នកដែលនឹងត្រូវទទួលខុសត្រូវអនុវត្តសកម្មភាពដែលព្រមព្រៀង។ លេខាកត់ត្រា (អនុប្រធាន)ត្រូវរក្សាទុកកំណត់ត្រា និងបញ្ជីវត្តមានការប្រជុំ (សូមមើលក្នុងឧបសម្ព័ន្ធ១៩ កំណត់ត្រាការប្រជុំ)។

# ១០. ការធ្វើផែនការក្រុម

## ១០.១. តើផែនការជាអ្វី?

ផែនការ គឺជាការគិតទុកជាមុននូវអ្វីដែលនឹងត្រូវធ្វើ និងតម្រូវការផ្សេងៗ សម្រាប់ពេលអនាគតដើម្បីសម្រេចបាននូវគោលដៅដែលចង់បាន។ គោលដៅត្រូវតែមានភាពជាក់លាក់ សមស្រប និងច្បាស់លាស់ ដោយផ្អែកលើបទដ្ឋានត្រឹមត្រូវ ហើយមានទំនាក់ទំនងច្បាស់លាស់ពីផ្នែកមួយទៅផ្នែកមួយទៀត។ ការកំណត់គោលដៅអាចកំណត់សម្រាប់រយៈពេលវែង ឬសម្រាប់រយៈពេលខ្លីទៅតាមប្រភេទនៃផែនការ។ ដើម្បីកំណត់គោលដៅឱ្យបានសមស្រប អ្នករៀបចំផែនការត្រូវវិភាគឱ្យបានច្បាស់លាស់អំពី ពេលវេលា ធនធាន និងមជ្ឈដ្ឋានជុំវិញដែលកំពុងប្រតិបត្តិ និងបញ្ចូលការងារយេនឌ័រ និងសង្គមទៅក្នុងផែនការរួម។ ហើយជាទូទៅ ក៏ត្រូវពឹងផ្អែកជាសំខាន់ទៅលើបទពិសោធន៍ពីអតីតកាលផងដែរ។

ផែនការ ជាបណ្តុំនៃសកម្មភាពដែលទាក់ទងគ្នាទៅវិញទៅមក ហើយរួមចំណែកសម្រេចគោលបំណងតាមរយៈការប្រើប្រាស់ធនធានដែលមានស្រាប់ និងក្នុងរយៈពេលកំណត់មួយ។

ខាងក្រោមនេះ គឺជាធាតុសំខាន់ៗមួយចំនួនដែលត្រូវពិចារណានៅពេលរៀបចំផែនការៈ

- ហេតុអ្វីបានជាត្រូវរៀបចំផែនការ?
- តើលទ្ធផលរំពឹងទុកមានអ្វីខ្លះ?
- តើគោលបំណងរបស់ផែនការដែលត្រូវសម្រេចមានលក្ខណៈយ៉ាងម៉េចដែរ?
- តើអ្នកណាខ្លះជាអ្នកទទួលខុសត្រូវ?
- តើដំណាក់កាលនិមួយៗនៃផែនការគួរសម្រេចនៅពេលណា?
- តើដំណាក់កាលនិមួយៗគួរអនុវត្តនៅកន្លែងណា?

## ១០.២. តើអ្នកណាជាអ្នកធ្វើផែនការ?

ដើម្បីទទួលបានប្រាក់កម្ចី និងសេវាកម្មផ្សេងទៀតពីក្រុម ក្រុមតូចដោយមានការជួយជ្រោមជ្រែងពីអ្នកផ្សព្វផ្សាយកសិកម្ម និងជំនួយការរដ្ឋបាលឃុំ សង្កាត់ ត្រូវបង្កើតផែនការសកម្មភាពក្រុមទៅតាមការឯកភាពនៅក្នុងក្រុមរបស់ខ្លួន (សូមមើលឧបសម្ព័ន្ធ២០ ស្តីពីផែនការសកម្មភាពគម្រោងចិញ្ចឹមមាន់)។ ការមានផែនការរបស់ខ្លួនគឺដើម្បីៈ

- ដឹងពីស្ថានភាពនាពេលបច្ចុប្បន្ន និងគោលដៅដែលចង់ធ្វើឱ្យសម្រេចក្នុងពេលកំណត់ណាមួយ
- កំណត់ធនធានដែលត្រូវការប្រើប្រាស់ (ធនធានមនុស្ស ថវិកា សម្ភារ សង្គម)។
- កំណត់បាននូវសកម្មភាពដែលត្រូវអនុវត្តតាមជំហាននិមួយៗ ដើម្បីឈានទៅរកការសម្រេចនូវជោគជ័យនៃការអនុវត្តផែនការ។
- កំណត់បាននូវយុទ្ធសាស្ត្រដែលមានភាពប្រាកដនិយមក្នុងការអនុវត្តកិច្ចការ។

- ងាយស្រួលក្នុងការបែងចែកភារៈកិច្ច ការទទួលខុសត្រូវលើកិច្ចការងារ ។
- មានឧបករណ៍ជំនួយដល់ការតាមដាន និងវាយតម្លៃ ។
- ផ្តល់ដល់អ្នកពាក់ព័ន្ធដើម្បីជួយគាំទ្រ ។

**១០.៣. តើធ្វើផែនការនោះមានលក្ខណៈបែបណា?**

ដើម្បីធានាថាផែនការក្រុមដែលបានរៀបចំមានភាពប្រាកដប្រជាអាចយកទៅអនុវត្តបាន ផែនការនោះត្រូវរៀបចំឱ្យមានលក្ខណៈដូចខាងក្រោម ៖

- សាមញ្ញ ប៉ុន្តែល្អិតល្អន់ និងមានគោលបំណងច្បាស់លាស់
- អាចសម្រេចទៅបាន (មិនត្រូវមានមហិច្ឆិតាហួសហេតុ)
- សមស្របតាមកាលៈទេសៈ ពេលវេលា និងស្ថានភាពជាក់ស្តែងនៅក្នុងគ្រួសារ ឬសហគមន៍
- អាចវាស់វែងបាន
- មានការពេញចិត្តចូលរួមអនុវត្ត

# ១១. គោលការណ៍ឲ្យមាននិរន្តរភាពក្រុម

## ១១.១. ទុនពីខាងក្រៅ

នៅដំណាក់កាលចាប់ផ្តើម ក្រុមដែលបានបង្កើតឡើងត្រឹមត្រូវ និងទទួលស្គាល់ដោយមេឃុំចៅ សង្កាត់ ទទួលវគ្គបណ្តុះបណ្តាល បើកគណនេយ្យ និងការរៀបចំចាត់ចែងផ្សេងៗដូចជាការប្រជុំ...ជាដើម ។ល ។ នឹងទទួល បានទុនពីមូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ដែលនឹងវិភាជន៍ដោយក្រុមប្រឹក្សាឃុំ សង្កាត់ផ្អែកលើសមត្ថភាពរបស់ក្រុម កែលម្អជីវភាព ។ ជាការសំខាន់ណាស់ គ្រប់ក្រុមកែលម្អជីវភាពដែលបានបង្កើតនៅខេត្តទាំងបួន អាចបន្តសកម្ម ភាពរបស់ខ្លួនបានជារៀងរហូតនោះ សមាជិកក្រុមទាំងអស់ច្បាស់ពីតួនាទី និងធនធានខាងក្រៅត្រូវបានគៀងគរ ដើម្បីបង្កើនមូលនិធិរបស់ក្រុមដែលមានស្រាប់ ។ ទុនពីខាងក្រៅអាចជាទុនដែលបានមកពីការជួយឧបត្ថម្ភពី អង្គការមិនមែនរដ្ឋាភិបាលនានាកំពុងអនុវត្តសកម្មភាពនៅមូលដ្ឋានរបស់ខ្លួន ឬបានមកពីអង្គការតណទានជនបទ នានាដែលផ្តល់មូលនិធិបន្ថែមឱ្យក្រុមយោងទៅលើតម្រូវការចាំបាច់របស់ក្រុម ប៉ុន្តែការវាយតម្លៃមួយនឹងត្រូវធ្វើ ឡើងដើម្បីវាស់វែងពីសមត្ថភាព និងភាពរឹងមាំរបស់ក្រុមកែលម្អជីវភាពមុនពេលចាប់ផ្តើមទទួលយកទុនពីខាង ក្រៅ ។ ទុនពីខាងក្រៅអាចទទួលយកបាន លុះណាតែមានការឯកភាពដោយសម្លេងច្រើនលើសលប់នៃសមាជិក ក្រុម ។

## ១១.២. ទុនទ្រទ្រង់

ទុនទ្រទ្រង់គឺជាទុនរួមរបស់ក្រុម ហើយទុននេះប្រើប្រាស់សម្រាប់ប្រយោជន៍រួមរបស់ក្រុម ។ ទុនទ្រទ្រង់ បានមកពីការសន្សំរបស់សមាជិកប្រចាំខែ ឬប្រចាំឆ្នាំ បានមកពីការកាត់ភាគរយប្រាក់ចំណេញ និងបានមកពីសេវា កម្មផ្សេងៗ ហើយទុនទ្រទ្រង់អាចប្រើប្រាស់បានលុះត្រាតែមានផែនការសកម្មភាពក្រុមដែលបានអនុលោមភាព ។ តាមការសង្កេត ឃើញថាក្រុមកែលម្អជីវភាពមួយចំនួនឈប់ដំណើរការដោយសារក្រុមទាំងនោះអាស្រ័យលើទុន ពីខាងក្រៅខ្លាំងពេក ពេលម្ចាស់ជំនួយឈប់ជួយ ឬផ្អាកដំណើរការ ។ ម៉្យាងទៀត ក្រុមខ្លះមានទុនច្រើនតែអត់ដឹង ឬមិនព្រមកាត់ទុន ចំណេញមួយចំណែកសម្រាប់ជាប្រយោជន៍រួមនៅពេលដែលក្រុមមានបញ្ហាអ្វីមួយកើតឡើង ។ ទុនទ្រទ្រង់បានមកពីការកាត់ប្រាក់ចំណេញសុទ្ធដាក់ចូលក្នុងទុនទ្រទ្រង់ ការកាត់អាចមានចំនួន ៥% ឬ១០% ឬ ១៥% ពីប្រាក់ចំណេញសរុប គឺវាអាស្រ័យនឹងការសម្រេចចិត្តរបស់សមាជិកក្រុម ។

## ១១.៣. ការវាយតម្លៃក្រុម

គោលបំណងនៃការវាយតម្លៃគឺដើម្បីធានាពីភាពរឹងមាំ និងនិរន្តរភាពរបស់ក្រុមកែលម្អជីវភាព វាមាន គោលបំណងសំខាន់ដែលត្រូវអនុវត្តរួមមាន៖

- ការសិក្សាអាចទទួលយកបានលុះណាតែមានវត្តមានសមាជិកយ៉ាងតិច ៦០% ។
- ការសិក្សាវាយតម្លៃត្រូវអនុវត្តជារៀងរាល់ឆ្នាំ
- ចាត់វិធានការណ៍ពង្រឹងក្រុមបន្ថែមទៀតនៅពេលការវាយតម្លៃស្ថិតក្នុងកម្រិតខ្សោយ ឬមធ្យម ។

ការវាយតម្លៃអាចធ្វើជាបីប្រភេទ៖

**(១). ការវាយតម្លៃដោយខ្លួនឯង**

អ្នកផ្សព្វផ្សាយកសិកម្មឃុំ សង្កាត់គួរពន្យល់សមាជិកក្រុមក្នុងឃុំ សង្កាត់និមួយៗពីរបៀបធ្វើការវាយតម្លៃក្រុមកែលម្អជីវភាពរបស់ខ្លួនដោយខ្លួនឯងតាមរយៈបញ្ជីសំនួរដែលផ្តល់ឱ្យ ។ វាមានលក្ខណៈវិនិច្ឆ័យសំខាន់មួយចំនួន (បញ្ជីសំនួរ) ដែលលើកមកសាកសួរ ហើយសំនួរនិមួយៗត្រូវដាក់ពិន្ទុពី១ ដល់ ៣ (៣ជាពិន្ទុខ្ពស់ជាងគេ) សំនួរទាំងនោះមានដូចជា៖

| **លក្ខណៈវិនិច្ឆ័យ** | **ពិន្ទុ** | | |
|---|---|---|---|
| | **១** | **២** | **៣** |
| ១. មានការយល់ដឹងច្បាស់លាស់ពីការអនុវត្តគម្រោង LIGs? | | | |
| ២. សមាជិកក្រុមនៅតែប្រើប្រាស់បច្ចេកទេសផ្តល់ដោយគម្រោង? | | | |
| ៣. ជីវភាពរបស់សមាជិកម្នាក់ៗមានការកែលម្អ? | | | |
| ៤. មានការអនុវត្តបទបញ្ជាផ្ទៃក្នុងបានល្អ? | | | |
| ៥. LIGs មានទំនាក់ទំនងល្អជាមួយស្ថាប័នផ្សេងទៀតដូចជា អាជ្ញាធរមូលដ្ឋាន ផ្នែកកសិកម្ម អ្នកផ្តល់សេវាកម្ម... ។ល។ | | | |
| ៦. មានការប្តេជ្ញាចិត្ត និងសាមគ្គីភាពខ្ពស់នៅក្នុងក្រុម? | | | |
| ៧. មានការប្រជុំប្រចាំខែជាទៀងទាត់? (មានកំណត់ហេតុ និងរបាយការណ៍) | | | |
| ៨. មានការគ្រប់គ្រងទុនបង្វិលបានល្អ? (កត់ត្រាបញ្ជីស្នាមបានត្រឹមត្រូវ និងធ្វើបច្ចុប្បន្នភាពទាន់ពេលវេលា និងសមាជិកក្រុមបានសងទុនបង្វិលគ្រប់ចំនួន និងទាន់ពេលវេលា និងភាគរយនៃការកើនទុនបង្វិលក្រុម) | | | |
| ៩. គ្មានការបាត់បង់សមាជិកក្រុមទេ? | | | |
| ១០. មានបង្កើតផែនការជំនួញរបស់ក្រុម? | | | |
| ១១. មានភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងល្អ? | | | |
| ១២. មានអំពើហឹង្សាក្នុងគ្រួសារ? | | | |
| ១៣ តើអ្នកយល់ពីការបញ្ជ្រាបយេនឌ័រក្នុង LIG ឬទេ? | | | |
| **សរុប** | | | |

## ២). ការវាយតម្លៃដោយក្រុមការងារគម្រោង

ក្រុមការងារគម្រោង ក៏អាចធ្វើការវាយតម្លៃសមត្ថភាពក្រុមកែលម្អជីវភាពនៅពេលវេលាសមស្របណាមួយ ។ ការវាយតម្លៃតម្រូវឱ្យមានរៀបចំបង្កើតក្រុម ឬគណៈកម្មការមួយដែលមានសមាសភាព ដូចខាងក្រោមៈ

- ក្រុមការងារគម្រោងថ្នាក់ខេត្ត
- ក្រុមការងារគម្រោងថ្នាក់ក្រុង ស្រុក
- ទីប្រឹក្សាគម្រោងថ្នាក់ខេត្តពាក់ព័ន្ធជាជំនួយការ

ការវាយតម្លៃនេះត្រូវប្រើប្រាស់លក្ខណៈវិនិច្ឆ័យដូចខាងលើដែរ ឬប្រសិនបើចាំបាច់ក្រុមការងារត្រូវបង្កើតបញ្ជីសំនួរបន្ថែម ។ ការវាយតម្លៃវិភាគទិន្នន័យត្រូវធ្វើនៅតាមខេត្តនីមួយៗ ហើយបញ្ជូនលទ្ធផលទាំងនោះមកក្រុមការងារថ្នាក់ជាតិដើម្បីធ្វើសំយោគ ។ របាយការណ៍ចុងក្រោយនឹងត្រូវចែកចាយជូនជាព័ត៌មានអំពីសមត្ថភាពក្រុមកែលម្អជីវភាពដែលបានបង្កើតឡើងដោយគម្រោង ។

**ជំហាននៃការវាយតម្លៃ**

| សកម្មភាព | អ្នកសម្របសម្រួល | អ្នកចូលរួម | ទីតាំង |
|---|---|---|---|
| ១. ប្រជុំអ្នកពាក់ព័ន្ធ ដើម្បីណែនាំនិតិវិធីនៃការវាយតម្លៃ និងពិនិត្យបញ្ជីសំនួរ | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ | ក្រុមការងារគម្រោងថ្នាក់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ | ថ្នាក់ក្រុង ស្រុក |
| ២. ធ្វើការវាយតម្លៃក្រុមដោយខ្លួនឯង | -ក្រុមប្រឹក្សាឃុំ សង្កាត់<br>-អ្នកផ្សព្វផ្សាយកសិកម្ម និងជំនួយការរដ្ឋបាល | សមាជិកក្រុមការងារកែលម្អជីវភាព | ភូមិគោលដៅ |
| ៣. ធ្វើការវាយតម្លៃដោយក្រុមការងារគម្រោង | -ក្រុមការងារថ្នាក់ខេត្ត<br>-ក្រុមការងារក្រុង ស្រុកក្រៅគោលដៅ<br>- | -ក្រុមប្រឹក្សាឃុំ សង្កាត់<br>-ក្រុមកែលម្អជីវភាព<br>-CEW, CAA,<br>-ប្រធានភូមិ | ភូមិគោលដៅ |
| ៤. បូកសរុបលទ្ធផល | មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ | ក្រុមការងារគម្រោងថ្នាក់ខេត្ត ក្រុង ស្រុក | ខេត្ត |

**** កំណត់សំគាល់ ៖ ការវាយតម្លៃធ្វើនៅឆ្នាំនៃការបង្កើតក្រុមដំបូង និងរៀងរាល់១ឆ្នាំម្តងនៅឆ្នាំបន្ទាប់ ។*

## (៣). ការវាយតម្លៃតាមរយៈកិច្ចសន្យា

គម្រោងក៏អាចធ្វើការវាយតម្លៃសមត្ថភាពក្រុមតាមរយៈការចុះកិច្ចសន្យាជួលអ្នកផ្តល់សេវាកម្ម ដែលមានបទពិសោធន៍ជាមួយសហគមន៍ ។ កិច្ចការនេះត្រូវធ្វើនៅថ្នាក់ជាតិតាមរយៈការជ្រើសរើសតាមនីតិវិធីលទ្ធកម្ម ។ ក្រុមការងារថ្នាក់ជាតិមានភារៈកិច្ចរៀបចំលក្ខខណ្ឌការងារ មុនការចាប់ផ្តើមអនុវត្តការងារវាយតម្លៃនេះ ហើយការវាយតម្លៃអាចធ្វើរៀងរាល់បីឆ្នាំម្តង ឬក៏តាមការចាំបាច់ ។

## ១១.៤. គោលការណ៍ទូទៅ

- ក្រុមត្រូវបង្កើតឱ្យមានលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងក្រុម និងធានាថាបញ្ហាយេនឌ័រនិងសង្គមត្រូវបានបញ្ចូលទៅក្នុងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុម
- សមាជិកក្រុមទាំងអស់ត្រូវគោរពលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងក្រុមឱ្យបានល្អ
- សមាជិកក្រុមទាំងអស់ត្រូវគិតថា ក្រុមនេះជារបស់សមាជិកក្រុមទាំងអស់គ្នា មិនមែនជារបស់បុគ្គលណាម្នាក់ឡើយ
- ក្រុមត្រូវរៀបចំផែនការឱ្យបានច្បាស់លាស់ដូចជា ការប្រជុំជាមួយសមាជិកក្រុម ការផ្សព្វផ្សាយពីគោលការណ៍ និងអត្ថប្រយោជន៍របស់ក្រុមកែលម្អជីវភាពដល់ប្រជាពលរដ្ឋក្នុងភូមិ ការតាមដាន និងត្រួតពិនិត្យមើលការប្រើប្រាស់ប្រាក់កម្ចីរបស់សមាជិកក្រុម... ។ល។
- សមាជិកក្រុមសន្សំប្រាក់ទាំងអស់ត្រូវចូលរួមប្រជុំឱ្យបានទៀងទាត់ ដើម្បីពិភាក្សា និងផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក។
- ក្រុមត្រូវប្រើប្រាស់ប្រាក់សន្សំដែលសមាជិកបានដាក់សន្សំឱ្យអស់លទ្ធភាព។
- ការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាន និងហិរញ្ញិកក្រុម ត្រូវគោរពតាមគោលការណ៍ប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ។
- កំណត់អាណត្តិរបស់ប្រធាន អនុប្រធាន និងហិរញ្ញិកឱ្យបានច្បាស់លាស់។
- ពេលចប់អាណត្តិ ត្រូវធ្វើការបោះឆ្នោតម្តងទៀតឱ្យបានទៀងទាត់។

## **ឧបសម្ព័ន្ធ ២០១** ÷បញ្ជីឈ្មោះឃុំ សង្កាត់ និងកម្រិតភាពក្រីក្រ

| ល.រ | ខេត្ត | ស្រុក | ឃុំ | គ្រួសារ ក្រកំរិតទី១ | គ្រួសារ ក្រកំរិតទី២ | %គ្រួសារ ក្រកំរិត | %គ្រួសារ ក្រកំរិត២ | សរុបក្រកំរិត១ និង២ | គ្រួសារ សរុបក្នុងឃុំ |
|---|---|---|---|---|---|---|---|---|---|
| 1 | បន្ទាយមានជ័យ | ភ្នំស្រុក | ណាំតៅ | 373 | 457 | 14.80% | 18.10% | 32.80% | 2527 |
| 2 | | | ប៉ោយចារ | 246 | 423 | 10.20% | 17.60% | 27.90% | 2400 |
| 3 | | | ពន្លៃ | 180 | 367 | 6.50% | 13.20% | 19.70% | 2778 |
| 4 | | | ស្ពានស្រែង | 196 | 171 | 23.90% | 20.90% | 44.80% | 820 |
| 5 | | | ស្រះជីក | 187 | 227 | 12.70% | 15.40% | 28% | 1478 |
| 6 | | | ភ្នំដី | 212 | 333 | 11.10% | 17.50% | 28.60% | 1907 |
| 7 | | ព្រះនេត្រព្រះ | ឈ្នួរមានជ័យ | 113 | 361 | 7.90% | 25.30% | 33.20% | 1429 |
| 8 | | | ជប់វារី | 250 | 550 | 8.80% | 19.40% | 28.20% | 2840 |
| 9 | | | ភ្នំលៀប | 331 | 601 | 9.90% | 18.10% | 28% | 3329 |
| 10 | | | ប្រាសាទ | 151 | 279 | 9.80% | 18% | 27.80% | 1546 |
| 11 | | | ព្រះនេត្រព្រះ | 257 | 503 | 8.70% | 17% | 25.70% | 2957 |
| 12 | | | រហាល | 316 | 161 | 15.90% | 8.10% | 24% | 1989 |
| 13 | | | ទានកាំ | 91 | 168 | 10.50% | 19.40% | 30% | 864 |
| 14 | | | ទឹកជោរ | 332 | 425 | 12.20% | 15.70% | 27.90% | 2712 |
| 15 | | | បុសស្បូវ | 523 | 484 | 18.90% | 17.50% | 36.30% | 2772 |
| 16 | | អូរជ្រៅ | ចង្ហា | 95 | 247 | 6.30% | 16.30% | 22.60% | 1512 |
| 17 | | | កូប | 191 | 146 | 10% | 7.70% | 17.70% | 1902 |
| 18 | | | គុត្តសត | 73 | 98 | 6% | 8% | 14% | 1221 |
| 19 | | | សំរោង | 233 | 301 | 12.80% | 16.50% | 29.30% | 1820 |
| 20 | | | សូភី | 66 | 207 | 5.60% | 17.60% | 23.20% | 1175 |
| 21 | | | សឹង្ហ | 109 | 280 | 7.40% | 19% | 26.40% | 1471 |
| 22 | | | អូរបីជាន់ | 397 | 209 | 12.60% | 6.60% | 19.20% | 3159 |
| 23 | | សិរីសោភ័ណ | កោះពងសត្វ | 112 | 155 | 10.40% | 14.40% | 24.80% | 1075 |
| 24 | | | ម្កាក់ | 241 | 209 | 13.40% | 11.60% | 25% | 1797 |
| 25 | | | ភ្នៀត | 175 | 67 | 16.70% | 6.40% | 23.10% | 1047 |
| 26 | | | ទឹកថ្លា | 203 | 547 | 6.70% | 18.10% | 24.80% | 3026 |
| 27 | | ថ្មពួក | បន្ទាយឆ្មារ | 634 | 724 | 18.50% | 21.10% | 39.50% | 3436 |
| 28 | | | គោករមៀត | 669 | 997 | 14.90% | 22.30% | 37.20% | 4480 |
| 29 | | | ភូមិថ្មី | 82 | 316 | 5.10% | 19.60% | 24.70% | 1609 |
| 30 | | | ថ្មពួក | 112 | 254 | 5.70% | 12.90% | 18.60% | 1967 |
| 31 | | | គោកកបិន | 169 | 365 | 10.20% | 22% | 32.20% | 1657 |
| 32 | | | គំរូ | 172 | 204 | 10.20% | 12.10% | 22.30% | 1687 |
| **សរុប** | | | | **7491** | **10836** | **25.00%** | **30.20%** | **55.10%** | **66389** |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 33 | | | ចារឈូក | 108 | 252 | 5.80% | 13.50% | 19.40% | 1860 |
| 34 | | | ដូនពែង | 166 | 239 | 12.50% | 18% | 30.50% | 1326 |
| 35 | | | គោកដូង | 405 | 248 | 13.90% | 8.50% | 22.30% | 2922 |
| 36 | | អង្គរជុំ | គោល | 101 | 157 | 13% | 20.20% | 33.20% | 776 |
| 37 | | | នគរភាស | 153 | 297 | 9.20% | 17.80% | 26.90% | 1670 |
| 38 | | | ស្រែខ្វាវ | 272 | 311 | 16.30% | 18.60% | 34.90% | 1670 |
| 39 | | | តាសោម | 71 | 211 | 3.80% | 11.20% | 15% | 1876 |
| 40 | | | ខ្នារសណ្ដាយ | 550 | 354 | 34.90% | 22.50% | 57.40% | 1576 |
| 41 | | | ឃុនរាម | 183 | 145 | 19% | 15.10% | 34.10% | 962 |
| 42 | | បន្ទាយស្រី | ព្រះដាក់ | 163 | 296 | 9.80% | 17.90% | 27.70% | 1656 |
| 43 | | | រំចេក | 109 | 207 | 21.10% | 40.10% | 61.20% | 516 |
| 44 | | | រុនតាឯក | 97 | 173 | 7.40% | 13.20% | 20.60% | 1310 |
| 45 | | | ត្បែង | 309 | 334 | 18% | 19.50% | 37.60% | 1712 |
| 46 | | | ខ្វាវ | 451 | 291 | 18% | 11.60% | 29.60% | 2508 |
| 47 | | | គោកធ្លកលើ | 294 | 315 | 14% | 15% | 28.90% | 2105 |
| 48 | | | លៀងឫស្សី | 598 | 406 | 22.30% | 15.10% | 37.40% | 2687 |
| 49 | | ជីក្រែង | ពង្រក្រោម | 275 | 451 | 14.30% | 23.50% | 37.80% | 1921 |
| 50 | | | ពង្រលើ | 267 | 78 | 34.60% | 10.10% | 44.70% | 771 |
| 51 | សៀមរាប | | ឫស្សីលក | 506 | 630 | 17.90% | 22.30% | 40.30% | 2822 |
| 52 | | | សង្វើយ | 478 | 514 | 23.70% | 25.40% | 49.10% | 2020 |
| 53 | | | ជន្លាស់ដៃ | 196 | 215 | 10.80% | 11.80% | 22.60% | 1821 |
| 54 | | | ក្រូចគរ | 49 | 128 | 5.20% | 13.50% | 18.70% | 946 |
| 55 | | | រោងគោ | 77 | 188 | 7.30% | 17.80% | 25.10% | 1055 |
| 56 | | ក្រឡាញ់ | សែនសុខ | 144 | 156 | 8.70% | 9.40% | 18.20% | 1652 |
| 57 | | | ស្នួល | 111 | 276 | 8.10% | 20% | 28.10% | 1377 |
| 58 | | | ស្រណាល | 197 | 321 | 9.60% | 15.70% | 25.30% | 2048 |
| 59 | | | តាអាន | 41 | 108 | 5.20% | 13.60% | 18.70% | 796 |
| 60 | | | ស្លក្រាម | 288 | 505 | 7.60% | 13.30% | 20.90% | 3788 |
| 61 | | | គោកចក | 348 | 919 | 6.60% | 17.50% | 24.20% | 5241 |
| 62 | | | សាលាកំរើក | 122 | 121 | 3.60% | 3.60% | 7.10% | 3407 |
| 63 | | សៀមរាប | នគរធំ | 472 | 398 | 29.10% | 24.60% | 53.70% | 1620 |
| 64 | | | ជ្រាវ | 386 | 298 | 18.10% | 14% | 32.10% | 2131 |
| 65 | | | សំបួរ | 81 | 141 | 10.40% | 18% | 28.40% | 782 |
| 66 | | | ស្រង៉ែ | 246 | 175 | 19.20% | 13.60% | 32.80% | 1284 |
| 67 | | | ចាន់សរ | 109 | 426 | 5.70% | 22.30% | 28% | 1911 |
| 68 | | សូទ្រនិគម | ដំដែក | 239 | 403 | 8.10% | 13.60% | 21.70% | 2958 |
| 69 | | | គៀនសង្កែ | 298 | 327 | 14.50% | 16% | 30.50% | 2050 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 70 | | | ខ្នាស់ | 241 | 319 | 12.50% | 16.50% | 29% | 1932 |
| 71 | | | ខ្នារពោធិ៍ | 249 | 180 | 23.30% | 16.90% | 40.20% | 1067 |
| 72 | | | ពពេល | 367 | 451 | 16.80% | 20.60% | 37.30% | 2191 |
| 73 | | | សំរោង | 327 | 343 | 16.20% | 17% | 33.10% | 2023 |
| 74 | | | តាយ៉ែក | 406 | 588 | 15.60% | 22.50% | 38.10% | 2609 |
| 75 | | ស្រីស្នំ | ជ្រោយនាងងួន | 199 | 263 | 14.70% | 19.40% | 34.10% | 1356 |
| 76 | | | ក្លាំងហាយ | 77 | 189 | 11.80% | 29% | 40.90% | 651 |
| 77 | | | ត្រាំសសរ | 287 | 297 | 24.10% | 25% | 49.10% | 1189 |
| 78 | | | មោង | 146 | 282 | 16.40% | 31.70% | 48.10% | 889 |
| 79 | | | ប្រីយ៍ | 54 | 133 | 6.90% | 16.90% | 23.80% | 785 |
| 80 | | | ស្លែងស្ពាន | 429 | 482 | 22.90% | 25.70% | 48.60% | 1875 |
| 81 | | ស្វាយលើ | បឹងមាលា | 151 | 112 | 14.80% | 10.90% | 25.70% | 1023 |
| 82 | | | កន្ទួត | 46 | 59 | 12.70% | 16.30% | 29% | 362 |
| 83 | | | ខ្នងភ្នំ | 129 | 188 | 16.80% | 24.40% | 41.20% | 770 |
| 84 | | | ស្វាយលើ | 206 | 309 | 10.80% | 16.30% | 27.10% | 1899 |
| 85 | | | តាសៀម | 77 | 131 | 7.30% | 12.40% | 19.80% | 1053 |
| 86 | | វ៉ារិន | ប្រាសាទ | 91 | 198 | 9.30% | 20.10% | 29.40% | 983 |
| 87 | | | ល្វាក្រាំង | 86 | 122 | 13.80% | 19.50% | 33.30% | 625 |
| 88 | | | ស្រែណូយ | 884 | 734 | 27.10% | 22.50% | 49.50% | 3268 |
| 89 | | | ស្វាយ ស | 127 | 246 | 12.10% | 23.50% | 35.60% | 1047 |
| 90 | | | វ៉ារិន | 324 | 319 | 22% | 21.70% | 43.70% | 1473 |
| សរុប | | | | **13863** | **16959** | **27.80%** | **35.20%** | **63.10%** | **98603** |
| 91 | កំពង់ធំ | បារាយណ៍ | បាក់ស្នា | 239 | 167 | 20.30% | 14.20% | 34.50% | 1176 |
| 92 | | | ចើងដើង | 200 | 201 | 9.30% | 9.30% | 18.60% | 2152 |
| 93 | | | ច្រនៀង | 675 | 410 | 29.70% | 18% | 47.70% | 2276 |
| 94 | | | ឈូកខ្សាច់ | 342 | 266 | 12.20% | 9.50% | 21.60% | 2811 |
| 95 | | | ចុងដូង | 151 | 109 | 6.20% | 4.50% | 10.70% | 2428 |
| 96 | | | ជ្រលង | 390 | 413 | 30.90% | 32.70% | 63.60% | 1263 |
| 97 | | | គគីរធំ | 318 | 215 | 17.70% | 12% | 29.60% | 1799 |
| 98 | | | ស្រឡៅ | 350 | 268 | 17% | 13% | 30.10% | 2056 |
| 99 | | ស្ទឹងសែន | ដំរីជាន់ខ្លា | 106 | 167 | 10.10% | 16% | 26.10% | 1045 |
| 100 | | | អូរគន្ធរ | 128 | 165 | 15.20% | 19.60% | 34.80% | 843 |
| 101 | | | ព្រៃតាហ៊ូ | 140 | 217 | 12.90% | 20% | 32.80% | 1087 |
| 102 | | | អាចារ្យលាក់ | 85 | 134 | 6.50% | 10.30% | 16.80% | 1306 |
| 103 | | | ត្បូងក្រពើ | 208 | 158 | 17.30% | 13.10% | 30.40% | 1203 |
| 104 | | | ស្រយូវ | 560 | 836 | 14.50% | 21.60% | 36.10% | 3871 |
| 105 | | ប្រាសាទបល្ល័ង្គ | ដូង | 88 | 208 | 7.30% | 17.40% | 24.70% | 1198 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 106 | | | ក្រយា | 139 | 165 | 11.10% | 13.20% | 24.40% | 1248 |
| 107 | | | ផាន់ញើម | 130 | 173 | 12.40% | 16.50% | 28.90% | 1050 |
| 108 | | | សាគ្រាម | 278 | 345 | 16.60% | 20.60% | 37.20% | 1674 |
| 109 | | | សាលាវិស័យ | 571 | 638 | 22.30% | 24.90% | 47.10% | 2566 |
| 110 | | | សាមគ្គី | 47 | 124 | 6.20% | 16.30% | 22.40% | 763 |
| 111 | | | ទួលគ្រើល | 200 | 236 | 21.70% | 25.60% | 47.20% | 923 |
| 112 | | សណ្តាន់ | ឈើទាល | 68 | 150 | 4.70% | 10.30% | 15% | 1451 |
| 113 | | | ដងកាំបិត | 41 | 67 | 10.30% | 16.80% | 27.10% | 398 |
| 114 | | | ក្លែង | 49 | 93 | 6.40% | 12.10% | 18.40% | 770 |
| 115 | | | មានរិទ្ធ | 159 | 112 | 15.80% | 11.10% | 26.90% | 1006 |
| 116 | | | មានជ័យ | 177 | 182 | 13% | 13.40% | 26.40% | 1362 |
| 117 | | | ងន | 238 | 247 | 15.50% | 16.10% | 31.60% | 1537 |
| 118 | | | សណ្តាន់ | 253 | 250 | 13.80% | 13.60% | 27.40% | 1838 |
| 119 | | | សុចិត្រ | 129 | 30 | 28.40% | 6.60% | 34.90% | 455 |
| 120 | | សន្ទុក | បឹងល្វា | 200 | 259 | 14.90% | 19.30% | 34.20% | 1343 |
| 121 | | | ជ្រាប់ | 103 | 107 | 11.40% | 11.80% | 23.20% | 906 |
| 122 | | | កកោះ | 271 | 414 | 12.50% | 19.10% | 31.70% | 2163 |
| 123 | | | ក្រយា | 301 | 303 | 15.40% | 15.50% | 30.90% | 1955 |
| 124 | | | ញ៉ៅ | 58 | 45 | 11.20% | 8.70% | 19.80% | 520 |
| 125 | | | ប្រាសាទ | 184 | 218 | 9.50% | 11.20% | 20.60% | 1947 |
| 126 | | | ទីពោ | 254 | 273 | 14.70% | 15.80% | 30.40% | 1732 |
| 127 | | ស្ទោង | បន្ទាយស្ទោង | 487 | 444 | 24.30% | 22.20% | 46.50% | 2004 |
| 128 | | | ចំណារលើ | 413 | 449 | 20.90% | 22.80% | 43.70% | 1972 |
| 129 | | | កំពង់ចិនជើង | 149 | 127 | 10.90% | 9.30% | 20.30% | 1361 |
| 130 | | | ម្សាក្រង | 593 | 413 | 31.20% | 21.80% | 53% | 1898 |
| 131 | | | ពពក | 378 | 367 | 29.40% | 28.60% | 58% | 1285 |
| 132 | | | ប្រឡាយ | 536 | 418 | 23.40% | 18.20% | 41.60% | 2293 |
| 133 | | | ព្រះដំរី | 197 | 228 | 11.30% | 13.10% | 24.40% | 1745 |
| 134 | | | រុងរឿង | 88 | 244 | 8.60% | 23.80% | 32.40% | 1025 |
| 135 | | | សំព្រោច | 590 | 547 | 28.90% | 26.80% | 55.70% | 2043 |
| **សរុប** | | | | **11261** | **11602** | **49.20%** | **41.00%** | **90.20%** | **69747** |
| 136 | កំពង់ចាម | ដំបែ | ចុងជាច | 766 | 387 | 25.90% | 13.10% | 39% | 2958 |
| 137 | | | ពោកស្រុក | 374 | 157 | 18.50% | 7.80% | 26.20% | 2024 |
| 138 | | | នាងទើត | 115 | 173 | 14% | 21% | 35% | 822 |
| 139 | | | សេដា | 553 | 272 | 14.40% | 7.10% | 21.50% | 3838 |
| 140 | | | ទឹកជ្រៅ | 333 | 171 | 12.10% | 6.20% | 18.30% | 2752 |
| 141 | | | ត្រពាំងព្រីង | 265 | 243 | 9.90% | 9.10% | 19% | 2673 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 142 | | ពញាក្រែក | ដូនតី | 387 | 519 | 12.60% | 16.90% | 29.50% | 3066 |
| 143 | | | កក់ | 499 | 566 | 13.50% | 15.30% | 28.90% | 3689 |
| 144 | | | កណ្តាលជ្រៃ | 421 | 655 | 10.80% | 16.80% | 27.60% | 3903 |
| 145 | | | ក្រែក | 481 | 1160 | 6.40% | 15.40% | 21.80% | 7522 |
| 146 | | | ពពេល | 163 | 389 | 7.60% | 18.10% | 25.70% | 2148 |
| 147 | | | ត្រពាំងផ្លុង | 644 | 555 | 17.20% | 14.90% | 32.10% | 3734 |
| 148 | | | វាលម្លូ | 273 | 191 | 18.50% | 13% | 31.50% | 1472 |
| 149 | | បាធាយ | បាធាយ | 507 | 316 | 17.80% | 11.10% | 28.90% | 2846 |
| 150 | | | ច្បារអំពៅ | 168 | 169 | 14.20% | 14.30% | 28.50% | 1181 |
| 151 | | | ជើងព្រៃ | 189 | 367 | 11.60% | 22.60% | 34.20% | 1626 |
| 152 | | | មេព្រីង | 226 | 251 | 18.20% | 20.20% | 38.40% | 1242 |
| 153 | | | សណ្តែក | 365 | 282 | 15.30% | 11.90% | 27.20% | 2378 |
| 154 | | | តាំងក្រាំង | 357 | 373 | 16.20% | 16.90% | 33% | 2210 |
| 155 | | | តាំងក្រសាំង | 258 | 302 | 14.30% | 16.70% | 31% | 1808 |
| 156 | | | ត្រប់ | 421 | 283 | 22.40% | 15% | 37.40% | 1882 |
| 157 | | | ទំនប់ | 345 | 267 | 23.10% | 17.80% | 40.90% | 1496 |
| 158 | | ជើងព្រៃ | គោករវៀង | 55 | 75 | 5.10% | 7% | 12.10% | 1074 |
| 159 | | | ផ្តៅជុំ | 247 | 92 | 16.40% | 6.10% | 22.60% | 1503 |
| 160 | | | ព្រៃចារ | 116 | 243 | 6.80% | 14.20% | 21% | 1713 |
| 161 | | | ព្រីងជ្រៃ | 257 | 308 | 15.70% | 18.80% | 34.50% | 1636 |
| 162 | | | សំពងជ័យ | 430 | 497 | 12.10% | 14% | 26.10% | 3549 |
| 163 | | | ស្តើងជ័យ | 316 | 425 | 13% | 17.50% | 30.40% | 2434 |
| 164 | | | ស្រម៉ | 179 | 282 | 10.20% | 16% | 26.20% | 1761 |
| 165 | | | ត្រពាំងគរ | 439 | 290 | 30.50% | 20.10% | 50.60% | 1441 |
| 166 | | កងមាស | រាយពាយ | | | | | | |
| 167 | | | ព្រែកកុយ | | | | | | |
| 168 | | | កងតានុង | | | | | | |
| 169 | | | ខ្ចៅ | | | | | | |
| 170 | | | អង្គរបាន | 199 | 270 | 9.60% | 13.10% | 22.70% | 2068 |
| 171 | | | ព្រែកក្របៅ | 351 | 264 | 17.10% | 12.90% | 30% | 2048 |
| 172 | | | រកាគយ | 204 | 81 | 9.70% | 3.90% | 13.60% | 2094 |
| 173 | | | សួរគង | 340 | 250 | 14.50% | 10.70% | 25.20% | 2338 |
| 308 | | កោះសូទិន | កំពង់រាប | | | | | | |
| 308 | | | កោះសូទិន | | | | | | |
| 308 | | | ល្វេ | | | | | | |
| 308 | | | មហាលាភ | | | | | | |
| 308 | | | មហាខ្ញូង | | | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 308 | | | ពាមប្រធ្នោះ | | | | | | |
| 308 | | | ពង្រ | | | | | | |
| 308 | | | ព្រែកតានង់ | | | | | | |
| 309 | | ក្រូចឆ្មារ | ឈូក | | | | | | |
| 309 | | | ជំនីក | | | | | | |
| 309 | | | កំពង់ទ្រាស | | | | | | |
| 309 | | | កោះពីរ | | | | | | |
| 309 | | | ក្រូចឆ្មារ | | | | | | |
| 309 | | | ប៉ឹស១ | | | | | | |
| 309 | | | ប៉ឹស២ | | | | | | |
| 309 | | | ព្រែកអាជី | | | | | | |
| 309 | | | រការខ្នុរ | | | | | | |
| 309 | | | ស្វាយឃ្លាំង | | | | | | |
| 309 | | | ទ្រា | | | | | | |
| 309 | | | ទួលស្នួល | | | | | | |
| 315 | | ស្ទឹងត្រង់ | អារក្សត្នោត | | | | | | |
| 315 | | | ដងក្តារ | 473 | 445 | 20.20% | 19% | 39.10% | 2345 |
| 315 | | | អូរម្លូ | 491 | 318 | 24.90% | 16.10% | 41.10% | 1970 |
| 315 | | | ព្រះអណ្តូង | | | | | | |
| 315 | | | ព្រែកបាក់ | | | | | | |
| 315 | | | សូភាស | 603 | 308 | 28% | 14.30% | 42.30% | 2154 |
| 315 | | | ទួលព្រះឃ្លាំង | | | | | | |
| 315 | | | ទួលសំបួរ | | | | | | |
| 315 | | | | **12810** | **12196** | **15.70%** | **18.80%** | **34.50%** | **87398** |
| ***សរុប*** | | | | | | | | | |

*កំណត់ចំណាំ៖*

*(១) ឃុំកំពង់ធំបានប្តូរឈ្មោះមកជាដំរីជាន់ខ្លា និងឃុំត្បូងក្រពើបានប្តូរមកនៅក្រោមស្រុកស្ទឹងសែនវិញ ។*

*(២) ឃុំមួយចំនួននៅក្នុងខេត្តកំពង់ចាមមិនមានទិន្នន័យគ្រប់គ្រាន់*

## ឧបសម្ព័ន្ធ ២០២ ÷តារាងប្រៀបធៀបកម្រិតនៃភាពក្រីក្រតាមភូមិនៃឃុំ សង្កាត់គោលដៅ

| លេខកូដភូមិសាស្រ្ត | ខេត្ត | ស្រុក | ឃុំ | លេខរៀងភូមិ | ភូមិ | ចំនួនគ្រួសារក្រីក្រកំរិតទី១ | ចំនួនគ្រួសារក្រីក្រកំរិតទី២ | គ្រួសារក្រីក្រកំរិតទី១ (%) | គ្រួសារក្រីក្រកំរិតទី២ (%) | %សរុបគ្រួសារក្រីក្រកំរិតទី១ និងទី២ | ចំនួនគ្រួសារសរុបក្នុងភូមិ |
|---|---|---|---|---|---|---|---|---|---|---|---|
| 1030301 | បន្ទាយមានជ័យ | ភ្នំស្រុក | ពន្លៃ | 1 | តាវ៉ង | 12 | 54 | 2% | 9.10% | 11.10% | 596 |
| 1030302 | | | | 2 | ពន្លៃ | 67 | 114 | 9.20% | 15.70% | 24.90% | 726 |
| 1030303 | | | | 3 | ស្វាយស | 45 | 88 | 7.90% | 15.50% | 23.40% | 568 |
| 1030304 | | | | 4 | ស្វាយខ្មៅ | 21 | 41 | 7.10% | 13.90% | 21% | 295 |
| 1030305 | | | | 5 | គោកតាសុខ | 12 | 23 | 4.80% | 9.20% | 14.10% | 249 |
| 1030306 | | | | 6 | ពោធិវាំបុណ្យ | 23 | 47 | 6.70% | 13.70% | 20.30% | 344 |
| 1040801 | | ព្រះនេត្រព្រះ | ទឹកជោរ | 7 | ស្នាច់ | 47 | 59 | 12.70% | 15.90% | 28.60% | 370 |
| 1040802 | | | | 8 | ប៉ោយចារ | 20 | 22 | 13.10% | 14.40% | 27.50% | 153 |
| 1040803 | | | | 9 | តាខែក | 9 | 22 | 8.10% | 19.80% | 27.90% | 111 |
| 1040804 | | | | 10 | គោកកី | 15 | 18 | 12.40% | 14.90% | 27.30% | 121 |
| 1040805 | | | | 11 | ទន្លាប់ | 6 | 6 | 13.60% | 13.60% | 27.30% | 44 |
| 1040806 | | | | 12 | គោកទៀម | 8 | 14 | 10.10% | 17.70% | 27.80% | 79 |
| 1040807 | | | | 13 | ចារលើ | 23 | 23 | 13.90% | 13.90% | 27.70% | 166 |
| 1040808 | | | | 14 | កន្ទូត | 6 | 8 | 11.80% | 15.70% | 27.50% | 51 |
| 1040809 | | | | 15 | ថ្មី | 37 | 36 | 14.10% | 13.70% | 27.90% | 262 |
| 1040810 | | | | 16 | កណ្តាល | 13 | 15 | 13.80% | 16% | 29.80% | 94 |
| 1040811 | | | | 17 | ទឹកជោរ | 24 | 27 | 13% | 14.70% | 27.70% | 184 |
| 1040812 | | | | 18 | តាសៀវ | 13 | 17 | 12% | 15.70% | 27.80% | 108 |
| 1040813 | | | | 19 | កំពង់ថ្កូវ | 14 | 15 | 13.10% | 14% | 27.10% | 107 |
| 1040814 | | | | 20 | តាប៉ុន | 13 | 23 | 10.20% | 18% | 28.10% | 128 |
| 1040815 | | | | 21 | ស្វាយល្អ | 28 | 50 | 10% | 17.90% | 27.90% | 280 |
| 1040816 | | | | 22 | តាដែក | 12 | 13 | 13.20% | 14.30% | 27.50% | 91 |
| 1040817 | | | | 23 | សំរោង | 30 | 42 | 11.50% | 16.10% | 27.60% | 261 |
| 1040818 | | | | 24 | អន្លង់វិល | 14 | 15 | 13.70% | 14.70% | 28.40% | 102 |
| 1040901 | | | បុសស្បូវ | 25 | ត្រពែក | 17 | 11 | 9.90% | 6.40% | 16.30% | 172 |
| 1040902 | | | | 26 | កណ្តាល | 19 | 26 | 16% | 21.80% | 37.80% | 119 |
| 1040903 | | | | 27 | គោកធំ | 26 | 51 | 12.60% | 24.60% | 37.20% | 207 |
| 1040904 | | | | 28 | បុសស្បូវ | 58 | 25 | 26.10% | 11.30% | 37.40% | 222 |
| 1040905 | | | | 29 | សូត្រមន្ត | 36 | 10 | 29% | 8.10% | 37.10% | 124 |
| 1040906 | | | | 30 | ស្រះខ្ចុំ | 22 | 10 | 28.20% | 12.80% | 41% | 78 |
| 1040907 | | | | 31 | កាបៅ | 20 | 53 | 10.60% | 28% | 38.60% | 189 |
| 1040908 | | | | 32 | ក្បាលខ្ចីង | 26 | 19 | 21.10% | 15.40% | 36.60% | 123 |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| 1040909 | | | | 33 | ស្ពាថ់ | 25 | 5 | 31.60% | 6.30% | 38% | 79 |
| 1040910 | | | | 34 | បឹងវែង | 17 | 15 | 19.80% | 17.40% | 37.20% | 86 |
| 1040911 | | | | 35 | បន្ទាត់បោះ | 33 | 10 | 28.90% | 8.80% | 37.70% | 114 |
| 1040912 | | | | 36 | ព្រីងកោង | 75 | 95 | 16.20% | 20.50% | 36.60% | 464 |
| 1040913 | | | | 37 | ខ្នាស់ | 19 | 41 | 12% | 25.90% | 38% | 158 |
| 1040914 | | | | 38 | ខ្មែរ | 43 | 39 | 20.50% | 18.60% | 39% | 210 |
| 1040915 | | | | 39 | ឃ្មួស្វាយ | 16 | 14 | 18.60% | 16.30% | 34.90% | 86 |
| 1040916 | | | | 40 | ខ្វាវ | 44 | 25 | 24.70% | 14% | 38.80% | 178 |
| 1040917 | | | | 41 | ត្បែង | 27 | 35 | 16.60% | 21.50% | 38% | 163 |
| 1070201 | | ថ្មពួក | គោករមៀត | 42 | គោកព្រេច | 16 | 50 | 3.70% | 11.50% | 15.10% | 436 |
| 1070202 | | | | 43 | ស្រែល្អ | 23 | 93 | 4.30% | 17.30% | 21.50% | 539 |
| 1070203 | | | | 44 | គោករមៀត | 14 | 32 | 6.90% | 15.80% | 22.70% | 203 |
| 1070204 | | | | 45 | ស្តៅ | 4 | 24 | 7.40% | 44.40% | 51.90% | 54 |
| 1070205 | | | | 46 | ថ្មី | 8 | 69 | 2.20% | 18.90% | 21% | 366 |
| 1070206 | | | | 47 | តាឡី | 16 | 35 | 11.30% | 24.80% | 36.20% | 141 |
| 1070207 | | | | 48 | សេរីកា | 8 | 8 | 25% | 25% | 50% | 32 |
| 1070208 | | | | 49 | តាសុង | 13 | 33 | 11.10% | 28.20% | 39.30% | 117 |
| 1070209 | | | | 50 | ត្រពាំងសំរោង | 61 | 135 | 17.50% | 38.70% | 56.20% | 349 |
| 1070210 | | | | 51 | ផ្លូវបំបែក | 78 | 99 | 27.70% | 35.10% | 62.80% | 282 |
| 1070211 | | | | 52 | ថ្មដ៏ត្រ | 9 | 19 | 13.80% | 29.20% | 43.10% | 65 |
| 1070212 | | | | 53 | វល្លិប្រេង | 16 | 18 | 20% | 22.50% | 42.50% | 80 |
| 1070213 | | | | 54 | ប្រាំមីនា | 12 | 20 | 16% | 26.70% | 42.70% | 75 |
| 1070214 | | | | 55 | សាមគ្គី | 89 | 56 | 33.70% | 21.20% | 54.90% | 264 |
| 1070215 | | | | 56 | បន្ទាយមានរិទ្ធិ | 71 | 87 | 16.60% | 20.30% | 36.90% | 428 |
| 1070217 | | | | 57 | ស្ពាន | 10 | 35 | 9.60% | 33.70% | 43.30% | 104 |
| 1070218 | | | | 58 | កណ្តោល | 77 | 38 | 29.10% | 14.30% | 43.40% | 265 |
| 1070219 | | | | 59 | ក្តីបថ្ម | 16 | 11 | 9.60% | 6.60% | 16.30% | 166 |
| 1070220 | | | | 60 | បឹងតាស្រី | 46 | 35 | 30.10% | 22.90% | 52.90% | 153 |
| 1070221 | | | | 61 | បឹងសុក្រំ | 34 | 10 | 39.50% | 11.60% | 51.20% | 86 |
| 1070222 | | | | 62 | តាម៉ាំង | 31 | 45 | 21.50% | 31.20% | 52.80% | 144 |
| 1070291 | | | | 63 | អូកំបុត | 17 | 45 | 13% | 34.40% | 47.30% | 131 |
| ចំនួនសរុប/ មធ្យមភាគ | | | | | | **1704** | **2273** | **15.40%** | **18.57%** | **33.97%** | **12742** |
| 17110801 | សៀមរាប | សូទ្រនិគម | ពពេល | 1 | ព្រៃលាន | 32 | 54 | 11.10% | 18.80% | 30% | 287 |
| 17110802 | | | | 2 | ត្រពាំងត្រាវ | 11 | 19 | 7.10% | 12.30% | 19.50% | 154 |
| 17110803 | | | | 3 | គោល | 30 | 44 | 17.90% | 26.20% | 44% | 168 |
| 17110804 | | | | 4 | ថ្នល់ត្រង់ | 29 | 56 | 13.90% | 26.90% | 40.90% | 208 |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| 17110805 | | | | 5 | ត្រពាំងត្រុំ | 59 | 59 | 24% | 24% | 48% | 246 |
| 17110806 | | | | 6 | ត្រាចពក | 36 | 41 | 16% | 18.20% | 34.20% | 225 |
| 17110807 | | | | 7 | ពពេលកណ្ដាល | 30 | 32 | 24.80% | 26.40% | 51.20% | 121 |
| 17110808 | | | | 8 | ពពេលលិច | 14 | 7 | 17.90% | 9% | 26.90% | 78 |
| 17110809 | | | | 9 | ក្រៀលពង | 5 | 12 | 5.10% | 12.10% | 17.20% | 99 |
| 17110810 | | | | 10 | ដីរីកូន | 35 | 47 | 19.20% | 25.80% | 45.10% | 182 |
| 17110811 | | | | 11 | ត្រពាំងផុង | 25 | 31 | 15.60% | 19.40% | 35% | 160 |
| 17110812 | | | | 12 | ត្រពាំងប្រីយ៍ | 48 | 26 | 32% | 17.30% | 49.30% | 150 |
| 17110813 | | | | 13 | គោលថ្មី | 13 | 23 | 11.50% | 20.40% | 31.90% | 113 |
| 17140501 | | | | 14 | នេល | 22 | 46 | 19.80% | 41.40% | 61.30% | 111 |
| 17140502 | | | | 15 | រំដួល | 17 | 19 | 14.50% | 16.20% | 30.80% | 117 |
| 17140503 | | | | 16 | វ៉ារិន | 44 | 62 | 13.50% | 19% | 32.40% | 327 |
| 17140504 | | វ៉ារិន | វ៉ារិន | 17 | គោកភ្នំ | 51 | 60 | 26% | 30.60% | 56.60% | 196 |
| 17140505 | | | | 18 | គោកស្រុក | 105 | 58 | 31.10% | 17.20% | 48.20% | 338 |
| 17140506 | | | | 19 | ទួលរមៀត | 39 | 49 | 16.60% | 20.90% | 37.40% | 235 |
| 17140507 | | | | 20 | គោកគ្រួស | 46 | 25 | 30.90% | 16.80% | 47.70% | 149 |
| **ចំនួនសរុប/ មធ្យមភាគ** | | | | | | **191** | **770** | **56.71%** | **64.73%** | **121.46 %** | **172260** |
| 6030901 | | | | 1 | ក្រចាប់ | 42 | 39 | 9.20% | 8.50% | 17.60% | 459 |
| 6030902 | | | អាចារ្យលាក់ | 2 | អាចារ្យលាក់ | 27 | 38 | 5.70% | 8% | 13.60% | 477 |
| 6030903 | | | | 3 | ព្រៃបន្ទិច | 16 | 57 | 4.30% | 15.40% | 19.70% | 370 |
| 6031001 | | | | 4 | រលួស | 70 | 59 | 25.80% | 21.80% | 47.60% | 271 |
| 6031002 | | | | 5 | ប្រម៉ាត់ដី | 16 | 33 | 10.10% | 20.90% | 31% | 158 |
| 6031003 | | | | 6 | កំពង់សំរោង | 35 | 38 | 16.90% | 18.40% | 35.30% | 207 |
| 6031004 | | | | 7 | ពោធិ៍សែនស្នាយ | 60 | 87 | 17.80% | 25.70% | 43.50% | 338 |
| 6031005 | | ស្ទឹងសែន | | 8 | ពោធិ៍តាអ៊ុន | 37 | 38 | 13.80% | 14.20% | 28% | 268 |
| 6031006 | កំពង់ធំ | | ស្រយូវ | 9 | ត្រញ៉ាំងវែង | 23 | 92 | 7.40% | 29.60% | 37% | 311 |
| 6031007 | | | | 10 | ស្រយ៉ូវជើង | 93 | 73 | 21% | 16.50% | 37.60% | 442 |
| 6031008 | | | | 11 | ស្រយ៉ូវត្បូង | 40 | 49 | 18.30% | 22.40% | 40.60% | 219 |
| 6031009 | | | | 12 | ពុកយុក | 47 | 91 | 10.10% | 19.50% | 29.60% | 466 |
| 6031010 | | | | 13 | ម្នាវ | 47 | 79 | 16.30% | 27.40% | 43.80% | 288 |
| 6031011 | | | | 14 | ចំបក់ | 21 | 43 | 8.80% | 17.90% | 26.70% | 240 |
| 6031012 | | | | 15 | កំរែង | 31 | 47 | 15.80% | 24% | 39.80% | 196 |
| 6031013 | | | | 16 | រកា | 40 | 107 | 8.60% | 22.90% | 31.50% | 467 |
| 6040501 | | ប្រាសាទបល្ល័ង្គ | សាលាវិស័យ | 17 | ត្រញ៉ាំងក្រោល | 13 | 21 | 13.50% | 21.90% | 35.40% | 96 |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| 6040502 | | | | 18 | បុស្សរវែង | 20 | 28 | 15.50% | 21.70% | 37.20% | 129 |
| 6040503 | | | | 19 | បុស្សឫដូច | 18 | 42 | 14.90% | 34.70% | 49.60% | 121 |
| 6040504 | | | | 20 | ស្រែ | 33 | 57 | 18% | 31.10% | 49.20% | 183 |
| 6040505 | | | | 21 | ចំណារ | 21 | 20 | 28.80% | 27.40% | 56.20% | 73 |
| 6040506 | | | | 22 | អូរក្រូច | 6 | 33 | 7.80% | 42.90% | 50.60% | 77 |
| 6040507 | | | | 23 | សាលាវិស័យ | 96 | 60 | 30.50% | 19% | 49.50% | 315 |
| 6040508 | | | | 24 | អណ្តាស | 19 | 28 | 20% | 29.50% | 49.50% | 95 |
| 6040509 | | | | 25 | ត្រពាំងផ្ញៀក | 19 | 17 | 17.80% | 15.90% | 33.60% | 107 |
| 6040510 | | | | 26 | ត្រពាំងថ្ម | 20 | 35 | 14.90% | 26.10% | 41% | 134 |
| 6040511 | | | | 27 | បុស្សស្រមោច | 11 | 22 | 13.30% | 26.50% | 39.80% | 83 |
| 6040512 | | | | 28 | វាលល្ពាក់ | 36 | 52 | 22.60% | 32.70% | 55.30% | 159 |
| 6040513 | | | | 29 | ខ្វាក់ | 39 | 49 | 19.40% | 24.40% | 43.80% | 201 |
| 6040514 | | | | 30 | ត្រឡែក | 88 | 31 | 40.20% | 14.20% | 54.30% | 219 |
| 6040515 | | | | 31 | ដងអន្ទាក់ | 57 | 38 | 32.80% | 21.80% | 54.60% | 174 |
| 6040516 | | | | 32 | ជ័យ | 7 | 18 | 8.90% | 22.80% | 31.60% | 79 |
| 6040517 | | | | 33 | គគីរ | 32 | 34 | 21.30% | 22.70% | 44% | 150 |
| 6040518 | | | | 34 | ក្វាន់ទៀង | 25 | 47 | 19.40% | 36.40% | 55.80% | 129 |
| 6040519 | | | | 35 | សាលាពពេល | 11 | 6 | 26.20% | 14.30% | 40.50% | 42 |
| 6070701 | | សន្ទុក | ក្រយា | 36 | សំពុង | 5 | 22 | 6.40% | 28.20% | 34.60% | 78 |
| 6070702 | | | | 37 | ស៊ីវត្ថា | 30 | 15 | 9.50% | 4.80% | 14.30% | 315 |
| 6070703 | | | | 38 | ចំបក់ជ្រើ | 30 | 13 | 10.50% | 4.50% | 15% | 286 |
| 6070704 | | | | 39 | ប្រាសាទ | 12 | 34 | 5.40% | 15.20% | 20.50% | 224 |
| 6070705 | | | | 40 | តាញ៉ោក | 26 | 19 | 15.60% | 11.40% | 26.90% | 167 |
| 6070706 | | | | 41 | ស្រែតាកោ | 27 | 26 | 27% | 26% | 53% | 100 |
| 6070707 | | | | 42 | ត្រើយម៉្យាប | 14 | 34 | 6% | 14.70% | 20.70% | 232 |
| 6070708 | | | | 43 | លាវ | 34 | 24 | 16.30% | 11.50% | 27.90% | 208 |
| 6070709 | | | | 44 | បន្ទាយយមរាជ | 4 | 28 | 1.30% | 9.30% | 10.70% | 300 |
| 6070710 | | | | 45 | ត្នោតជុំ | 2 | 3 | 5.40% | 8.10% | 13.50% | 37 |
| 6080901 | | ស្ទោង | ប្រឡាយ | 46 | អង្គឃ្លាំ | 17 | 25 | 7.40% | 10.90% | 18.30% | 230 |
| 6080902 | | | | 47 | កំពង់វាំង | 33 | 31 | 19.40% | 18.20% | 37.60% | 170 |
| 6080903 | | | | 48 | ព្រៃខ្លា | 35 | 19 | 16.30% | 8.80% | 25.10% | 215 |
| 6080904 | | | | 49 | ប្រឡាយ | 20 | 18 | 19.20% | 17.30% | 36.50% | 104 |
| 6080905 | | | | 50 | គោករវៀង | 41 | 33 | 34.20% | 27.50% | 61.70% | 120 |
| 6080906 | | | | 51 | អន្លង់ព្រីង | 43 | 21 | 38.40% | 18.80% | 57.10% | 112 |
| 6080907 | | | | 52 | កំព្រាល | 39 | 58 | 17.50% | 26% | 43.50% | 223 |
| 6080908 | | | | 53 | កន្ទាន | 33 | 22 | 24.80% | 16.50% | 41.40% | 133 |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| 6080909 | | | | 54 | នាងសល្ងាច | 17 | 16 | 23.30% | 21.90% | 45.20% | 73 |
| 6080910 | | | | 55 | ថ្មី | 62 | 34 | 28.10% | 15.40% | 43.40% | 221 |
| 6080911 | | | | 56 | ក្រែក | 20 | 59 | 9.70% | 28.50% | 38.20% | 207 |
| 6080912 | | | | 57 | ឈូក | 72 | 37 | 30.10% | 15.50% | 45.60% | 239 |
| 6080913 | | | | 58 | តាទ្រាល | 83 | 32 | 43.70% | 16.80% | 60.50% | 190 |
| 6080914 | | | | 59 | ស្រែតាម៉ែន | 21 | 13 | 37.50% | 23.20% | 60.70% | 56 |
| **ចំនួនសរុប/ មធ្យមភាគ** | | | | | | **1936** | **2244** | **17.77%** | **20.31%** | **38.07%** | **11983** |
| 3120601 | | | | 1 | ក្រែកត្បូង | 8 | 64 | 1.80% | 14.60% | 16.40% | 438 |
| 3120602 | | | | 2 | ក្រែកជើង | 14 | 66 | 4.90% | 23% | 27.90% | 287 |
| 3120603 | | | | 3 | ជីមាន់ត្បូង | 8 | 48 | 3.70% | 22.10% | 25.80% | 217 |
| 3120604 | | | | 4 | ជីមាន់ជើង | 7 | 24 | 3.70% | 12.70% | 16.40% | 189 |
| 3120605 | | | | 5 | ជីមាន់កណ្ដាល | 2 | 8 | 0.50% | 2.10% | 2.60% | 386 |
| 3120606 | | | | 6 | ជីមាន់លិច | 17 | 5 | 9.30% | 2.70% | 12.10% | 182 |
| 3120607 | | | | 7 | ពើក | 11 | 69 | 3.10% | 19.20% | 22.30% | 359 |
| 3120608 | | | | 8 | ហួចលិច | 21 | 22 | 16.50% | 17.30% | 33.90% | 127 |
| 3120609 | | | | 9 | ហួចកើត | 20 | 44 | 10.80% | 23.80% | 34.60% | 185 |
| 3120610 | | | | 10 | ព្រៃទទឹង | 7 | 28 | 10.10% | 40.60% | 50.70% | 69 |
| 3120611 | | | | 11 | ទួលអង្រុង | 21 | 32 | 13.20% | 20.10% | 33.30% | 159 |
| 3120612 | | | | 12 | នាងនយ | 11 | 24 | 9.20% | 20% | 29.20% | 120 |
| 3120613 | | | | 13 | ត្រសិត | 13 | 30 | 7.80% | 18.10% | 25.90% | 166 |
| 3120614 | | | | 14 | កូវ | 17 | 16 | 23.30% | 21.90% | 45.20% | 73 |
| 3120615 | កំពង់ចាម | ពញាក្រែក | ក្រែក | 15 | ល្អក់ | 10 | 39 | 5.80% | 22.50% | 28.30% | 173 |
| 3120616 | | | | 16 | គរ | 3 | 25 | 1.20% | 10.20% | 11.50% | 244 |
| 3120617 | | | | 17 | អំពុក | 4 | 42 | 1.40% | 14.70% | 16.10% | 286 |
| 3120618 | | | | 18 | ជីពាំង | 27 | 81 | 5.90% | 17.60% | 23.50% | 460 |
| 3120619 | | | | 19 | បុសល្វេ | 18 | 39 | 9.70% | 21.10% | 30.80% | 185 |
| 3120620 | | | | 20 | សមាគម | 52 | 73 | 12.40% | 17.30% | 29.70% | 421 |
| 3120621 | | | | 21 | ត្រពាំងសុខា | 9 | 12 | 12.90% | 17.10% | 30% | 70 |
| 3120622 | | | | 22 | អណ្ដូងជ័យ | 21 | 17 | 12.70% | 10.20% | 22.90% | 166 |
| 3120623 | | | | 23 | សេរីសុខា | 39 | 66 | 6.70% | 11.30% | 17.90% | 585 |
| 3120624 | | | | 24 | ជីតុក | 20 | 34 | 11.70% | 19.90% | 31.60% | 171 |
| 3120625 | | | | 25 | មេម៉ៃ | 23 | 56 | 4.40% | 10.70% | 15.10% | 524 |
| 3120626 | | | | 26 | ស្រែទឹក | 7 | 12 | 14.90% | 25.50% | 40.40% | 47 |
| 3120627 | | | | 27 | ស្ពំ | 23 | 85 | 4.80% | 17.90% | 22.70% | 475 |
| 3120628 | | | | 28 | រោងចក្រ | 0 | 5 | 0 | 7.60% | 7.60% | 66 |
| 3120629 | | | | 29 | សំបូរផល | 4 | 9 | 7.50% | 17% | 24.50% | 53 |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| 3120631 | | | | 30 | ភូមិ ៥៥ | 4 | 24 | 1.70% | 10.20% | 11.90% | 235 |
| 3120632 | | | | 31 | ភូមិ ៥៤ | 6 | 8 | 10.50% | 14% | 24.60% | 57 |
| 3120633 | | | | 32 | ភូមិ ៣៧ | 4 | 11 | 4.50% | 12.50% | 17% | 88 |
| 3120635 | | | | 33 | ព្រីក្ស | 30 | 42 | 11.60% | 16.20% | 27.80% | 259 |
| 3120901 | | | វាលម្លូ | 34 | ច្រាប | 44 | 4 | 30.10% | 2.70% | 32.90% | 146 |
| 3120902 | | | | 35 | ស្រឡៅច្រឹង | 21 | 33 | 10% | 15.70% | 25.70% | 210 |
| 3120903 | | | | 36 | វាលម្លូ | 40 | 46 | 12.80% | 14.70% | 27.60% | 312 |
| 3120904 | | | | 37 | ដំបងអំពាក់ | 23 | 14 | 16.30% | 9.90% | 26.20% | 141 |
| 3120905 | | | | 38 | កប្បាស | 26 | 10 | 24.30% | 9.30% | 33.60% | 107 |
| 3120906 | | | | 39 | ក្រញូង | 54 | 63 | 14.80% | 17.30% | 32.10% | 365 |
| 3120907 | | | | 40 | សុខចំរើន | 20 | 18 | 19.20% | 17.30% | 36.50% | 104 |
| 3120908 | | | | 41 | ១០.៨ | 45 | 3 | 51.70% | 3.40% | 55.20% | 87 |
| 3010901 | | បាធាយ | តាំងក្រាំង | 42 | ភ្នំដិល | 32 | 33 | 11.50% | 11.80% | 23.30% | 279 |
| 3010902 | | | | 43 | ជើងឆ្នុក | 55 | 84 | 9.10% | 13.90% | 23.10% | 603 |
| 3010903 | | | | 44 | ត្បូងភ្នំ | 26 | 55 | 11% | 23.30% | 34.30% | 236 |
| 3010904 | | | | 45 | ពពិត | 28 | 17 | 26.40% | 16% | 42.50% | 106 |
| 3010905 | | | | 46 | អកទ្បេង | 26 | 69 | 8.60% | 22.90% | 31.60% | 301 |
| 3010906 | | | | 47 | កំពង់ព្រះ | 17 | 28 | 11.50% | 18.90% | 30.40% | 148 |
| 3010907 | | | | 48 | តាំងគោក | 162 | 70 | 35.80% | 15.50% | 51.30% | 452 |
| 3010908 | | | | 49 | ប្រាសាទ | 11 | 17 | 12.90% | 20% | 32.90% | 85 |
| 3011001 | | | តាំងក្រសាំង | 50 | បឹងវែង | 45 | 50 | 13.40% | 14.90% | 28.40% | 335 |
| 3011002 | | | | 51 | ក្រដាស ក | 36 | 22 | 22.60% | 13.80% | 36.50% | 159 |
| 3011003 | | | | 52 | ក្រដាស ខ | 25 | 33 | 10.50% | 13.80% | 24.30% | 239 |
| 3011004 | | | | 53 | ស្តុកធំ | 20 | 32 | 8.80% | 14% | 22.80% | 228 |
| 3011005 | | | | 54 | ត្រាវភ្នី | 30 | 30 | 17% | 17% | 34.10% | 176 |
| 3011006 | | | | 55 | ខ្វិត | 24 | 41 | 9.80% | 16.70% | 26.40% | 246 |
| 3011007 | | | | 56 | បឹង | 10 | 15 | 13.90% | 20.80% | 34.70% | 72 |
| 3011008 | | | | 57 | ខ្ទុំ | 12 | 28 | 8.20% | 19.20% | 27.40% | 146 |
| 3011009 | | | | 58 | ចាន់ | 24 | 28 | 20.50% | 23.90% | 44.40% | 117 |
| 3011010 | | | | 59 | ជីនាង | 32 | 23 | 35.60% | 25.60% | 61.10% | 90 |
| **ចំនួនសរុប** | | | | | | **1369** | **2026** | **12.28%** | **16.34%** | **28.64%** | **13012** |

**ប្រភព:** *របាយការណ៍ចេញពីទិន្នន័យមូលដ្ឋានគ្រួសារក្រីក្រ*

| | |
|---|---|
| (cyan) | ជម្រើសទី១ |
| (green) | ជម្រើសទី២ |
| (light blue) | ជម្រើសទី៣ |

## ឧបសម្ព័ន្ធ ២០៣ ៖បញ្ជីគ្រួសារក្រីក្រតាមភូមិនៃឃុំ សង្កាត់គោលដៅ

| ខេត្ត | ស្រុក | ឃុំ | ភូមិ | ឈ្មោះមេគ្រួសារ | ភេទ | ឈ្មោះប្តីឬប្រពន្ធ | ចំណាត់ | ខេត្ត | ស្រុក | ឃុំ | ភូមិ | ឈ្មោះមេគ្រួសារ | ភេទ | ឈ្មោះប្តីឬប្រពន្ធ | ចំណាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| បន្ទាយមានជ័យ | ភ្នំស្រុក | ពង្រ | ពង្រ | ណែប ស៊ីណូ | ប្រុស | ម៉ាន់ ត្រា | 1 | | | | | បូ រ៉ន | ប្រុស | បួត ធើប | 1 |
| | | | | ល័ក្ខ ឈឿត | ប្រុស | ធិប សៀង | 1 | | | | | ស៊ូ ប៊ុនស៊ី | ប្រុស | សិ សាអៀម | 1 |
| | | | | ញ៉ូយ ឈាត | ប្រុស | លួស យាយ | 1 | | | | | ហ៊ន់ ស្ទួន | ប្រុស | លោម ផៃ | 1 |
